ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ក្រុមការងារផអ៣ ទី២ ក្រសួងមហាផ្ទៃ

# របាយការណ៍ប្រចាំឆ្នាំ
# ស្តីពី
# ការអនុវត្តគម្រោង
# ថ្នាក់ក្រោមជាតិឆ្នាំ២០១៧

- ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និង គម្រោងក្រុង ស្រុក
- ការសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប
- បញ្ហាប្រឈមចម្បងបើអវត្តមាន PIA
- កត្តាដែលធ្វើឱ្យការអនុវត្តគម្រោងបានល្អ
- រូបភាពខ្លះៗ នៃការអនុវត្តគម្រោង

ខែមករា ឆ្នាំ២០១៨

## មាតិកា


**១. សេចក្តីផ្តើម ..... 3**

**២. រចនាសម្ព័ន្ធគាំទ្រក្នុងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិ ..... 4**

**៣. គាំទ្រនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ..... 7**

៣.១. ការវិភាជន៍មូលនិធិឃុំ សង្កាត់ ..... 7

៣.២. គាំទ្រដល់ដំណើរការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ..... 8

៣.២.១. គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ ..... 8

៣.២.២. គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ ..... 8

៣.២.៣. គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ..... 19

៣.២.៣.១. ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ..... 19

៣.២.៣.២. ការធ្វើលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ..... 20

៣.២.៣.៣. ការអនុវត្តកិច្ចសន្យាគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ..... 24

៣.២.៤. ការចុះតាមដានការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ..... 25

៣.២.៥. បញ្ហាប្រឈមក្នុងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ..... 28

៣.២.៦. អនុសាសន៍ក្នុងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ..... 30

**៤. គាំទ្រដល់ដំណើរការរៀបចំគម្រោងមូលនិធិក្រុង ស្រុក ..... 31**

៤.១. ប្រវត្តិនៃមូលនិធិក្រុង ស្រុក ..... 31

៤.២. ប្រភពមូលនិធិក្រុង ស្រុក ..... 31

៤.៣. ការអនុវត្តគម្រោងក្រុង ស្រុក ..... 33

៤.៣.១. ការរៀបចំគម្រោងក្រុង ស្រុក ដោយប្រើប្រាស់មូលនិធិរាជរដ្ឋាភិបាលឆ្នាំ២០១៧ ..... 33

៤.៣.២. ការធ្វើលទ្ធកម្មគម្រោង ..... 34

៤.៣.៣. ការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង ..... 35

៤. ៤ បញ្ហាចម្បងខ្លះៗក្នុងការអនុវត្តគម្រោងក្រុង ស្រុក ..... 35

៤.៤.១. ការរៀបចំសំណើគម្រោងក្រុង ស្រុក ..... 35

៤.៤.២. ការធ្វើលទ្ធកម្មគម្រោង ..... 36

៤.៤.៣. ការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង ..... 36

៤.៥. អនុសាសន៍ និងដំណោះស្រាយ ..... 37

៤.៥.១. ការរៀបចំសំណើគម្រោងក្រុង ស្រុក ..... 37

៤.៥.២. ការធ្វើលទ្ធកម្មគម្រោង ..... 37

៤.៥.៣. ការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង ..... 37

**៥. គាំទ្រនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត ..... 38**
៥.១. ការរៀបចំគម្រោងរាជធានី ខេត្ត ..... 38
៥.២. រៀបចំបញ្ជីតម្លៃសម្ភារស្តង់ដា ..... 38
៥.៣. គាំទ្រលើការងារត្រួតពិនិត្យ និងពង្រឹងសមត្ថភាព ..... 39
**៦. សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ..... 39**
៦.១. ប្រវត្តិនៃការសហការកែសម្រួលគំនូសប្លង់ ..... 39
៦.២. គោលបំណងនៃការកែសម្រួល ..... 40
៦.៣. លទ្ធផលនៃការកែសម្រួលឆ្នាំ២០១៧ ..... 40
៦.៤. ផែនការឆ្នាំ២០១៨ ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ..... 41
**៧. ការគាំទ្ររបស់ PIA ដល់ថ្នាក់ក្រោមជាតិ ..... 41**
៧.១ តួនាទី PIA ក្នុងការជួយគាំទ្រវិមជ្ឈការនៅថ្នាក់ក្រោមជាតិ ..... 42
៧.២ បញ្ហាប្រឈមចម្បងបើអវត្តមាន PIA ..... 43
**៨. កត្តាដែលធ្វើឱ្យការអនុវត្តគម្រោងបានល្អ ..... 44**
៨.១. មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ (TSO) ..... 44
៨.២. អ្នកទទួលការ ..... 45
៨.៣. គណៈកម្មការគ្រប់គ្រងគម្រោង ..... 45
៨.៤. ឧបករណ៍ត្រួតពិនិត្យបច្ចេកទេស ..... 45
៨.៥. ចុះពិនិត្យពីថ្នាក់ជាតិ ..... 46
៨.៦. កត្តាផ្សេងៗទៀត ..... 46
**៩. សំណូមពរ ..... 46**
**១០. ផែនការឆ្នាំ ២០១៨ ..... 47**
**១១. ឧបសម្ព័ន្ធ ..... 48**
ឧបសម្ព័ន្ធទី១ ៖ របាយការណ៍នៃការចុះតាមដានការអនុវត្តគម្រោង ..... 48
ឧបសម្ព័ន្ធទី២ ៖ របាយការណ៍ស្តីពីការសិក្សាពីករណីមិនប្រក្រតី និងអនុសាសន៍ ..... 48
ឧបសម្ព័ន្ធទី៣ ៖ រូបភាពមួយចំនួនស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ..... 48
ឧបសម្ព័ន្ធទី៤ ៖ ឧបករណ៍សម្រាប់ជួយគាំទ្រការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ..... 48
ឧបសម្ព័ន្ធទី៥ ៖ បញ្ជីទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងអ្នកពាក់ព័ន្ធការងារ ..... 48

## ១. សេចក្តីផ្តើម

នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលបានរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ២០១០-២០១៩ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការអនុវត្តកម្មវិធីជាតិត្រូវបានបែងចែកជា៣ដំណាក់កាល និងគ្រប់គ្រងសម្របសម្រួលដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។

ផែនការអនុវត្តរយៈពេល៣ឆ្នាំដំណាក់កាលទី១ (ផអ៣ទី១) ពីឆ្នាំ២០១១-២០១៣ និងពន្យាររពេលមួយឆ្នាំបន្ថែមទៀត គឺឆ្នាំ២០១៤ ដូច្នេះផអ៣ទី១ មានរយៈពេល៤ឆ្នាំ (២០១១-២០១៤) ដែលផ្តោតលើ**ការអភិវឌ្ឍប្រព័ន្ធ និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ត្រូវបានបញ្ចប់នៅខែធ្នូឆ្នាំ២០១៤ ហើយផែនការអនុវត្តរយៈពេល៣ឆ្នាំដំណាក់កាលទី២ (ផអ៣ទី២) បានចាប់ផ្តើមពីឆ្នាំ២០១៥-២០១៧ ហើយមានចក្ខុវិស័យផ្តោតលើ "**រដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានបានកាន់តែច្រើន កាន់តែល្អប្រសើរ កាន់តែមានលក្ខណៈឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន**"។ **ផអ៣ទី៣** ពីឆ្នាំ២០១៨-២០២០ មានគោលបំណងបន្តពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យកាន់តែមានស្វ័យភាព និងគណនេយ្យភាព ក្នុងការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឲ្យកាន់តែប្រសើរថែមទៀត។

គម្រោងមូលនិធិឃុំ សង្កាត់៩ឆ្នាំមុនកម្មវិធី**ផអ៣** (២០០២-២០១០) គម្រោងឃុំ សង្កាត់សរុបមានចំនួន១៥.៣៩១គម្រោង ដែលក្រុមប្រឹក្សារដ្ឋបាលឃុំ សង្កាត់គឺជាម្ចាស់គម្រោងដែលមានស្វ័យភាពក្នុងការធ្វើសេចក្តីសម្រេចលើការអនុវត្តគម្រោង ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ បានចំណាយមូលនិធិឃុំ សង្កាត់វិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធដូចខាងក្រោម៖

- ✓ ៧៥% លើផ្លូវលំជនបទ (ផ្លូវដី ផ្លូវក្រួសក្រហម សំណង់លូ ស្ពាន...)
- ✓ ១២% លើប្រព័ន្ធស្រោចស្រព (ប្រឡាយ សំណង់សិល្បការ)
- ✓ ០៦% លើផ្លូវនៅទីប្រជុំជន (ផ្លូវក្រួសក្រហម ផ្លូវបេតុង ផ្លូវកៅស៊ូ)
- ✓ ០៣% លើទឹកស្អាតជនបទ (អណ្តូងទឹក ស្រះ)
- ✓ ០៣% លើសាលារៀន (សាលារៀនថ្ម និងឈើ)
- ✓ ០១% ផ្សេងៗ (លូដោះទឹក បង្គន់ ប្រព័ន្ធទុយោទឹកស្អាត បរិស្ថាន...)

គម្រោងមូលនិធិឃុំ សង្កាត់៧ឆ្នាំចុងក្រោយក្នុងកម្មវិធីផអ៣ទី១ និងផអ៣ទី២ (២០១១-២០១៧) គម្រោងឃុំ សង្កាត់សរុបមានចំនួន១២.២៣១គម្រោង ដែលភាគច្រើននៃគម្រោងទាំងនោះបានផ្តោតទៅលើ៖

- ✓ ៨៨% លើផ្លូវលំជនបទ (ផ្លូវដី ផ្លូវក្រួសក្រហម ផ្លូវបេតុង និងស្ពាន)
- ✓ ០៧% លើប្រព័ន្ធស្រោចស្រព (ប្រឡាយ និងសំណង់សិល្បការផ្សេងៗ)
- ✓ ០៣% លើអនាម័យជនបទ (លូទឹកស្អុយ បង្គន់ និងប្រព័ន្ធបង្ហូរទឹក)
- ✓ ០១% លើការផ្គត់ផ្គង់ទឹកស្អាត (អណ្តូង ស្រះ និងប្រព័ន្ធបំពង់ទុយោ)
- ✓ ០១% លើសំណង់ផ្សេងៗទៀត (អគារសាលារៀន អគារសុខាភិបាល អគារសង្គម សំណង់ផ្សារ និងសំណង់សម្រាប់ទឹកជំនន់)

ប្រភព: ដកស្រង់ចេញពីប្រព័ន្ធទិន្នន័យគម្រោងមូលនិធិឃុំ សង្កាត់ (PID-NCDD Website)

ចំនួនគម្រោងមូលនិធិឃុំ សង្កាត់ដែលបានអនុវត្តពីឆ្នាំ២០០២-២០១៧ រយៈពេល១៦ឆ្នាំ មានសរុប ២៧.៦២២គម្រោង និងប្រើប្រាស់មូលនិធិអភិវឌ្ឍន៍អស់២.៤៦៧.៤២៧.៤៣៨.០០០រៀល (មូលនិធិដែលបានវិភាជន៍) ស្មើនឹង ៦០៩.២៤១.៣៤២,៧២ដុល្លារអាមេរិក។

| ឆ្នាំ | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|---|---|
| ចំនួនគម្រោង | 500 | 1,887 | 1,994 | 1,948 | 2,087 | 1,757 | 1,757 | 1,817 |
| មូលនិធិអភិវឌ្ឍន៍ $ | 4,157,960 | 7,908,822 | 9,547,325 | 11,206,913 | 13,128,098 | 14,082,962 | 14,861,427 | 19,510,098 |
| | | | | | | | | |
| ឆ្នាំ | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 |
| ចំនួនគម្រោង | 1644 | 1697 | 1849 | 1784 | 1711 | 1723 | 1713 | 1754 |
| មូលនិធិអភិវឌ្ឍន៍ $ | 27,160,558 | 26,369,876 | 31,914,320 | 37,113,827 | 32,601,481 | 32,631,851 | 30,442,162 | 36,494,074 |

ក្នុងការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់បានអនុវត្តតាមគោលការណ៍ និងនីតិវិធីនានាដែលបានកំណត់នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងឃុំ សង្កាត់ ដែលតម្រូវឱ្យមានការចូលរួម តម្លាភាព គណនេយ្យភាព ការឆ្លើយតប សុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។ ក្នុងគោលបំណងទប់ស្កាត់នូវអំពើឃុបឃិតគ្នាក្នុងដំណើរការរៀបចំគម្រោង ការដេញថ្លៃ និងការអនុវត្តគម្រោង ក្រសួងមហាផ្ទៃបានដាក់ចេញនូវសេចក្តីណែនាំថ្មីៗមួយចំនួនបន្ថែមលើនីតិវិធីអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងរៀបចំយន្តការតាមដានត្រួតពិនិត្យនៅថ្នាក់ក្រោមជាតិ។

ឆ្នាំ២០១៦ មាន១៣ឃុំ សង្កាត់បានបង្កើតថ្មី តែពុំទាន់បានទទួលមូលនិធិឃុំ សង្កាត់សម្រាប់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានរបស់ខ្លួនទេក្នុងឆ្នាំ២០១៧នេះ។ ក្នុងឆ្នាំនេះការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មានតែ ១.៦៣៣ឃុំ សង្កាត់ទូទាំងប្រទេស ដែលមានថវិកាវិភាជន៍ពីរាជរដ្ឋាភិបាលផ្នែកអភិវឌ្ឍន៍សរុបទាំង២៤ ខេត្ត រាជធានី ១៤៧.៨១០.០០០.០០០រៀល ប្រហាក់ប្រហែល៣៦,៥០លានដុល្លារអាមេរិក។

ក្នុងឆ្នាំ២០១៧នេះគឺជាឆ្នាំដែលមានព្រឹត្តិការណ៍ពិសេសមួយគឺការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ នៅថ្ងៃទី៤ **ខែមិថុនា ឆ្នាំ២០១៧**។ ព្រឹត្តិការណ៍នេះក៏ជះឥទ្ធិពលបន្តិចបន្តួចលើការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់ដោយធ្វើឱ្យមានអំពើឃុបឃិតច្រើនក្នុងពេលដេញថ្លៃគម្រោង តែត្រូវបានគ្រប់គ្រងឱ្យមានស្ថានភាពល្អវិញក្រោយការបោះឆ្នោត។ ទោះជាមានទឹកភ្លៀងធ្លាក់ច្រើនជាប់រហូតក្នុងឆ្នាំនេះយ៉ាងណាក៏ដោយ គិតមកដល់ដំណាច់ខែធ្នូ ឆ្នាំ២០១៧នេះ ការរៀបចំគម្រោង ការដេញថ្លៃ ការរៀបចំកិច្ចសន្យា និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ទទួលបាននូវលទ្ធផលប្រហាក់ប្រហែលឆ្នាំ២០១៦ និងឆ្នាំកន្លងមកដែរ។ សូមមើលលម្អិតនូវចំណុចធំទី៣ (គាំទ្រដល់ដំណើរការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់) ទំព័រទី៧។

## ២. រចនាសម្ព័ន្ធគាំទ្រក្នុងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិ

ក្នុងការជួយគាំទ្រដល់ដំណើរការរៀបចំការអនុវត្តគម្រោងនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប មានរចនាសម្ព័ន្ធគាំទ្រពីថ្នាក់ជាតិដល់ថ្នាក់ខេត្ត ក្រោមការដឹកនាំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងមហាផ្ទៃ

ដែលមានអគ្គនាយកដ្ឋានរដ្ឋបាល (GDA) ប្រធាន អនុប្រធាន និងមន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ (DDC) ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ (NIA) និងនៅថ្នាក់ខេត្តមានទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ខេត្ត (PIA) និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ (TSO) ដែលមានសមាសភាពដូចខាងក្រោម ៖

- ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរដ្ឋបាល ប្រធាន អនុប្រធាន និងមន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ដែលមានការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់ជាសេនាធិការក្នុងការចុះគាំទ្រដល់ថ្នាក់ក្រោមជាតិ។
- ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ០១នាក់ នៅនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។
- ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ខេត្តសរុប២៣នាក់ (ស្ត្រី១នាក់) បានបំពេញការងារតាមរាជធានីខេត្តរៀងៗខ្លួន ដោយឡែកខេត្តប៉ៃលិន និងខេត្តកែបគ្មានទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធទេ (ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធប្រចាំខេត្តកំពតត្រូវជួយមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធនៅខេត្តកែប ចំណែកឯទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធប្រចាំខេត្តបាត់ដំបងត្រូវជួយមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធនៅខេត្តប៉ៃលិន)។ គិតដល់ដំណាច់ខែធ្នូ ឆ្នាំ២០១៧ មានខេត្តបាត់ដំបង និងខេត្តតាកែវ គ្មានទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្តទេ ដោយសារទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្តបាត់ដំបង បានសុំប្តូរទៅខេត្តស្វាយរៀង និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្តតាកែវបានសុំលាឈប់។ សូមមើលតារាងខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ឈ្មោះPIAលាឈប់ | ឈ្មោះ PIAជំនួសថ្មី | សម្គាល់ |
|---|---|---|---|---|
| ១ | តាកែវ | លោក គួច វុឌ្ឍី (31 Dec 2014) | លោក ប៉ុង វីរៈ (17 July 2017) | លោក ប៉ុង វីរៈ បានលាឈប់ (15 November 2017) |
| ២ | កំពត | លោក សូ សារ៉ន (30 June 2016) | លោក អ៊ុំ ឆាយណយ (07 August 2017) | បានជ្រើសរើសបំពេញ |
| ៣ | កំពង់ចាម | លោក ច្រេស ប៊ុនថា បានស្លាប់ 31 May 2016 | លោក សូ សារ៉ន (15 August 2017) | បានជ្រើសរើសបំពេញ |
| ៤ | ស្វាយរៀង | លោក សៀង សិទ្ធ (31 Jan 2017) | លោក មួន សុខុម (1st Sept. 2017) | លោក សៀង សិទ្ធ បានសុំឈប់មកបម្រើការនៅ CDRR/NCDDS និងលោក មួន សុខុម មកជំនួសវិញ |
| ៥ | បាត់ដំបង | លោក មួន សុខុម (1st Sept. 2017) | ជ្រើសរើសបាន តែមិនទាន់ហៅចូលធ្វើការ ខ្លាចមានការប្រែប្រួល | លោក ....... រើសថ្មីមកជំនួសលោក មួន សុខុម ដែលសុំប្តូរពីខេត្ត BAT ទៅ SVR |
| 6 | តាកែវ | លោក ប៉ុង វីរៈ (17 July 2017) | | លោក ប៉ុង វីរៈ បានលាឈប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១៧ |

* គិតដល់ដំណាច់ខែធ្នូ ឆ្នាំ២០១៧នេះ មានខេត្តពីរគឺខេត្តតាកែវ និងខេត្តបាត់ដំបងគ្មានទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធទេ។

- មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ សរុបទូទាំងប្រទេសគិតមកដល់ចុងឆ្នាំ២០១៧ មាន១៨៩នាក់ (ស្រ្តី២នាក់)។ តាមរបាយការណ៍ពី២៥រាជធានី ខេត្តបង្ហាញថា៖ TSO ជាមន្ត្រីសាលាខេត្តមាន ៦៧% TSO មកពីមន្ទីរជំនាញក្នុងខេត្តមាន២៧% និង TSO សុំលាឈប់មាន៦% នៃមន្ត្រី TSO សរុបទាំងអស់។

តារាងខាងក្រោមបង្ហាញពីស្ថានភាពមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធពីឆ្នាំ២០១៣-២០១៧

| ការបរិយាយ | ចុងឆ្នាំ ២០១៣ | ឆ្នាំ២០១៤ | | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ |
|---|---|---|---|---|---|
| | | ខែមិថុនា | ខែវិច្ឆិកា | វិច្ឆិកា | ធ្នូ |
| TSO សរុប | ១៨៧ | ១៩៤ | ១៩៤ | ១៩៩ | ១៨៩ |
| TSO ជាមន្ត្រីសាលាខេត្ត | ៣៦% | ៤៤% | ៥៦% | ៦១% | ៦៧% |
| TSO មកពីមន្ទីរជំនាញក្នុងខេត្ត | ៦០% | ៤៩% | ៣៨% | ៣៣% | ២៧% |
| TSO សុំឈប់ | ៤% | ៧% | ៦% | ៦% | ៦% |




☞ កម្រិតវប្បធម៌មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ (TSO)

ផ្អែកតាមការធ្វើអង្កេតនៅចុងឆ្នាំ២០១៧ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ ៨៤% មិនមានមូលដ្ឋានគ្រឹះជាអ្នកបច្ចេកទេសទេ (no background on technical) និង១៦%ជាអ្នកមានបរិញ្ញាបត្រ បរិញ្ញាបត្ររងផ្នែកបច្ចេកទេស តែក្រុមពួកគាត់គឺគ្រាន់តែជាការរៀនបំពេញក្រេឌីតតាមសាលាឯកជន ដែលមិនទទួលបានចំណេះដឹងពេញលេញជាវិស្វករទេ ដូច្នេះពួកគាត់មានការពិបាកក្នុងការសិក្សាគម្រោងដែលត្រូវការបច្ចេកទេសខ្ពស់ និងស្មុគស្មាញ។ ខាងក្រោមនេះជាទូរលេខរបស់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធដែលនៅបម្រើការងារទាំង១៨៩នាក់ (ស្ត្រី២នាក់) ក្នុងផអ៣ទី២ទាំងអស់របស់រាជធានី និង២៤ខេត្ត៖

- ✓ ១៦% TSO ដែលមានសញ្ញាបត្រជាវិស្វករ និងមធ្យមបច្ចេកទេស
- ✓ ២៥% TSO ដែលមានសញ្ញាបត្រ តែមិនមែនបច្ចេកទេស (គ្រូបង្រៀន គ្រប់គ្រង បរិស្ថាន...)
- ✓ ១៥% TSO ដែលជាប់បាក់ឌុប និងក្រោមបាក់ឌុបដែលមានបទពិសោធន៍ជាមួយកម្មវិធី ១-២ឆ្នាំ
- ✓ ១៥% TSO ដែលជាប់បាក់ឌុប និងក្រោមបាក់ឌុបដែលមានបទពិសោធន៍ជាមួយកម្មវិធី ៣-៥ឆ្នាំ
- ✓ ២៨% TSO ដែលជាប់បាក់ឌុប និងក្រោមបាក់ឌុបដែលមានបទពិសោធន៍ជាមួយកម្មវិធីច្រើនជាង៥ឆ្នាំ

# ៣. គាំទ្រនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់

## ៣.១. ការវិភាជន៍មូលនិធិឃុំ សង្កាត់

**មូលនិធិឃុំ សង្កាត់** គឺជាមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ដែលមូលនិធិនេះទទួលបាននូវការចូលរួមធនធានប្រចាំឆ្នាំពីថវិការជាតិក្នុងកម្រិតអត្រា២,៨០%នៃចំណូលចរន្តថវិការជាតិដែលបានអនុម័តមួយឆ្នាំមុន។ ការវិភាជន៍ធនធានពីមូលនិធិឃុំ សង្កាត់សម្រាប់ឃុំ សង្កាត់នីមួយៗ ត្រូវបានធ្វើឡើងតាមរូបមន្តដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ និងសន្ទស្សន៍ជាក់លាក់ដូចជា **ចំណែកស្មើគ្នាជាមូលដ្ឋាន ចំនួនប្រជាពលរដ្ឋ និងសន្ទស្សន៍នៃភាពក្រីក្រ**។ មូលនិធិឃុំ សង្កាត់ត្រូវបានបែងចែកជាពីរសមាសភាគ គឺសមាសភាគរដ្ឋបាលទូទៅ និងសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។

☞ការវិភាជន៍មូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ មាន ៣៧៥,៤០៤លានរៀល (៩២.៦៩លានដុល្លារ) ដែលឃុំ សង្កាត់នីមួយៗ បានទទួលមូលនិធិជាមធ្យម ៥៦,៧៦២ដុល្លារ ស.រ.អា។ មូលនិធិឃុំ សង្កាត់ត្រូវបានវិភាជន៍ជាពីរសមាសភាគដូចខាងក្រោម៖

- សមាសភាគសម្រាប់រដ្ឋបាល និង
- សមាសភាគសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន

| ចំណាយប្រតិបត្តិការរដ្ឋបាល | ចំណាយអភិវឌ្ឍន៍មូលដ្ឋាន |
|---|---|
| ៣០% សម្រាប់ចំណែកស្មើ | ៣០% សម្រាប់ចំណែកស្មើ |
| ៦០% សម្រាប់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ៣០% សម្រាប់ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ |
| ១០% សម្រាប់សន្ទស្សន៍ភាពក្រីក្រ | ៣០% សម្រាប់សន្ទស្សន៍ភាពក្រីក្រ |
| | ១០% សម្រាប់ចំនួនភូមិក្នុងឃុំ សង្កាត់ |

ប្រភពៈ បទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦

ក្រាហ្វិកខាងក្រោមជាថវិការជាតិដែលបានផ្ទេរចូលមូលនិធិឃុំ សង្កាត់សរុប (ផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍) ពីឆ្នាំ២០០២ ដល់ឆ្នាំ២០១៧។






ប្រភពៈ បទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧។
**សម្គាល់៖** ចាប់ពីឆ្នាំ២០១៥ ដល់បច្ចុប្បន្នមូលនិធិឃុំ សង្កាត់ផ្នែកអភិវឌ្ឍន៍បានថយចុះ ដោយសារការដំឡើងប្រាក់ខែដល់ក្រុមប្រឹក្សាឃុំ សង្កាត់។

## ៣.២. គាំទ្រដល់ដំណើរការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

ជួយគាំទ្រដល់ដំណើរការរៀបចំការសិក្សាគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ ឆ្នាំ២០១៦ និងឆ្នាំ២០១៧ គិតត្រឹមពាក់កណ្ដាលខែធ្នូ ឆ្នាំ២០១៧នេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

### ៣.២.១. គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥

គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ បានបញ្ចប់ការសាងសង់ទូទាំងប្រទេសនៅពាក់កណ្ដាលខែឧសភា ឆ្នាំ២០១៧។ ក្នុងឆ្នាំ២០១៥ សរុបមាន១.៧២៣កិច្ចសន្យា លទ្ធផលបង្ហាញក្នុងតារាងខាងក្រោម៖

| ការបរិយាយ | ចំនួនកិច្ចសន្យា | គិតជា% | ផ្សេងៗ |
|---|---|---|---|
| បានបញ្ចប់ការសាងសង់ | ១.៧១៦ | ៩៩,៦% | ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ បានអូសបន្លាយ២ឆ្នាំ (ចាប់អនុវត្តខែឧសភា ឆ្នាំ២០១៥ ដល់ខែឧសភា ឆ្នាំ២០១៧) |
| អ្នកទទួលការបោះបង់ចោល | ៧ | 0,៤% | |

គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ដែលអ្នកទទួលការបោះបង់ចោលទាំង៧នោះ ម្ចាស់គម្រោងបានពិគ្រោះ និងប្រជុំជាមួយគណៈកម្មការគ្រប់គ្រងគម្រោងបង្វែរថវិកាដែលនៅសល់ដាក់ចូលក្នុងកញ្ចប់ថវិកាឆ្នាំ២០១៦ ដើម្បីធ្វើគម្រោងថ្មី ឬក៏ធ្វើលើគម្រោងដែលអ្នកទទួលការបោះបង់ចោលនោះបន្តឱ្យចប់។

### ៣.២.២. គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦

គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ សរុប១.៧១៣កិច្ចសន្យា គិតមកដល់ពាក់កណ្ដាលខែធ្នូ ឆ្នាំ២០១៧ នេះលទ្ធផលលម្អិតបង្ហាញតារាងខាងក្រោម៖

| ការបរិយាយ | ចំនួនកិច្ចសន្យា | គិតជា% | ផ្សេងៗ |
|---|---|---|---|
| បានបញ្ចប់ការសាងសង់១០០% | ១.៦០២ | ៩៣,៥% | បើធៀបនឹងឆ្នាំ២០១៥ យឺតជាង៥% |
| អនុវត្តបានលើសពី៥០% | ៧១ | ៤,១% | សរុប ៩៩កិច្ចសន្យា BMC=2 KPC=1 KCH=4 KPT=19 KAM=2 KDL=6 KKG=3 KRT=3 MKR=3 PVR=18 PVG=4 PUR=3 RAT=4 SRP=3 SHV=4 STG=4 OMC=8 and TKM=3 |
| អនុវត្តបានតិចជាង៥០% | ២៨ | ១,៦% | |
| មិនទាន់បានអនុវត្ត | ៥ | 0,៤% | PVR=18 RAT=1 and TKM=3 |
| អ្នកទទួលការបោះបង់ចោល+លប់ | ៧ | 0,៤% | BAT=1 KCH=1 KAM=1 KRT=3 RAT=1 |

☞ តារាងខាងក្រោមបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តតាមរាជធានី ខេត្តនីមួយៗក្នុងឆ្នាំ២០១៦

**វឌ្ឍនភាពនៃការអនុវត្តកិច្ចសន្យាគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ គិតត្រឹមថ្ងៃ១៥ ខែធ្នូ ឆ្នាំ២០១៧**




| លេខកូដរាជធានី ខេត្ត | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | ផ្ទៀងផ្ទាត់ | ភាគរយ | ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះកាត់រាជធានី ខេត្ត | BMC | BAT | KPC | KCH | KSP | KPT | KAM | KDL | KKG | KRT | MKR | PNP | PVR | PVG | PUR | RAT | SRP | SHV | STG | SVR | TAK | OMC | KEP | PLN | TKM | Verify | % | |
| កិច្ចសន្យាសរុប | 73 | 109 | 120 | 66 | 104 | 81 | 100 | 130 | 28 | 45 | 19 | 98 | 53 | 118 | 57 | 48 | 103 | 28 | 36 | 85 | 107 | 23 | 5 | 8 | 69 | 1713 | 100% | 1713 |
| មិនទាន់បានអនុវត្ត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | 5 | 0.3% | 5 |
| អនុវត្តបានតិចជាង ៥០% | 0 | 0 | 0 | 3 | 0 | 3 | 0 | 2 | 1 | 2 | 1 | 0 | 10 | 0 | 0 | 3 | 0 | 0 | 0 | 0 | 0 | 3 | 0 | 0 | 0 | 28 | 1.6% | 28 |
| អនុវត្តបានលើសពី ៥០% | 2 | 0 | 1 | 4 | 0 | 16 | 2 | 4 | 2 | 1 | 2 | 0 | 8 | 4 | 3 | 1 | 3 | 4 | 4 | 0 | 2 | 5 | 0 | 0 | 3 | 71 | 4.1% | 71 |
| បញ្ចប់ការសាងសង់១០០% | 71 | 108 | 119 | 58 | 104 | 62 | 97 | 124 | 25 | 39 | 16 | 98 | 34 | 114 | 54 | 42 | 100 | 24 | 32 | 85 | 105 | 15 | 5 | 8 | 63 | 1602 | 93.5% | 1602 |
| អ្នកទទួលការបោះបង់ | 0 | 1 | 0 | 1 | 0 | 0 | 1 | 0 | 0 | 3 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 7 | 0.4% | 7 |
| ផ្ទៀងផ្ទាត់តាមខេត្ត | 73 | 109 | 120 | 66 | 104 | 81 | 100 | 130 | 28 | 45 | 19 | 98 | 53 | 118 | 57 | 48 | 103 | 28 | 36 | 85 | 107 | 23 | 5 | 8 | 69 | 1713 | 100.0% | 1713 |

សម្គាល់: ខេត្តបាត់ដំបង កំពង់ស្ពឺ រាជធានីភ្នំពេញ ស្វាយរៀង កែប និងប៉ៃលិនបានបញ្ចប់ជាស្ថាពរការសាងសង់គម្រោង២០១៦ និង១៩ខេត្តកំពង់បន្តអនុវត្តការសាងសង់

គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ដែលមិនទាន់បញ្ចប់ការសាងសង់មាន៩៩កិច្ចសន្យា នៅ១៩ខេត្ត ហើយមូលហេតុនៃការយឺតយ៉ាវមានបញ្ជាក់ជូនក្នុងតារាងខាងក្រោម៖

| កូដ | ឈ្មោះគម្រោង | មូលហេតុ បញ្ហានៃការយឺតយ៉ាវ | បញ្ចប់ពេលណា |
|---|---|---|---|
| **០១. ខេត្ត បន្ទាយមានជ័យ** មានចំនួន ០២ គម្រោង | | | |
| ១ | **ឃុំគយម៉ែង៖** លើកផ្លូវលំ **ស្រុក៖** មង្គលបូរី | • ទីតាំងសាងសង់គម្រោងមានទឹកលិចសងខាង ទើបដាក់លូមិនបានព្រោះទឹកជ្រៅមិនអាចធ្វើផ្លូវវាងបាន | គ្រោងបញ្ចប់នៅខែមីនា ឆ្នាំ២០១៨ |
| ២ | **ឃុំបន្ទាយឆ្មា ៖** ស្ពារប្រឡាយ **ស្រុក៖** ថ្មពួក | • ប្រឡាយមានទឹកច្រើន និងកំពុងស្រោចស្រព ទើបមិនអាចអនុវត្តបាន។ បច្ចុប្បន្នប្រឡាយបានអស់ទឹកហើយ និងត្រៀមចុះបន្តការងារទៀតនៅចុងខែនេះ | គ្រោងបញ្ចប់នៅដើមខែមករា ឆ្នាំ ២០១៨ |
| **០៣. ខេត្តកំពង់ចាម** មានចំនួន ០១ គម្រោង | | | |
| ១ | **ឃុំស្ពឺ ៖** ជួសជុលផ្លូវដីក្រាលក្រួសក្រហម | • ទីតាំងគម្រោងនៅលិចទឹកមិនអាចចូលអនុវត្តបាន | គ្រោងបញ្ចប់នៅ ២៨/០២/២០១៨ |

| | | | |
|---|---|---|---|
| | ស្រុកៈ ចំការលើ | | |
| **០៤. ខេត្តកំពង់ឆ្នាំង** មានចំនួន០៦គម្រោង | | | |
| ១ | **ឃុំសំរោងសែន** ៈ ស្តារប្រឡាយដី<br>ស្រុកៈ កំពង់លែង | • ដោយសារទីតាំងគម្រោងស្ថិតក្នុងតំបន់ទឹកលិច អ្នកទទួលការមានការយឺតយ៉ាវក្នុងការចុះអនុវត្តផង ហើយឆ្នាំនេះ ភ្លៀងធ្លាក់ដើមឆ្នាំ និងច្រើន (អនុវត្តបានប្រមាណ ២០%)។ | គ្រោងបញ្ចប់<br>30/03/2018 |
| ២ | **ឃុំអូរឬស្សីៈ** សំណង់ទ្វារទឹក<br>ស្រុកៈ កំពង់ត្រឡាច | • ដោយសារភ្លៀងច្រើនពេក ទើបអនុវត្តបាន៧០% (បានទូរទាត់៥០%ហើយ) | គ្រោងបញ្ចប់<br>30/03/2018 |
| ៣ | **ឃុំ ក្រាំងលាវ** ៈ ជួសជុលផ្លូវក្រួសក្រហម<br>ស្រុកៈ រលាប្អៀរ | • អ្នកទទួលការមិនគោរពពេលវេលានៃការអនុវត្តក្នុងកិច្ចសន្យា ជាប់អនុវត្តនៅខេត្តផ្សេង នៅពេលកំពុងអនុវត្តភ្លៀងធ្លាក់ខ្លាំង (អនុវត្តបានប្រមាណ៣០%) | គ្រោងបញ្ចប់<br>15/02/2018 |
| ៤ | **ឃុំ ជើងគ្រាវៈ** ជួសជុលផ្លូវក្រួសធម្មជាតិ<br>ស្រុកៈ រលាប្អៀរ | • កម្រាសក្រួសមិនគ្រប់ ម្ចាស់គម្រោងមិនទទួលយក ក៏ដកគ្រឿងចក្រទៅកន្លែងផ្សេង។ ជាអ្នកទទួលការតែមួយជាមួយឃុំក្រាំងលាវ | គ្រោងបញ្ចប់<br>28/02/2018 |
| ៥ | **ឃុំ ឈានឡើងៈ** ជួសជុលផ្លូវក្រួសធម្មជាតិ<br>ស្រុកៈ សាមគ្គីមានជ័យ | • អ្នកទទួលការមិនបានបំពេញចំណុចខ្វះខាតក្នុងការសុំទូទាត់ ១០០% ធ្វើឱ្យម្ចាស់គម្រោង និងអ្នកបច្ចេកទេសមិនឯកភាពគ្នា | គ្រោងបញ្ចប់<br>31/12/2017 |
| ៦ | **ឃុំ ខ្លុងពពកៈ** ជួសជុលផ្លូវក្រួសធម្មជាតិ<br>ស្រុកៈ ទឹកផុស | • ទឹកភ្លៀងច្រើន | គ្រោងបញ្ចប់<br>20/01/2018 |
| **០៦. ខេត្ត កំពង់ធំ** មានចំនួន ១៩ គម្រោង | | | |
| ១ | **ឃុំបាក់ស្នា** ៈ គម្រោងជួសជុលផ្លូវលំក្រាលក្រួសក្រហម<br>ស្រុកៈ បារាយណ៍ | • ពីមុនមានភ្លៀងធ្លាក់ច្រើនផ្អាកសិន បច្ចុប្បន្នអាចចូលធ្វើបាន ហើយក្រុមហ៊ុននឹងចូលអនុវត្តឆាប់ៗ ។ | ក្នុង ខែមករា ឆ្នាំ ២០១៨ |
| ២ | **ឃុំបល្ល័ង្គ** ៈ គម្រោងជួសជុលផ្លូវលំក្រាលក្រួសក្រហម<br>ស្រុកៈបារាយណ៍ | • មានភ្លៀងធ្លាក់ច្រើនផ្អាកសិន ហើយទីតាំងខ្លះមានទឹកដក់។ បច្ចុប្បន្នអាចចូលបាន តែក្រុមហ៊ុនកំពុងអនុវត្តគម្រោងផ្សេងសិន | ក្នុង ខែកុម្ភៈ ឆ្នាំ ២០១៨ |
| ៣ | **ឃុំ បារាយណ៍ៈ** គម្រោងជួសជុលផ្លូវលំក្រាលក្រួសក្រហម<br>ស្រុកៈបារាយណ៍ | • ផ្លូវដែលត្រូវជួសជុលនៅសល់២០០មទៀតមានដក់ទឹកសងខាងផ្លូវ | ក្នុង ខែកុម្ភៈ ដល់ មីនា ឆ្នាំ ២០១៨ |
| ៤ | **ឃុំបឹងៈ** គម្រោងទ្វារទឹក៦កន្លែង<br>ស្រុកៈបារាយណ៍ | • កំពុងអនុវត្ត តែទីតាំងពីរកន្លែងទៀតមិនអាចដឹកសម្ភារចូលបាន | ក្នុង ខែកុម្ភៈ ដល់ មីនា ឆ្នាំ ២០១៨ |
| ៥ | **ឃុំចើងដើងៈ** គម្រោងសាងសង់ស្ពាន និងផ្លូវ<br>ស្រុកៈបារាយណ៍ | • មានភ្លៀងធ្លាក់ច្រើនផ្អាកសិន ប្រហែល១០ថ្ងៃទៀតអាចចូលបាន | ក្នុង ខែកុម្ភៈ ដល់ មីនា ឆ្នាំ ២០១៨ |
| ៦ | **ឃុំ ទ្រៀលៈ** គម្រោងជួសជុលផ្លូវលំក្រាលក្រួសក្រហម | • ផ្លូវដែលត្រូវជួសជុលនៅសល់៦០០មទៀតមានដក់ទឹកសងខាងផ្លូវ | ក្នុង ខែកុម្ភៈ ឆ្នាំ ២០១៨ |

| | | | |
|---|---|---|---|
| | ស្រុកៈបារាយណ៍ | | |
| ៧ | **ឃុំ នីពេជ** ៖ គម្រោងកែលម្អផ្លូវលំក្រាលក្រួសក្រហម<br>**ស្រុកៈ** កំពង់ស្វាយ | • ផ្លូវដែលត្រូវកែលម្អ មានដក់ទឹកសងខាង | ខែមករា ឆ្នាំ ២០១៨ |
| ៨ | **ឃុំ សាន់គរ** ៖ គម្រោងកែលម្អផ្លូវលំក្រាលក្រួសក្រហម<br>**ស្រុកៈ** កំពង់ស្វាយ | • ទីតាំងគម្រោងមានលូកាត់ប្រឡាយ ដែលមិនអាចសាសង់បាន | ខែកុម្ភៈ ឆ្នាំ ២០១៨ |
| ៩ | **ឃុំទួលគ្រើល** ៖ គម្រោងកែលម្អផ្លូវលំក្រាលក្រួសក្រហម<br>**ស្រុកៈ** ប្រាសាទបល្ល័ង្គ | • គម្រោងកែលម្អផ្លូវលំក្រាលក្រួសក្រហម នៅសល់ ៣៧០ម<br>• មានដក់ទឹកសងខាងផ្លូវ ហើយថ្មីៗនេះអ្នកទទួលការចូលអនុវត្ត តែមិនអាចធ្វើបាន | ខែមករា ឆ្នាំ ២០១៨ |
| ១០ | **ឃុំសំបូរ** ៖ គម្រោងកែលម្អផ្លូវលំក្រាលក្រួសក្រហម<br>**ស្រុកៈ** ប្រាសាទសំបូរ | • ផ្លូវដែលត្រូវកែលម្អ មានដក់ទឹកសងខាងផ្លូវ | ខែកុម្ភៈ ឆ្នាំ ២០១៨ |
| ១១ | **ឃុំ ស្រើងៈ** គម្រោងកែលម្អផ្លូវលំក្រាលក្រួសក្រហម និងលូជ្រុង<br>**ស្រុកៈ** ប្រាសាទសំបូរ | • ពេលសាងសង់មានភ្លៀងធ្លាក់ អ្នកទទួលការបានផ្អាកអនុវត្តសិន<br>• ទីតាំងសាងសង់លូមិនអាចដឹកសម្ភារចូលបាន | ខែកុម្ភៈ ឆ្នាំ ២០១៨ |
| ១២ | **ឃុំ តាំងក្រសៅ** ៖ គម្រោងកែលម្អផ្លូវលំក្រាលក្រួសក្រហម<br>**ស្រុកៈ** ប្រាសាទសំបូរ | • ផ្លូវដែលត្រូវកែលម្អ មានដក់ទឹកសងខាង | ខែកុម្ភៈ ឆ្នាំ ២០១៨ |
| ១៣ | **ឃុំបឹងល្វាៈ** គម្រោងសាងសង់ផ្លូវលំក្រាលក្រួសក្រហម<br>**ស្រុកៈ** សន្ទុក | • ទីតាំងយកក្រួសនៅចុងផ្លូវមានអូរ ពិបាកឆ្លងកាត់ដឹកក្រួស បច្ចុប្បន្នអាចចូលបាន | ខែមករា ឆ្នាំ ២០១៨ |
| ១៤ | **ឃុំជ្រាប់ៈ** គម្រោងសាងសង់ឡាយ និងលូកាត់ប្រឡាយ<br>**ស្រុកៈ** សន្ទុក | • ប្រឡាយបានសាងសង់រួច១០០% ។ នៅសល់លូ១កន្លែងទីតាំងនៅផ្សេងមិនអាចដឹកសម្ភារចូលដល់នៅដក់ទឹក | ខែកុម្ភៈ ឆ្នាំ ២០១៨ |
| ១៥ | **ឃុំកកោះៈ** គម្រោងសាងសង់ផ្លូវលំក្រាលក្រួសក្រហម និង លូ៩កន្លែង<br>**ស្រុកៈ** សន្ទុក | • នៅមិនទាន់សាងសង់លូ០៩កន្លែង<br>• ទីតាំងអាចចូលបានក្នុងខែធ្នូនេះ | ខែមករា ឆ្នាំ ២០១៨ |
| ១៦ | **ឃុំតាំងក្រសាំងៈ** គម្រោងសាងសង់ផ្លូវលំក្រាលក្រួសក្រហម **ស្រុកៈ** សន្ទុក | • ទីតាំងផ្លូវដោយកន្លែងមានទឹក<br>• បច្ចុប្បន្នអាចចូលបាន | ខែមករា ឆ្នាំ ២០១៨ |
| ១៧ | **ឃុំបន្ទាយស្ទោង** ៖ គម្រោងសាងសង់ផ្លូវលំក្រាលក្រួសក្រហម និងលូ<br>**ស្រុកៈ** ស្ទោង | • មានដក់ទឹកសងខាងផ្លូវ និងមិនអាចអនុវត្តបាន | ខែមករា ឆ្នាំ ២០១៨ |

| | | | |
|---|---|---|---|
| ១៨ | **ឃុំព្រះដំរី** ៖ គម្រោងសាងសង់ផ្លូវលំក្រាលក្រួសក្រហម និងលូ<br>**ស្រុក៖** ស្ទោង | • ក្រុមហ៊ុនបានចូលអនុវត្តច្រើនដង ពេលចូលមានភ្លៀងធ្លាក់ ដក់ទឹកសងខាងផ្លូវ និងមិនអាចអនុវត្តបាន<br>• បច្ចុប្បន្ន អាចចូលបាន | ខែមករា ឆ្នាំ ២០១៨ |
| ១៩ | **ឃុំរុងរឿង** ៖ គម្រោងសាងសង់ផ្លូវលំក្រាលក្រួសក្រហម និង លូ<br>**ស្រុក៖** ស្ទោង | • ក្រុមហ៊ុនបានចូលអនុវត្តច្រើនដង ពេលចូលមានភ្លៀងធ្លាក់ ដក់ទឹកសងខាងផ្លូវ និង<br>• មិនអាចអនុវត្តបាន<br>• ខែធ្នូនេះអាចចូលបាន | ខែមករា ឆ្នាំ ២០១៨ |
| **០៧. ខេត្ត កំពត** មានចំនួន ០៣ គម្រោង | | | |
| ១ | **ឃុំស្វាយទងខាងត្បូង** ៖ ផ្លូវក្រួសក្រហមប្រវែង០,៨គ.ម ទទឹង៤ម និងសំណង់លូ ០១ កន្លែង<br>**ស្រុក៖ កំពង់ត្រាច** | • ទីតាំងគម្រោងកាត់បឹង មានទឹក ដីផុង គ្រឿងចក្រមិនអាចចូលការដ្ឋានបាន<br>• ទឹកច្រើនជីកដីធ្វើគ្រឹះមិនទាន់បាន | អាចបញ្ចប់នៅចុងខែ ធ្នូ ឆ្នាំ ២០១៧ |
| ២ | **ឃុំ នរាយណ៍** ៖ ផ្លូវដីប្រវែង ១.៩០គម ទទឹង៤,៥ម និងសំណង់លូមូល២កន្លែង<br>**ស្រុក៖ ឈូក** | • ទីតាំងខាងចុងកាត់ដីស្រែប្រជាជន រង់ចាំការច្រូតកាត់ចប់សព្វគ្រប់<br>• ទឹកច្រើនជីកដីធ្វើគ្រឹះមិនទាន់បាន | អាចបញ្ចប់នៅចុងខែ មករា ឆ្នាំ ២០១៨ |
| ៣ | **ឃុំ នរាយណ៍** ៖ ស្រះសហគមន៍ទំហំ១០០x៣៥x៣ម<br>**ស្រុក៖ ឈូក** | • ទីតាំងគម្រោងមានទឹកដក់ច្រើនមិនអាចចូលអនុវត្តបាន | អាចបញ្ចប់នៅចុងខែ មេសា ឆ្នាំ ២០១៨ |
| **០៨. ខេត្តកណ្ដាល** មានចំនួន ៦ គម្រោង | | | |
| ១ | **ឃុំ ជើងកើប៖** ជួសជុលផ្លូវដី<br>**ស្រុក៖** កណ្ដាលស្ទឹង | • គម្រោងទើបអនុវត្តបាន ១៥% ហើយបានដាក់ពាក្យពន្យាររការអនុវត្ត ដោយសារគម្រោងអនុវត្តកាត់ស្រែរបស់ប្រជាពលរដ្ឋ និងម៉្យាងទៀតទីតាំងគម្រោង និងទីតាំងយកដីត្រូវលិចទឹក (ស្ថិតជាប់មាត់ស្ទឹង) | ខែកុម្ភៈ ឆ្នាំ២០១៨ ក្រោយពេលប្រជាពលរដ្ឋប្រមូលផលស្រូវរួច |
| ២ | **ឃុំ បាក់ដាវ** ៖ គម្រោងជួសជុលផ្លូវដី<br>**ស្រុក៖** ខ្សាច់កណ្ដាល | • គម្រោងអនុវត្តបាន៥០% ហើយ អ្នកទទួលការបានដាក់ពាក្យពន្យារការអនុវត្តដោយសារគម្រោងមិនមានអាចដីចាក់បំពេញបន្ថែម ព្រោះទឹកលិចទីតាំងយកអាចម៍ដីចាក់បំពេញតួផ្លូវ | ខែកុម្ភៈ ឆ្នាំ២០១៨ ក្រោយពេលទឹកស្រក គ្រឿងចក្រអាចចូលយកអាចម៍ដីបាន |
| ៣ | **ឃុំ ព្រែករៃ** ៖ គម្រោងជួសជុលផ្លូវដី<br>**ស្រុក៖** ល្វាឯម | • គម្រោងអនុវត្តបាន៦០% ហើយអ្នកទទួលការបានដាក់ពាក្យពន្យារការអនុវត្ត ដោយសារគម្រោងមិនមានអាចម៍ដីចាក់បំពេញបន្ថែម ព្រោះទឹកលិចទីតាំងយកអាចម៍ដីចាក់បំពេញតួផ្លូវ | |
| ៤ | **ឃុំ សំបួរ** ៖ ស្ពារប្រឡាយដី<br>**ស្រុក៖** ល្វាឯម | • គម្រោងទើបអនុវត្តបាន១៥% ហើយ អ្នកទទួលការបានដាក់ពាក្យពន្យារការអនុវត្តដោយសារទីតាំងគម្រោងលិចទឹក (ទីតាំងគម្រោងស្ថិតក្នុងកណ្ដាល | ខែមីនា ឆ្នាំ២០១៨ ក្រោយពេលទឹកស្រក គ្រឿងចក្រ |

| | | | |
|---|---|---|---|
| | | អាងទឹក) គ្រឿងចក្រមិនអាចចូលដល់ទីតាំងគម្រោងបាន | អាចចូលយកអាចម៍ដីបាន |
| ៥ | **ឃុំទួលព្រេច** ៖ គម្រោងជួសជុលផ្លូវក្រាលក្រួសក្រហម **ស្រុក៖** អង្គស្នួល | • គម្រោងអនុវត្តបាន៥០% ការអនុវត្តយឺតយ៉ាវនេះបណ្តាលមកពីក្រុមហ៊ុន (សំ ស៊ីវន ខនស្រ្តាក់សិន ខូ អិលធីឌី ចុះឈ្មោះនៅរាជធានីភ្នំពេញ) មានការងារច្រើន ហើយម្ចាស់គម្រោង បានអញ្ជើញច្រើនដង ហើយតែមិនចូលមកអនុវត្ត បច្ចុប្បន្ននេះក្រុមប្រឹក្សាឃុំកំពុងពិចារណាលប់កិច្ចសន្យានេះចោល | នឹងលប់កិច្ចសន្យា |
| ៦ | **ឃុំប្រាសាទ** ៖ គម្រោងជួសជុលផ្លូវដី **ស្រុក៖** ស្អាង | • គម្រោងទើបអនុវត្តបាន៥០% ហើយបានដាក់ពាក្យពន្យារការអនុវត្តដោយសារទីតាំងគម្រោងលិចទឹក (ទីតាំងគម្រោងស្ថិតក្នុងតំបន់ទំនាប) និងមិនមានអាចម៍ដីចាក់បំពេញបន្ថែម ព្រោះទឹកលិចទីតាំងយកអាចម៍ដីចាក់បំពេញតួផ្លូវ ថែមទាំងគ្រឿងចក្រមិនអាចចូលដល់ទីតាំងគម្រោងបានផងដែរ។ | សប្តាហ៍ទី៤ ខែមីនា ២០១៨ ក្រោយពេលទឹកស្រក |
| **០៩. ខេត្ត កោះកុង** មានចំនួន ០៣ គម្រោង | | | |
| ១ | **ឃុំ ព្រែកខ្សាច់** ៖ គម្រោងផ្លូវក្រាលក្រួសក្រហម និងសំណង់លូកាត់ផ្លូវ **ស្រុក៖** គីរីសាគរ | • មានភ្លៀងធ្លាក់ខ្លាំង<br>• ស្ថានភាពផ្លូវចូលទៅកាន់ទីតាំងគម្រោងមានការលំបាកមិនអាចចូលអនុវត្តបាន (ផ្លូវឡើងចុះភ្នំ និងជ្រោះ) | បញ្ចប់នៅ ៣០/០១/២០១៨ |
| ២ | **ឃុំ ជំនាប់** ៖ គម្រោងផ្លូវក្រាលក្រួសក្រហម **ស្រុក៖** ថ្មបាំង | | ១៥/០២/២០១៨ |
| ៣ | **ឃុំ ថ្មដូនពៅ** ៖ គម្រោងផ្លូវក្រាលក្រួសក្រហម **ស្រុក៖** ថ្មបាំង | | ១៥/០២/២០១៨ |
| **១១. ខេត្តមណ្ឌលគិរី** មានចំនួន០៣គម្រោង | | | |
| ១ | **ឃុំ ស្រែព្រះ** ៖ គម្រោង ជួសជុលផ្លូវលំដីស **ស្រុក៖** កែវសីមា | • បានពន្យារពេលកិច្ចសន្យាដោយកត្តាអាកាសធាតុ<br>• ផ្លូវចូលគ្រឿងចក្រមិនអាចចូលរួចនិង<br>• រណ្តៅដី ឬក្រួសលិចទឹក | ចុងខែធ្នូ ឆ្នាំ ២០១៧ |
| ២ | **ឃុំស្រែឈូក** ៖ គម្រោងជួសជុលផ្លូវលំដីស និងដាក់លូ **ស្រុក៖** កែវសីមា | | |
| ៣ | **សង្កាត់ សុខដុម** ៖ ជួសជុលផ្លូវលំក្រាលក្រួសក្រហម **ក្រុង៖** សែនមនោរម្យ | | |
| **១៣. ខេត្តព្រះវិហារ** មានចំនួន១៩គម្រោង | | | |
| ១ | **ឃុំពុទ្រា** ៖ គម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហម | • អនុវត្តបានតិចជាង៥០%<br>• ដេញបានគម្រោងច្រើន ដេញចុះខ្លាំង គម្រោងដេញ | • ទីចាត់ការផែនការ និងវិនិ |

| | | | |
|---|---|---|---|
| | **ស្រុក៖ ជ័យសែន** | ចុងឆ្នាំ២០១៦ អនុវត្តក្នុងឆ្នាំ២០១៧ និងក្នុងឆ្នាំ ២០១៧ ភ្លៀងធ្លាក់ច្រើនហើយអូសបន្លាយយូរស្ទើរតែពេញមួយឆ្នាំ | យោគខេត្តដាក់កំណត់ថានឹងត្រូវបញ្ចប់ទាំងអស់ ត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ជាកំហិត |
| ២ | **ឃុំធ្មា** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ ជ័យសែន** | • អនុវត្តបានច្រើនជាង៥០%<br>• ដេញបានគម្រោងច្រើន ដេញចុះខ្លាំង គម្រោងដេញចុងឆ្នាំ២០១៦ អនុវត្តក្នុងឆ្នាំ២០១៧ និងក្នុងឆ្នាំ ២០១៧ ភ្លៀងធ្លាក់ច្រើនហើយអូសបន្លាយយូរសឹងពេញមួយឆ្នាំ<br>• ទីតាំងគម្រោងឆ្ងាយ ពិបាកចេញចូលទាំងរដូវប្រាំង និងវស្សា | |
| ៣ | **ឃុំសង្កែ២** ៖ គម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ ឆែប** | • មិនទាន់បានអនុវត្ត<br>• ដេញបានគម្រោងច្រើន ដេញចុះខ្លាំង គម្រោងដេញចុងឆ្នាំ២០១៦ អនុវត្តក្នុងឆ្នាំ២០១៧<br>• ក្នុងឆ្នាំ២០១៧ភ្លៀងធ្លាក់ច្រើនហើយអូសបន្លាយយូរសឹងពេញមួយឆ្នាំ<br>• ទីតាំងគម្រោងនៅឆ្ងាយពិបាកចេញចូលទាំងរដូវប្រាំង និងវស្សា | • ទីចាត់ការបានកំណត់ពេលឱ្យត្រឹមថ្ងៃទី២៩ខែធ្នូ ឆ្នាំ២០១៧ បើមិនចូលអនុវត្ត និងត្រូវលប់គម្រោងចោល |
| ៤ | **ឃុំម្លូព្រៃ២** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ ឆែប** | • អនុវត្តបានតិចជាង៥០%<br>• ដេញបានគម្រោងច្រើន ដេញចុះខ្លាំង គម្រោងដេញចុងឆ្នាំ២០១៦ អនុវត្តក្នុងឆ្នាំ២០១៧ និងក្នុងឆ្នាំ ២០១៧ភ្លៀងធ្លាក់ច្រើនហើយអូសបន្លាយយូរសឹងពេញមួយឆ្នាំ<br>• ទីតាំងគម្រោងស្ថិតនៅឆ្ងាយ ពិបាកចេញចូលទាំងរដូវប្រាំង និងវស្សា | • ទីចាត់ការផែនការ និងវិនិយោគខេត្តដាក់កំណត់ថានឹងត្រូវបញ្ចប់ទាំងអស់ ត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ជាកំហិត |
| ៥ | **ឃុំគូលែនជើង** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ គូលែន** | | |
| ៦ | **ឃុំគូលែនត្បូង០១** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ គូលែន** | | |
| ៧ | **ឃុំ គូលែនត្បូង០២** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ គូលែន** | | |
| ៨ | **ឃុំ ថ្មី** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖គូលែន** | | |
| ៩ | **ឃុំភ្នំត្បែងពីរ** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ គូលែន** | | |
| ១០ | **ឃុំព្រីងធំ** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ ជាំក្សាន្ត** | | |

| | | | |
|---|---|---|---|
| ១១ | **ឃុំ រួសរាន់** ៖ គម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ រវៀង** | • អនុវត្តបានតិចជាង៥០%<br>• ដេញបានគម្រោងច្រើន ដេញចុះខ្លាំង គម្រោងដេញចុងឆ្នាំ២០១៦ អនុវត្តក្នុងឆ្នាំ២០១៧ និងក្នុងឆ្នាំ២០១៧ភ្លៀងធ្លាក់ច្រើនហើយអូសបន្លាយយូរសឹងពេញមួយឆ្នាំ<br>• ទីតាំងគម្រោងស្ថិតនៅឆ្ងាយ ពិបាកចេញចូលទាំងរដូវប្រាំង និងវស្សា | ទីចាត់ការផែនការ និងវិនិយោគខេត្ត ដាក់កំណត់ថានឹងត្រូវបញ្ចប់ទាំងអស់ត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ជាកំហិត។ |
| ១២ | **ឃុំរហ័ស** ៖ សាងសង់ស្ពានឈើក្បាលបេតុង<br>**ស្រុក៖ រវៀង** | | |
| ១៣ | **ឃុំរៀបរយ** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ រវៀង** | | |
| ១៤ | **ឃុំស្តៅ** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ សង្គមថ្មី** | | |
| ១៥ | **ឃុំរអាង** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ សង្គមថ្មី** | | |
| ១៦ | **ឃុំចំរើន** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖សង្គមថ្មី** | | |
| ១៧ | **ឃុំប្រមេរ** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ ត្បែងមានជ័យ** | | |
| ១៨ | **ឃុំ ឃ្លាំង** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ត្បែងមានជ័យ** | | |
| ១៩ | **ឃុំឈានមុខ** ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម<br>**ស្រុក៖ ត្បែងមានជ័យ** | | |
| **១៤. ខេត្ត ព្រៃវែង** មានចំនួន ០៤ គម្រោង | | | |
| ១ | **ឃុំ ព្រែកតាសរ** ៖ ជួសជុលទំនប់ដី និងលូទ្វារទឹក<br>**ស្រុក៖ ពោធិ៍រៀង** | • ទឹកលិចទីតាំងយកដីសម្រាប់ការងារសាងសង់ និងនៅឆ្នាំ២០១៧ មានភ្លៀងធ្លាក់បន្តបន្ទាប់ | គ្រោងបញ្ចប់នៅដើមឆ្នាំ២០១៨ |
| ២ | **ឃុំកំពង់ពពិល** ៖ ជួសជុលផ្លូវដីស<br>**ស្រុក៖** ពារាំង | • ទឹកលិចទីតាំងយកដីសម្រាប់ការងារសាងសង់ និងនៅឆ្នាំ២០១៧ មានភ្លៀងធ្លាក់បន្តបន្ទាប់ | គ្រោងបញ្ចប់នៅដើមឆ្នាំ២០១៨ |
| ៣ | **ឃុំរាប** ៖ ជួសជុលផ្លូវដីសនិងក្រាលក្រួសក្រហម<br>**ស្រុក៖**ពារាំង | • អ្នកទទួលការអនុវត្តការងារមានការយឺតយ៉ាវ រវល់ជាមួយគម្រោងផ្សេងៗ | គ្រោងបញ្ចប់នៅដើមឆ្នាំ២០១៨ |
| ៤ | **ឃុំ ស្តៅកោង** ៖ ជួសជុលផ្លូវ | • ទឹកលិចទីតាំងយកដីសម្រាប់ការងារសាងសង់ និង | គ្រោងបញ្ចប់នៅ |

| | | | |
|---|---|---|---|
| | ដីសនិងក្រាលខ្សាច់ភ្នំ<br>ស្រុក៖ បាភ្នំ | នៅឆ្នាំ២០១៧ មានភ្លៀងធ្លាក់បន្តបន្ទាប់ | ដើមឆ្នាំ២០១៨ |
| **១៥. ខេត្តពោធិ៍សាត់** មានចំនួន ៣ គម្រោង | | | |
| ១ | **ឃុំ រាំងទិល៖** ផ្លូវក្រួសក្រហម<br>**ស្រុក៖កណ្ដៀង** | • ទឹកលិចផ្លូវសម្រាប់ដឹកក្រួសចូលការដ្ឋាន | គ្រោងបញ្ចប់នៅ<br>ខែមីនាឆ្នាំ២០១៨ |
| ២ | **ឃុំ ស្វាយដូនកែវ៖** ផ្លូវក្រួសក្រហម<br>**ស្រុក៖បាកាន** | | គ្រោងបញ្ចប់នៅ<br>ខែមីនាឆ្នាំ២០១៨ |
| ៣ | **ឃុំ ក្បាលត្រាច៖** ផ្លូវក្រួសក្រហម<br>**ស្រុក៖ក្រគរ** | | គ្រោងបញ្ចប់នៅ<br>ខែមីនាឆ្នាំ២០១៨ |
| **១៦. ខេត្តរតគិរី** មានចំនួន៥គម្រោង | | | |
| ១ | **ឃុំ សិរីមង្គល** ៖ ជួសជុលផ្លូវក្រួសក្រហម<br>**ស្រុក៖** កូនមុំ | • អ្នកទទួលការមិនព្រមចូលអនុវត្ត ដោយហេតុផលផ្ទាល់ខ្លួន។ បន្ទាប់ពីទីចាត់ការបានព្រមានអ្នកទទួលការបានសន្យានឹងបញ្ចប់ក្នុងខែធ្នូ ២០១៧ | ខែធ្នូ ២០១៧<br>ក្រុមហ៊ុន រតនពិសិដ្ឋ |
| ២ | **ឃុំ កាឡែង** ៖ សាងសង់ស្ពានឈើក្បាលបេតុង<br>**ស្រុក៖** លំផាត់ | • អ្នកទទួលការមិនព្រមចូលអនុវត្ត ដោយហេតុផលផ្ទាល់ខ្លួន។ ទីចាត់ការបានធ្វើការព្រមានពីរដងរួចហើយ | ខែមេសា ២០១៨<br>ក្រុមហ៊ុន ស៊ុន ចាន់តារា |
| ៣ | **ឃុំ ល្បាំង២** ៖ សាងសង់ផ្លូវក្រួសក្រហមនិងលូ<br>**ស្រុក៖** លំផាត់ | • ដោយសារការរង់ចាំឱ្យប្រជាពលរដ្ឋប្រមូលផលដំណាំសិន | ខែកុម្ភៈ ២០១៨<br>ក្រុមហ៊ុន ស៊ុន ចាន់តារា |
| ៤ | **ឃុំ សោមធំ** ៖ សាងសង់ផ្លូវក្រួសក្រហមនិងលូ<br>**ស្រុក៖** អូរយ៉ាដាវ | • ដោយសារហេតុផលផ្ទាល់ខ្លួនរបស់អ្នកទទួលការហើយអ្នកទទួលការសុំពន្យារ និងព្រមឱ្យឃុំផាកពិន័យ | ខែមករា ២០១៨<br>ក្រុមហ៊ុនស៊ានខាំរិន |
| ៥ | **ឃុំតាវែងក្រោម** ៖ ជួសជុលផ្លូវក្រួសក្រហម និងលូ<br>**ស្រុក៖** តាវែង | • ដោយសារស្ថានភាពភូមិសាស្ត្រមិនអំណោយផលមានអូរច្រើន ទឹកជ្រៅ ពិបាកឆ្លងគ្រឿងចក្រ | ខែមករា ២០១៨<br>ក្រុមហ៊ុន វ៉ាន់ សុធី |
| **១៧. ខេត្តសៀមរាប** មានចំនួន ០៣ គម្រោង | | | |
| ១ | **ឃុំស្នួល** ៖ ជួសជុលផ្លូវដីសក្រាលក្រួសភ្នំ<br>**ស្រុក៖** ក្រឡាញ់ | • ទីតាំងគម្រោងនៅមានទឹក និងប្រជាកសិករមិនទាន់ប្រមូលផលស្រូវអស់ពីស្រែ អ្នកទទួលការមិនមានលទ្ធភាពដឹកយកដីសបាន | គ្រោងបញ្ចប់នៅ<br>២៩-១២-២០១៧ |
| ២ | **ឃុំ ត្រីញ័រ** ៖ ជួសជុលផ្លូវដីសទទឹង៥ម៉ែត្រ ប្រវែង៩៥០ម៉ែត្រ និងលូកាត់ផ្លូវចំនួន៣កន្លែង<br>**ស្រុក៖** ពួក | • ទីតាំងគម្រោងនៅមានទឹក និងប្រជាកសិករមិនទាន់ប្រមូលផលស្រូវអស់ពីស្រែ អ្នកទទួលការមិនមានលទ្ធភាពដឹកយកដីសបំពេញគ្រឹះផ្លូវបាន | គ្រោងបញ្ចប់នៅ<br>១៥-០២-២០១៨ |
| ៣ | **ឃុំ ស្រែណូយ** ៖ សាងសង់ផ្លូវដីស ប្រវែង១៥០០ម៉ែត្រ | • ទីតាំងគម្រោងនៅមានទឹក អ្នកទទួលការមិនមានលទ្ធភាពដឹកយកដីសបាន | គ្រោងបញ្ចប់នៅ<br>១០-០១-២០១៨ |

| | | | |
|---|---|---|---|
| | និងលូមូលមុខកាត់១ម មួយកន្លែង ស្រុក៖ វ៉ារិន | | |
| **២២. ខេត្ត ឧត្តរមានជ័យ** មានចំនួន ៨គម្រោង | | | |
| ១ | **ឃុំ លំទង៖** សាងសង់ផ្លូវដីក្រាលក្រួសក្រហមនិងលូ៣កន្លែង<br>**ស្រុក៖** អន្លង់វែង | • ដេញថ្លៃបរាជ័យ២ដង និងប្រកាសដេញថ្លៃយឺតយ៉ាវទើបចុះកិច្ចសន្យាក្នុងឆ្នាំ២០១៧ | ១៩ ខែកុម្ភៈ ២០១៨<br>អ្នកទទួលការ ៖ ញ៉ែម សន (ឧ.ជ) |
| ២ | **ឃុំ ពង្រ៖** កែលម្អផ្លូវដីក្រាលក្រួសក្រហមប្រវែង ១១០៥មលូ៣កន្លែង<br>**ស្រុក៖** ចុងកាល់ | • ទើបបាន៥០%<br>• ពេលដេញថ្លៃនិងចុះកិច្ចសន្យារួចស្ថិតក្នុងខែ វស្សាដីសើម ជាំទឹកមិនអាចធ្វើបាន។<br>• អ្នកទទួលការមានការងារច្រើន មិនមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់អនុវត្ត | បញ្ចប់នៅថ្ងៃទី ២៥ ធ្នូ ២០១៧<br>អ្នកទទួលការ ៖ ថេង រីតា (ព្រ.វិ) |
| ៣ | **សង្កាត់ បុស្សស្បូវ៖** កែលម្អផ្លូវដីក្រាលក្រួសក្រហម ប្រវែង ២៤៥០មលូ១កន្លែង<br>**ក្រុង៖**សំរោង | • ទើបបាន៥០%<br>• ដេញថ្លៃ និងចុះកិច្ចសន្យាក្នុងឆ្នាំ២០១៧<br>• អ្នកទទួលការមានការងារច្រើន មិនមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់អនុវត្ត<br>• ទីតាំងក្រួសក្រហមសើមជាំទឹកចូលដឹកមិនបាន | ពន្យារពេលគ្មានឯកសារអ្នកទទួលការ៖ ស៊ីអឹម (ឧ.ជ) |
| ៤ | **សង្កាត់ កូនក្រៀល៖** កែលម្អផ្លូវដី ក្រាលក្រួសក្រហម ប្រវែង៣.១៨៦ម លូ៦កន្លែង<br>**ក្រុង៖** សំរោង | • ដេញថ្លៃ និងចុះកិច្ចសន្យាក្នុងឆ្នាំ២០១៧<br>• អ្នកទទួលការមានការងារច្រើន មិនមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់អនុវត្ត<br>• ពន្យារពេលអនុវត្តគ្មានឯកសារ | ០១ ធ្នូ ២០១៧<br>អ្នកទទួលកា ៖ ថេង រីតា (ព្រ.វិ) |
| ៥ | **សង្កាត់សំរោង៖** សាងសង់ផ្លូវក្រាលក្រួសក្រហម ប្រវែង ៤.១៤០ម និងលូ៨កន្លែង<br>**ក្រុង៖** សំរោង | • ទើបបាន៥០%<br>• ដេញថ្លៃ និងចុះកិច្ចសន្យាក្នុងឆ្នាំ២០១៧<br>• អ្នកទទួលការមានការងារច្រើន មិនមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់អនុវត្ត<br>• ពន្យារពេលអនុវត្តមិនមានឯកសារ | អ្នកទទួលការ ៖ ស៊ី អឹម (ឧ.ជ) |
| ៦ | **ឃុំផ្អាវ៖** កែលម្អផ្លូវដីក្រាលក្រួសក្រហមប្រវែង៣.៣០០ ម៉ែត្រ និងលូ២កន្លែង<br>**ស្រុក៖** ត្រពាំងប្រាសាទ | • ការអនុវត្តគម្រោងឆ្លងកាត់រដូវវស្សា<br>• ទីតាំងក្រួសក្រហមមិនអាចចូលយកបាន<br>• អ្នកទទួកលការមានគ្រឿងចក្រមិនគ្រប់គ្រាន់ និងកិច្ចសន្យាច្រើន<br>• ពន្យារពេលមិនមានឯកសារ | អ្នកទទួលការ ៖ ហាក់ គឹមហុង (ព្រ.វិ) |
| ៧ | **ឃុំអូស្វាយ៖** កែលម្អផ្លូវដីក្រាលក្រួសក្រហមប្រវែង ៣.៥២០ម និងលូ២កន្លែង<br>**ស្រុក៖** ត្រពាំងប្រាសាទ | • អ្នកទទួលការមានគ្រឿងចក្រមិនគ្រប់គ្រាន់ និងកិច្ចសន្យាច្រើន<br>• ពន្យារពេលមិនមានឯកសារ | អ្នកទទួលការ៖ ថេង រីតា (ព្រ.វិ) |
| ៨ | **ឃុំទំនប់ដាច់៖** កែលម្អផ្លូវដីក្រាលក្រួសក្រហមប្រវែង | • ការអនុវត្តគម្រោងឆ្លងកាត់រដូវវស្សា<br>• ទីតាំងក្រួសក្រហមមិនអាចចូលយកបាន | អ្នកទទួលការ ៖ |

| | | | |
|---|---|---|---|
| | ២.១២០ម និងលូ៣កន្លែង<br>**ស្រុក៖** ត្រពាំងប្រាសាទ | • ពន្យារពេលអនុវត្ត មិនមានឯកសារ | ហាក់ គឹមហុង (ព្រ.វិ) |
| **២៥. ខេត្តត្បូងឃ្មុំ** មានចំនួន ០៦ គម្រោង | | | |
| ១ | **ឃុំជាំតាម៉ៅ** ៖ សាងសង់លូជ្រុងមុខបី និងមានទ្វារទឹក (មិនទាន់បានអនុវត្ត)<br>**ស្រុក៖** មេមត់ | • ដឹកសម្ភារ និងគ្រឿងចក្រចូលទីតាំងគម្រោងមិនរួចដោយសារស្រូវប្រាំងរបស់ប្រជាពលរដ្ឋមិនទាន់ច្រូត<br>• បន្ទាប់មកមានជំនន់ទឹកភ្លៀងជាប់ៗគ្នាធ្វើឱ្យមានដក់ទឹកក្នុងប្រឡាយដែលត្រូវសាងសង់លូជ្រុងមិនអាចអនុវត្តបាន | គ្រោងបញ្ចប់នៅដំណាច់ខែមករា ឆ្នាំ២០១៨ |
| ២ | **ឃុំជាំតាម៉ៅ** ៖ ស្ពានប្រឡាយ (មិនទាន់បានអនុវត្ត)<br>**ស្រុក៖** មេមត់ | • ដឹកសម្ភារ និងគ្រឿងចក្រចូលទីតាំងគម្រោងមិនរួចដោយស្រូវប្រាំងរបស់ប្រជាពលរដ្ឋមិនទាន់ច្រូត<br>• បន្ទាប់មកមានជំនន់ទឹកភ្លៀងជាប់ៗគ្នា ធ្វើឱ្យប្រឡាយទឹកដែលត្រូវសាងសង់មានទឹកពេញមិនអាចអនុវត្តបាន | គ្រោងបញ្ចប់នៅដំណាច់ខែមករា ឆ្នាំ២០១៨ |
| ៣ | **ឃុំកោះពីរ៖** សាងសង់ផ្លូវដី (មិនទាន់បានអនុវត្ត)<br>**ស្រុក៖** ក្រូចឆ្មារ | • អ្នកទទួលការមានតែគ្រឿងចក្រធុនធំមិនអាចដឹកឆ្លងទូកដរទៅទីតាំងគម្រោងនៅលើកោះបាន<br>• ពេលជួលគ្រឿងចក្រធុនតូចបានទីតាំងគម្រោងត្រូវលិចទឹកទន្លេអស់<br>• រហូតមកដល់ខែធ្នូ ឆ្នាំ២០១៧នេះទីតាំងយកដីមិនទាន់អស់ទឹក និងដីនៅសើមខ្លាំង | គ្រោងបញ្ចប់នៅដំណាច់ខែកុម្ភៈ ឆ្នាំ ២០១៨ |
| ៤ | **ឃុំត្រពាំងផ្លុង៖** សាងសង់ផ្លូវដី (មិនទាន់បានអនុវត្តបន្ត)<br>**ស្រុក៖** ពញាក្រែក | • អនុវត្តបាន៥០% សុំពន្យារមួយរយៈធំ ដោយមានភ្លៀងច្រើនពេកមិនអាចអនុវត្តបន្តបាន តែពេលនេះទីតាំងគម្រោងអស់ទឹកអាចអនុវត្តបានហើយតែអ្នកទទួលការនៅតែមិនទាន់ចាប់ផ្តើមអនុវត្ត | គ្រោងបញ្ចប់នៅដំណាច់ខែធ្នូ ឆ្នាំ ២០១៧ |
| ៥ | **ឃុំអញ្ជើម៖** សាងសង់ផ្លូវដី (មិនទាន់បានអនុវត្តបន្ត)<br>**ស្រុក៖** ត្បូងឃ្មុំ | • អនុវត្តបាន៥០% សុំពន្យារមួយរយៈធំ ដោយមានភ្លៀងច្រើនពេកមិនអាចអនុវត្តបន្តបាន តែពេលនេះទីតាំងគម្រោងអស់ទឹកអាចអនុវត្តបានហើយតែអ្នកទទួលការនៅតែមិនទាន់ចាប់ផ្តើមបន្ត | គ្រោងបញ្ចប់នៅដំណាច់ខែធ្នូ ឆ្នាំ ២០១៧ |
| ៦ | **ឃុំទ្រា៖** សាងសង់ផ្លូវក្រួសក្រហម (មិនទាន់អនុវត្តបន្ត)<br>**ស្រុក៖** ក្រូចឆ្មារ | • អនុវត្តបាន៣០% សុំពន្យារពេល ដោយមានភ្លៀងច្រើនពេកលិចទីតាំងគម្រោង និងរណ្តៅយកក្រួសក្រហម | គ្រោងបញ្ចប់នៅដំណាច់ខែធ្នូ ឆ្នាំ ២០១៧ |

☞ គម្រោងដែលអ្នកទទួលការបោះបង់ ឬម្ចាស់គម្រោងលប់ចោលកិច្ចសន្យាមាន៧កិច្ចសន្យា (BAT=1 KCH=1 KAM=1 KRT=3 RAT=1)

### ៣.២.៣. គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧

#### ៣.២.៣.១. ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧

ការរៀបចំសំណុំឯកសារសំណើគម្រោងមូលនិធិឃុំ សង្កាត់ក្នុងឆ្នាំ២០១៧មានល្បឿនប្រហាក់ប្រហែលឆ្នាំ២០១៦ បើធៀបនឹងរយៈពេលដូចគ្នា (យឺតជាង២០១៦ ចំនួន១%ប៉ុណ្ណោះ)។ ក្នុងការរៀបចំសំណុំឯកសារនេះដោយមានការគាំទ្រពីមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ រួមជាមួយទីប្រឹក្សាបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីចាត់ការផែនការ និងវិនិយោគខេត្តនីមួយៗ សម្រេចបានលទ្ធផលដូចខាងក្រោម៖

| ការបរិយាយ | ចំនួនគម្រោង | គិតជា% | ផ្សេងៗ |
|---|---|---|---|
| បានចុះកិច្ចសន្យា | ១.៥៤៥ | ៨៨% | គម្រោងដែលលើកឡើងសរុបមាន១.៧៥៤គម្រោង កំពង់ដំណើរការសិក្សាបញ្ចប់២៧ គម្រោង នៅ KPC=4 KPT=8 KAM=5 SRP=1 STG=3 OMC=4 and KEP=2 និងមាន៩គម្រោងបានលើកទៅអនុវត្តឆ្នាំ ២០១៨ (KDL=2 MKR=2 TAK=3 and RAT=2) |
| បានបញ្ចប់ការសិក្សា | ១៧៣ | ៩% | |
| កំពង់ដំណើរការសិក្សា | ២៧ | ២% | |
| លើកទៅធ្វើឆ្នាំ២០១៨ | ៩ | ១% | |

ក្រាហ្វិកខាងក្រោមបង្ហាញពីវឌ្ឍនភាពនៃការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ តាមរាជធានី ខេត្ត៖

**វឌ្ឍនភាពនៃការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧**

| លេខកូដរាជធានី ខេត្ត | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | ផ្ទៀងផ្ទាត់ | គិតជា | ចំនួន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះកាត់រាជធានី ខេត្ត | BMC | BAT | KPC | KCH | KSP | KPT | KAM | KDL | KKG | KRT | MKR | PNP | PVR | PVG | PUR | RAT | SRP | SHV | STG | SVR | TAK | OMC | KEP | PLN | TKM | Verify | % | គម្រោង |
| ផែនការសិក្សាគម្រោងឆ្នាំ២០១៧ | 75 | 114 | 121 | 62 | 102 | 81 | 96 | 138 | 27 | 59 | 21 | 105 | 55 | 128 | 63 | 50 | 103 | 27 | 34 | 83 | 108 | 24 | 5 | 8 | 65 | 1754 | 99% | 1745 |
| មិនទាន់ចាប់ផ្ដើមសិក្សាគម្រោង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0% | 0 |
| កំពង់ដំណើរការសិក្សាគម្រោង | 0 | 0 | 4 | 0 | 0 | 8 | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 3 | 0 | 0 | 4 | 2 | 0 | 0 | 27 | 2% | 27 |
| បានបញ្ចប់ការរៀបចំគម្រោង | 75 | 114 | 117 | 62 | 102 | 73 | 91 | 138 | 27 | 59 | 19 | 105 | 55 | 128 | 61 | 48 | 102 | 27 | 31 | 83 | 105 | 20 | 3 | 8 | 65 | 1718 | 10% | 173 |
| បានចុះកិច្ចសន្យាសាងសង់ | 75 | 96 | 117 | 59 | 98 | 59 | 78 | 136 | 22 | 42 | 19 | 105 | 43 | 128 | 57 | 42 | 90 | 27 | 10 | 83 | 94 | 12 | 0 | 8 | 45 | 1545 | 88% | 1545 |

**សម្គាល់:** ០៨ រាជធានី ខេត្តបានបញ្ចប់ការសិក្សាលទ្ធភាពគម្រោងឆ្នាំ២០១៧ហើយ ខេត្តផ្សេងៗទៀតកំពង់បន្តបញ្ចប់ និងបានចុះកិច្ចសន្យាសាងសង់បាន ១.៥៤៥កិច្ចសន្យា




☞គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ដែលមិនទាន់បញ្ចប់ការសិក្សាមាន៧ខេត្ត ចំនួន២៧គម្រោង (នៅ KPC=4 KPT=8 KAM=5 SRP=1 STG=3 OMC=4 and KEP=2 គម្រោង) និងគម្រោងចំនួន១៧៣ កំពុងបន្តដេញថ្លៃ និងមាន៩គម្រោងបានលើកទៅអនុវត្តឆ្នាំ២០១៨ (KDL=2 MKR=2 TAK=3 and RAT=2)។

តារាង និងក្រាហ្វិកខាងក្រោមជាលទ្ធផលនៃការតាមដានការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់រយៈពេល៧ឆ្នាំ (២០១១-២០១៧ ក្នុងដំណាក់កាលផអ៣ទី១ និងផអ៣ទី២) ភាគរយនេះគឺធៀបនឹងចំនួនគម្រោងក្នុងឆ្នាំ។

| Year | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec | Project |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2011 | 0% | 0% | 0% | 0% | 12% | 16% | 19% | 30% | 43% | 59% | 73% | 85% | **1697** |
| 2012 | 0% | 0% | 4% | 17% | 27% | 42% | 53% | 63% | 75% | 81% | 89% | 95% | **1849** |
| 2013 | 0% | 0% | 4% | 21% | 27% | 61% | 80% | 88% | 92% | 94% | 99% | 99% | **1784** |
| 2014 | 0% | 0% | 4% | 14% | 26% | 49% | 50% | 77% | 83% | 90% | 94% | 98% | **1711** |
| 2015 | 0% | 1% | 8% | 22% | 35% | 51% | 65% | 75% | 85% | 90% | 96% | 99% | **1723** |
| 2016 | 0% | 0% | 8% | 15% | 28% | 46% | 64% | 72% | 84% | 91% | 96% | 99% | **1713** |
| 2017 | 0% | 0% | 4% | 23% | 38% | 59% | 63% | 71% | 78% | 86% | 92% | 98% | **1754** |




### ៣.២.៣.២. ការធ្វើលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧

យោងតាមរបាយការណ៍ពីរាជធានី ខេត្តគិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ មាន ១.៥៧២គម្រោង ស្មើ ៩០% (គម្រោងសរុប=១.៧៥៤) បានប្រកាសដេញថ្លៃ ជាលទ្ធផលទទួលបានជោគជ័យ៩៨% និងបរាជ័យ ២%។ តាមលទ្ធផលនៃការដេញថ្លៃតារាងខាងក្រោមបង្ហាញថា៖ ក) **ការដេញថ្លៃភាគច្រើនមានលក្ខណៈប្រកួតប្រជែងខ្លាំងដោយការដេញចុះច្រើនជាង៣០% មាន៤៨% ខ) ការដេញថ្លៃប្រកួតប្រជែងមធ្យមចុះពី២០% ទៅ ៥% មាន២២% និង គ) លក្ខណៈត្រូវរ៉ូវ ឬឃុបឃិតគ្នាមាន ៣០% (ដេញចុះតិចជាង៥%)។**

ការដេញថ្លៃនៅឆ្នាំ២០១៧នេះមានការប្រកួតប្រជែងនិងមានអ្នកទទួលការចូលរួមច្រើនក្នុងពេលដេញថ្លៃម្តងៗ តែក៏មានអ្នកទទួលការខ្លះដាក់តម្លៃដេញទាបបំផុត ចំពោះលទ្ធផលគម្រោងដែលមិនអាចបន្ថែមលទ្ធផលបាន តែបើគាត់ដឹងថាគម្រោងណាអាចបន្ថែមលទ្ធផលបានគាត់ដេញថ្លៃខ្ពស់កប់ពពក (ហើយស៊ុំគ្រលំជាមួយមេឃុំ ឬម្ចាស់គម្រោង ធ្វើការបន្ថែមលទ្ធផលគម្រោងដែលដេញថ្លៃនោះ)។

☞ សូមមើលតារាងខាងក្រោមបង្ហាញពីលទ្ធផលនៃការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ គិតដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ តាមរាជធានី ខេត្តនីមួយៗ៖

| លរ/កូដខេត្ត | រាជធានី ខេត្ត | ចំនួនគម្រោង | | | ភាគរយចុះធៀបតម្លៃប៉ាន់ស្មាន | | | | | | អ្នកទទួលការជាមធ្យមដែលបានដេញក្នុង១គម្រោង |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រកាសដេញថ្លៃរួច | ជោគជ័យ | បរាជ័យ | ច្រើនជាង៥០% | ៥០-៣០% | ៣០-២០% | ២០-១០% | ១០-៥% | ៥-0% | |
| ១ | បន្ទាយមានជ័យ | 75 | 75 | 0 | 12 | 13 | 14 | 8 | 20 | 8 | 4-9 |
| ២ | បាត់ដំបង | 100 | 96 | 4 | 54 | 25 | 8 | 0 | 0 | 9 | 4 |
| ៣ | កំពង់ចាម | 117 | 117 | 0 | 15 | 16 | | 5 | 16 | 65 | 3 to 5 |
| ៤ | កំពង់ឆ្នាំង | 59 | 59 | 0 | 11 | 15 | 1 | 1 | 11 | 20 | 5 នាក់ |
| ៥ | កំពង់ស្ពឺ | 98 | 98 | 0 | 65 | 19 | 3 | 4 | 4 | 3 | 3-13 |
| ៦ | កំពង់ធំ | 62 | 59 | 3 | 21 | 14 | 0 | 0 | 1 | 23 | 5 |
| ៧ | កំពត | 78 | 78 | 0 | 27 | 2 | 0 | 1 | 23 | 25 | 1-3 |
| ៨ | កណ្តាល | 138 | 136 | 2 | 19 | 73 | 8 | 21 | 2 | 13 | 3-4 |
| ៩ | កោះកុង | 23 | 21 | 2 | 7 | 7 | 0 | 3 | 2 | 2 | 3 |
| ១០ | ក្រចេះ | 49 | 42 | 7 | 6 | 2 | 2 | 0 | 1 | 31 | 3-4នាក់ |
| ១១ | មណ្ឌលគិរី | 19 | 19 | 0 | 10 | 3 | | 2 | | 4 | 4 |
| ១២ | ភ្នំពេញ | 105 | 105 | 0 | 12 | 37 | 2 | 11 | 39 | 4 | 5 |
| ១៣ | ព្រះវិហារ | 43 | 42 | 1 | 4 | 5 | 1 | 4 | 1 | 28 | 3-4 |
| ១៤ | ព្រៃវែង | 128 | 128 | 0 | 59 | 17 | 0 | 2 | 4 | 46 | 5 |
| ១៥ | ពោធិ៍សាត់ | 58 | 57 | 1 | 8 | 15 | 22 | 6 | 5 | 1 | 4 |
| ១៦ | រតនគិរី | 43 | 42 | 1 | 0 | 5 | 3 | 5 | 3 | 26 | 3-4នាក់ |
| ១៧ | សៀមរាប | 90 | 90 | 0 | 26 | 22 | 5 | 1 | 1 | 35 | 3-5 |
| ១៨ | ព្រះសីហនុ | 27 | 27 | 0 | | | 3 | | | 24 | 4-5 |
| ១៩ | ស្ទឹងត្រែង | 12 | 10 | 2 | 1 | | | | 8 | 1 | 4 |
| ២០ | ស្វាយរៀង | 83 | 83 | 0 | 36 | 6 | 0 | 0 | 1 | 40 | 5 |
| ២១ | តាកែវ | 97 | 94 | 3 | 22 | 8 | 1 | 15 | 31 | 17 | 3 - 9 |
| ២២ | ឧត្តរមានជ័យ | 15 | 12 | 3 | 9 | | | 1 | | 2 | 3 |
| ២៣ | កែប | | | | | | | | | | |
| ២៤ | ប៉ៃលិន | 8 | 8 | 0 | 0 | 0 | 0 | 0 | 2 | 6 | 3 |
| ២៥ | ត្បូងឃ្មុំ | 45 | 45 | 0 | 17 | 1 | 0 | 0 | 1 | 26 | 3-7នាក់ |
| | សរុប | **1572** | **1543** | **29** | **441** | **305** | **73** | **90** | **176** | **459** | |
| | ភាគរយ | 100% | 98% | 2% | 28.6% | 19.8% | 4.7% | 5.8% | 11.4% | 29.7% | |




**សម្គាល់៖** ការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ មានភាពរអាក់រអួលបន្តិចក្នុងខែមិថុនា-កក្កដា ដោយសារគណៈកម្មការលទ្ធកម្មខ្វះកូរ៉ុម (បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧) ធ្វើឱ្យគម្រោងមូលនិធិឃុំ សង្កាត់ មួយចំនួនដែលបានបញ្ចប់ការរៀបចំសំណើគម្រោងរួចហើយ តែមិនទាន់បានប្រកាសដេញថ្លៃទេ ដោយពន្យារពេលសិនរង់ចាំការរៀបចំក្រុមប្រឹក្សាឃុំ សង្កាត់អណត្តិថ្មីរួចរាល់សិន លុះដល់ពាក់កណ្តាលខែវិច្ឆិកាក៏កើតមានការផ្លាស់ប្តូរក្រុមប្រឹក្សាឃុំម្តងទៀត ធ្វើឱ្យគម្រោងមួយចំនួនមិនអាចប្រកាសដេញថ្លៃបាន។

ដើម្បីពង្រឹងការអនុវត្តតួនាទី ភារកិច្ចដល់អ្នកពាក់ព័ន្ធក្នុងដំណើរការដេញថ្លៃគម្រោងប្រកបដោយប្រសិទ្ធភាពតម្លាភាព និងគណនេយ្យភាពមន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់បានចុះសង្កេតមើលការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់បាន២៨គម្រោង ស្មើនឹង២៧ឃុំ សង្កាត់ ១១ក្រុង ស្រុក ៥ខេត្តហើយលទ្ធផលបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ក្រុង ស្រុក | ឃុំ សង្កាត់ | ចំនួនគម្រោង |
|---|---|---|---|---|
| ១ | កំពត (29-30/03/17) | ស្រុកបន្ទាយមាស និងស្រុកឈូក | ឃុំស្តេចគង់ខាងជើង ឃុំព្រៃទន្លេ ឃុំបន្ទាយមាសខាងកើត ឃុំសំរោងលើ ឃុំបានៀវ និងឃុំដូនយ៉យ | ៦ |
| ២ | កំពង់ចាម (30-31/03/17) | ស្រុកកំពង់សៀម និងស្រុកចំការលើ | ឃុំរំចេក ឃុំស្ពឺ និងឃុំជយោ | ៤ |
| ៣ | បន្ទាយមានជ័យ (09-12/05/17) | ស្រុកមង្គលបូរី ស្រុកព្រះនេត្រព្រះ និងក្រុងប៉ោយប៉ែត | ឃុំភ្នំតូច រហាត់ទឹក ឬស្សីក្រោក សំបួរ តាឡំ ភ្នំលាភ ទឹកជោរ សង្កាត់ផ្សារកណ្តាល និម្មិត និងប៉ោយប៉ែត | ១០ |
| ៤ | សៀមរាប (23-26/05/17) | ស្រុកអង្គរជុំ និងស្រុកសូទ្រនិគម | ឃុំគោកដូង ឃុំនគរភាស និងឃុំកៀនសង្កែ | ៣ |

| | | | | |
|---|---|---|---|---|
| ៥ | កំពង់ឆ្នាំង (07-10/06/17) | ស្រុករលាប្អៀរ និងស្រុកបរិបូណ៌ | ឃុំបន្ទាយព្រាល ឃុំប្រស្នឹប ឃុំផ្សារ ឃុំពេជចង្វារ និងឃុំពពេល | ៥ |
| **សរុប** | **៥ខេត្ត** | **១១ក្រុង ស្រុក** | **២៧ឃុំ សង្កាត់** | **២៨** |

បន្ទាប់ពីការចុះសង្កេតមើលការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ខាងលើ ក្រុមការងារបច្ចេកទេសការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់បានរកឃើញចំណុចល្អ និងចំណុចខ្វះខាតមួយចំនួនដូចខាងក្រោម៖

ក. **ចំណុចល្អ៖**

- មានរបៀបវារៈត្រឹមត្រូវ បានចុះបញ្ជីវត្តមានអ្នកចូលរួម អ្នកទទួលការ និងអ្នកចូលរួមភាគច្រើនមានក្រមសីលធម៌ល្អ
- បានប្រកាសទុនចូលរួមឱ្យអ្នកចូលការដេញថ្លៃបានដឹង និងបានអានគោលការណ៍សំខាន់ៗឱ្យអ្នកទទួលការ និងអ្នកចូលរួមយល់ច្បាស់ពីនីតិវិធីដេញថ្លៃ
- ខេត្តខ្លះគណៈអភិបាលស្រុកចូលរួមបើក និងបិទការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ជាអធិបតី
- ការប្រជុំបើកសំណើ និងប្រកាសលទ្ធផលដេញថ្លៃជាសាធារណៈ
- ពេលដាក់ និងទទួលសំណើដេញថ្លៃបានអនុវត្តតាមនីតិវិធីក្នុងសៀវភៅភីម
- អ្នកឈ្នះក្នុងការដេញថ្លៃបានឡើងធ្វើការប្តេជ្ញាចិត្តក្នុងការអនុវត្តគម្រោងចំពោះមន្ត្រីទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីបច្ចេកទេស គណៈកម្មការលទ្ធកម្ម ស្មៀន សមាជិកក្រុមប្រឹក្សា និងប្រជាពលរដ្ឋដែលបានចូលរួម
- មុនប្រកាសបិទអង្គប្រជុំដេញថ្លៃគណៈអភិបាលស្រុក និងគណៈកម្មការលទ្ធកម្មមានមតិផ្តាំផ្ញើរទៅកាន់អ្នកដេញថ្លៃឈ្នះឱ្យយកចិត្តទុកដាក់អនុវត្តគម្រោងតាមកិច្ចសន្យា និងមានគុណភាពល្អ

ខ. **ចំណុចខ្វះខាត៖**

- អ្នកដែលចូលរួមដេញថ្លៃច្រើន តែបានដាក់សំណើដេញថ្លៃចំនួនតិចជាងការរំពឹងទុក
- ឃុំ សង្កាត់ខ្លះមិនមានរបៀបវារៈនៃការដេញថ្លៃ
- ពេលអានគោលការណ៍សំខាន់ៗនៃការដេញថ្លៃ អ្នកទទួលការចូលរួមស្តាប់តិចតួចបំផុត ខ្លះទៀតមិនចូលស្តាប់ទៀតផង រង់ចាំនៅខាងក្រៅអគារ ចាំតែពេលដាក់សំណើដេញថ្លៃ
- គណៈកម្មការលទ្ធកម្ម និងស្មៀនឃុំខ្លះមិនបានចូលក្នុងបន្ទប់នៅពេលប្រជុំវាយតម្លៃសំណើដេញថ្លៃ។

ក្នុងករណីដែលការដេញថ្លៃប្រកួតប្រជែងខ្លាំងនៅខេត្តមួយចំនួន ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិបានសហការជាមួយការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់បានផ្តល់យោបល់ខ្លះៗ ទៅរាជធានី ខេត្តសម្រាប់ពិចារណា៖

- រាជធានី ខេត្តគួរពន្យល់ ឬណែនាំទៅគណៈកម្មការលទ្ធកម្មឃុំ សង្កាត់ ដោយមិនគួរអនុញ្ញាតឱ្យបន្ថែមលទ្ធផលគម្រោងក្រោយការដេញថ្លៃ ប្រសិនពិនិត្យឃើញថាតម្លៃឯកតានីមួយៗ មានគម្លាតខុសគ្នាខ្លាំងពីតម្លៃឯកតាមួយទៅតម្លៃឯកតាមួយទៀត ហើយថវិកាដែលសល់ពីការដេញថ្លៃត្រូវរៀបចំឯកសារគម្រោងថ្មី ដេញថ្លៃលទ្ធផលថ្មី ធ្វើរបៀបនេះឃុំ សង្កាត់អាចចំណេញលទ្ធផលគម្រោងបានច្រើន ឬទុកលុយសល់ទៅធ្វើគម្រោងមួយទៀត ឬទុកមូលនិធិនេះអតិរេកទៅឆ្នាំ២០១៨។

- ក្រោយចុះកិច្ចសន្យាចំពោះលទ្ធផលដែលបានដេញថ្លៃ ត្រូវតាមដានការអនុវត្តឱ្យបានម៉ត់ចត់ទៅតាមគំនូសប្លង់ និងបទដ្ឋានបច្ចេកទេសដោយប្រើប្រាស់ទម្រង់តាមដានការអនុវត្តគម្រោង។ ក្នុងករណីដែលអ្នកទទួលការមិនមកចុះកិច្ចសន្យា ឬចុះកិច្ចសន្យាហើយចេះតែពន្យារពេលអនុវត្តគម្រោងរាជធានី ខេត្តត្រូវមានវិធានការបន្ទាន់។

### ៣.២.៣.៣. ការអនុវត្តកិច្ចសន្យាគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧

គិតមកដល់ពាក់កណ្ដាលខែធ្នូនេះគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ មានគម្រោងចំនួន១.៥៤៥ បានចុះកិច្ចសន្យាសាងសង់។ តារាងខាងក្រោមបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តកិច្ចសន្យាទាំង១.៥៤៥។

| ការបរិយាយ | ចំនួនកិច្ចសន្យា | គិតជា% | ផ្សេងៗ |
|---|---|---|---|
| បានបញ្ចប់ការសាងសង់ | ៥៩៥ | ៣៩% | ការអនុវត្តកិច្ចសន្យាឆ្នាំ២០១៧ យឺតជាងឆ្នាំ២០១៦ ជាង៥% បើធៀបនឹងរយៈពេលដូចគ្នា។ |
| អនុវត្តបានលើសពី៥០% | ២១៥ | ១៤% | |
| អនុវត្តបានតិចជាង៥០% | ១៥៦ | ១០% | |
| មិនទាន់បានអនុវត្ត | ៥៧៩ | ៣៧% | |
| អ្នកទទួលការបោះបង់ចោល | 0 | 00% | |

តារាង និងក្រាហ្វិកខាងក្រោមបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តកិច្ចសន្យាគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ ២០១៧ លម្អិតតាមរាជធានី ខេត្តនីមួយៗ៖

វឌ្ឍនភាពនៃការអនុវត្តកិច្ចសន្យាគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ គិតត្រឹមថ្ងៃ១៥ ខែធ្នូ ឆ្នាំ២០១៧




| លេខកូដរាជធានី ខេត្ត | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះកាត់រាជធានី ខេត្ត | BMC | BAT | KPC | KCH | KSP | KPT | KAM | KDL | KKG | KRT | MKR | PNP | PVR |
| កិច្ចសន្យាសរុប | 75 | 96 | 117 | 59 | 98 | 59 | 78 | 136 | 22 | 42 | 19 | 105 | 43 |
| មិនទាន់បានអនុវត្ត | 10 | 65 | 49 | 50 | 16 | 30 | 25 | 13 | 14 | 34 | 4 | 4 | 26 |
| អនុវត្តបានតិចជាង ៥០% | 3 | 2 | 0 | 4 | 7 | 7 | 3 | 10 | 5 | 3 | 10 | 10 | 10 |
| អនុវត្តបានលើសពី ៥០% | 24 | 7 | 12 | 3 | 32 | 11 | 6 | 16 | 0 | 0 | 1 | 23 | 0 |
| បញ្ចប់ការសាងសង់១០០% | 38 | 22 | 56 | 2 | 43 | 11 | 44 | 97 | 3 | 5 | 4 | 68 | 7 |
| អ្នកទទួលការបោះបង់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ផ្ទៀងផ្ទាត់តាមខេត្ត | 75 | 96 | 117 | 59 | 98 | 59 | 78 | 136 | 22 | 42 | 19 | 105 | 43 |

| លេខកូដរាជធានី ខេត្ត | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | ផ្ទៀងផ្ទាត់ | ភាគរយ | ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះកាត់រាជធានី ខេត្ត | PVG | PUR | RAT | SRP | SHV | STG | SVR | TAK | OMC | KEP | PLN | TKM | Verify | % | |
| កិច្ចសន្យាសរុប | 128 | 57 | 42 | 90 | 27 | 10 | 83 | 94 | 12 | 0 | 8 | 45 | 1545 | 100% | 1545 |
| មិនទាន់បានអនុវត្ត | 51 | 36 | 32 | 25 | 5 | 9 | 34 | 21 | 9 | 0 | 0 | 17 | 579 | 37% | 579 |
| អនុវត្តបានតិចជាង ៥០% | 5 | 13 | 6 | 19 | 12 | 0 | 3 | 15 | 3 | 0 | 0 | 6 | 156 | 10% | 156 |
| អនុវត្តបានលើសពី ៥០% | 30 | 2 | 2 | 13 | 8 | 0 | 8 | 4 | 0 | 0 | 1 | 12 | 215 | 14% | 215 |
| បញ្ចប់ការសាងសង់១០០% | 42 | 6 | 2 | 33 | 2 | 1 | 38 | 54 | 0 | 0 | 7 | 10 | 595 | 39% | 595 |
| អ្នកទទួលការបោះបង់ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0% | 0 |
| ផ្ទៀងផ្ទាត់តាមខេត្ត | 128 | 57 | 42 | 90 | 27 | 10 | 83 | 94 | 12 | 0 | 8 | 45 | 1545 | 100% | 1545 |

សម្គាល់៖ ២៤ រាជធានី ខេត្តបានចុះកិច្ចសន្យាការសាងសង់គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ នៅទ្បើយតែខេត្តកែប។

## ៣.២.៤. ការចុះតាមដានការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

យោងសេចក្តីណែនាំលេខ០០១ សណន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងផ្អែកលើផែនការសកម្មភាពឆ្នាំ២០១៧ លេខ២.៤.២.១.៥ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ក្រោមក្របខណ្ឌអ៣ទី២ ក្រុមការងារបច្ចេលទេសការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ បានចុះធ្វើការត្រួតពិនិត្យការអនុវត្តគម្រោងបាន៤៤គម្រោងនៅ៤៣ឃុំ សង្កាត់ ២៥ក្រុង ស្រុក ១១ខេត្ត តារាងខាងក្រោមបង្ហាញពីឈ្មោះខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ដែលបានចុះត្រួតពិនិត្យការអនុវត្តគម្រោងគិតមកដល់ដំណាច់ខែវិច្ឆិកា ឆ្នាំ២០១៧។

| ល.រ | រាជធានី ខេត្ត | ក្រុង ស្រុក | ឃុំ សង្កាត់ | ចំនួនគម្រោង |
|---|---|---|---|---|
| ១ | មណ្ឌលគិរី (28/02/ to 02/03/17) | ស្រុកពេជ្រាដា ស្រុកកែវសីមា និងក្រុងសែនមនោរម្យ | ឃុំស្រែអំពូម ឃុំស្រែខ្ទុម និង សង្កាត់ស្ពានមានជ័យ | ៣ |
| ២ | ព្រះសីហនុ (14-16/03/17) | ស្រុកព្រៃនប់ ស្រុកស្ទឹងហាវ ក្រុងព្រះសីហនុ | ឃុំជើងគោ ឃុំបឹងតាព្រហ្ម ឃុំអូរជ្រៅ ឃុំកំពេញ ឃុំអូរត្រេះ និង សង្កាត់លេខ១ | ៦ |
| ៣ | កំពង់ស្ពឺ (28-30/03/17) | ស្រុកភ្នំស្រួច និងក្រុងច្បារមន | ឃុំដំបូករូង និងសង្កាត់កណ្តោលដុំ | ២ |
| | | ស្រុកឱរ៉ាល់ | ពិនិត្យគម្រោងស្រុក | ១ |
| ៤ | ព្រៃវែង (08-12/05/17) ករណីអនុវត្តយឺត (ប្តឹង) | ស្រុកព្រះស្តេច ស្រុកពាមរក៍ ស្រុកស៊ីធរកណ្តាល | ឃុំរំចេក ឃុំព្រៃកខ្សាយ ក និងឃុំព្រៃកចង្ក្រាន | ៣ |
| | | ស្រុកស៊ីធរកណ្តាល | ពិនិត្យគម្រោងស្រុក | ១ |
| ៥ | បាត់ដំបង (22-27/05/17) | ស្រុកបវេល | ពិនិត្យឯកសារ៤គម្រោងគឺនៅឃុំខ្នាចរមាស ឃុំអំពិលប្រាំដើម ឃុំឃ្លាំងមាស និងឃុំបវេល តែត្រួតពិនិត្យផ្ទាល់មួយឃុំបវេលទេ | ១ |
| ៦ | ត្បូងឃ្មុំ (26-30/06/17) | ស្រុកត្បូងឃ្មុំ និងស្រុកមេមត់ | ឃុំបឹងព្រួល ឃុំជប់ ឃុំត្រមូង | ៣ |
| | | ស្រុកអូររាំងឪ | គម្រោងស្រុក | ១ |
| ៧ | តាកែវ (24-28/07/17) | ស្រុកគិរីវង ស្រុកសំរោង និង ក្រុងដូនកែវ | ឃុំអង្គប្រាសាទ ឃុំខ្វាវ ឃុំស្លា និង សង្កាត់រកាក្នុង | ៤ |
| ៨ | កំពង់ឆ្នាំង (14-18/08/17) | ស្រុកបរិបូរណ៍ ស្រុកទឹកផុស ស្រុករលាប្អៀរ ស្រុកកំពង់ត្រឡាច និងក្រុងកំពង់ឆ្នាំង | ឃុំខុនរ៉ង ឃុំអភិវឌ្ឍន៍ ឃុំស្វាយជ្រុំ ឃុំស្រែថ្មី ឃុំឈូក និងសង្កាត់ខ្សាម | ៦ |
| ៩ | កោះកុង | ស្រុកថ្មបាំង ស្រុកមណ្ឌល | ឃុំតាទៃលើ ឃុំឫស្សីជ្រុំ ឃុំពាមក្រ | ៤ |

| | | | | |
|---|---|---|---|---|
| | (10-16/09/17) | សីមា និងក្រុងខេមរភូមិន | សោម និងសង្កាត់ស្មាច់មានជ័យ | |
| ១០ | សៀមរាប (09-14/10/17) | ស្រុកបន្ទាយស្រី អង្គរធំ សូទ្រនិគម និងក្រុងសៀមរាប | ឃុំរំចេក ឃុំជប់តាត្រាវ ឃុំដំដែក និងសង្កាត់ស្វាយដង្គំ | ៤ |
| ១១ | ស្ទឹងត្រែង (05-11/11/17) | ស្រុកសៀមប៉ាង ក្រុងស្ទឹងត្រែង និងស្រុកសៀមបូក | នៅឃុំថ្មកែវ សង្កាត់សាមគ្គី និងសង្កាត់ស្រះឬស្សី និងឃុំអូរម្រះ | ៥ |
| **សរុប** | **១១ខេត្ត** | **២៥ក្រុង ស្រុក** | **៤០ឃុំ សង្កាត់ និង៣គម្រោងស្រុក** | **៤៤ គម្រោង** |

**បញ្ជាក់៖** បញ្ហាដែលក្រុមការងារបានរកឃើញ គឺបានធ្វើជាបទបង្ហាញឆ្លុះបញ្ចាំងជូនក្រុមការងារខេត្តឱ្យបានដឹងពីចំណុចល្អ និងចំណុចខ្វះខាត និងផ្តល់អនុសាសន៍សម្រាប់ធ្វើការកែលម្អ ចំពោះការចុះត្រួតពិនិត្យការអនុវត្តគម្រោងទាំង៤៤គម្រោង នៅ៤៣ឃុំ សង្កាត់ ២៥ក្រុង ស្រុក ១១ខេត្ត (របាយការណ៍នៃការចុះតាមដានការអនុវត្តគម្រោងបង្ហាញជាឧទាហរណ៍នៅ**ឧបសម្ព័ន្ធទី១**។

☞ បានចុះពិនិត្យផ្ទៀងផ្ទាត់ការផ្តល់អនុសាសន៍ឱ្យកែលម្អ នូវអ្វីដែលបានរកឃើញកាលពីឆ្នាំ២០១៦

| **ល.រ** | **រាជធានី ខេត្ត** | **ក្រុង ស្រុក** | **ឃុំ សង្កាត់** | **ចំនួន គម្រោង** |
|---|---|---|---|---|
| ១ | រតនគិរី (14-16/03/17) | ស្រុកលំផាត់ | ឃុំសេដា | ១ |
| | | ស្រុកតាវែង និងស្រុកបកែវ | ពិនិត្យគម្រោងស្រុកឆ្នាំ២០១៦ | ២ |
| ២ | ព្រះវិហារ | គ្រោងទៅពាក់កណ្តាលខែធ្នូ ២០១៧ តែពេលវេលាមិនអនុគ្រោះ | | 0 |
| **សរុប** | **១ខេត្ត** | **៣ ស្រុក** | **១ឃុំ សង្កាត់ ២ស្រុក** | **៣** |

☞ បានចុះជួយមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តដែល**គ្មានទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ**ចំនួន២ខេត្ត

| **ល.រ** | **រាជធានី ខេត្ត** | **ពិពណ៌នា** |
|---|---|---|
| ១ | កំពង់ចាម (21-22/02/17) | ✓ ផ្តល់នូវការណែនាំពីគំនូសប្លង់បច្ចេកទេស និងរបៀបគណនាតារាងប៉ាន់ស្មានតម្លៃ សម្រាប់ការសិក្សាគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧។<br>✓ ធ្វើការដំឡើងនូវកម្មវិធី Auto-CAD ArcReader និងគំនូសប្លង់បច្ចេកទេសក្នុង NCDD Template បញ្ចូលកុំព្យូទ័ររបស់ TSO។<br>✓ TSO សរុប ១១នាក់ |
| ២ | កែប (11-14/10/17) | ✓ ផ្តល់នូវការណែនាំពីគំនូសប្លង់បច្ចេកទេស និងរបៀបគណនាតារាងប៉ាន់ស្មានតម្លៃសម្រាប់ការសិក្សាគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ដែលជាបញ្ហាជួបប្រទះ TSO ដោះស្រាយមិនចេញ<br>✓ ធ្វើការដំឡើងនូវកម្មវិធី Auto-CAD ថ្មី ArcReader GPS និងគំនូសប្លង់បច្ចេកទេសថ្មីៗ ទើបកែសម្រួលបញ្ចូលក្នុងកុំព្យូទ័ររបស់ TSO សម្រាប់ប្រើប្រាស់។ |

| | | |
|---|---|---|
| | | ✓ បានណែនាំទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្មីរបស់ខេត្តកំពត ឱ្យជួយគាំទ្រដល់ការអនុវត្តគម្រោងក្រុង ស្រុក និងឃុំ សង្កាត់នៅខេត្តកែប<br>✓ បានបង្ហាញពីគំនូសប្លង់បច្ចេកទេស និងរបៀបគណនាតារាងប៉ាន់ស្មានតម្លៃដែលជាតម្រូវការរបស់ TSO និងផ្តល់មេរៀនមួយចំនួនដល់ TSO ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលដល់ឃុំ សង្កាត់ និងអ្នកទទួលការ។ ក្នុងពេលនោះដែរក្រោយពីធ្វើបទបង្ហាញបានឱ្យ TSO អនុវត្តជាក់ស្តែងលើការគ្រោងគំនូសប្លង់បច្ចេកទេស និងតារាងប៉ាន់ស្មានតម្លៃលូជ្រុង៣មX២ម មានទ្វារទឹកនិយ័តករ និងផ្លូវបេតុងអាមេដោយខ្លួនឯង។ |

ក្រៅពីចុះតាមដានត្រួតពិនិត្យការអនុវត្តគម្រោង ក្រុមការងារនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិបានចុះសិក្សាពីករណីមិនប្រក្រតីចំនួន២រាជធានី ខេត្តក្នុងឆ្នាំ២០១៧។

| ល.រ | រាជធានី ខេត្ត | ពិពណ៌នា |
|---|---|---|
| ១ | ព្រៃវែង | ការអនុវត្តគម្រោងឆ្នាំ២០១៦ មានការយឺតយ៉ាវនៅឃុំរំចេក ស្រុកព្រះស្តេច |
| ២ | រាជធានីភ្នំពេញ | អ្នកទទួលការប្តឹងពីការអនុវត្តនីតិវិធីលទ្ធកម្មឃុំ សង្កាត់ (សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ) |

ការសិក្សាពីករណីមិនប្រក្រតីនេះបានរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំជ្រាប ហើយក៏បានធ្វើរបាយការណ៍ ត្រឡប់ជូនរាជធានី ខេត្តវិញដោយផ្តល់អនុសាសន៍ដើម្បីអនុវត្តបន្ត (**ឧបសម្ព័ន្ធទី២**)។

### ☞ កំណត់ត្រានៃការចុះតាមដានការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់តាមខេត្តកន្លងមក

តារាងបង្ហាញពីការកត់ត្រានៃការចុះតាមដានការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់តាមខេត្ត រយៈពេល ៧ឆ្នាំ (២០១១-២០១៧)

| ឆ្នាំ | ចំនួនខេត្ត | ការអនុវត្តគម្រោង | ចំនួនឃុំ សង្កាត់ |
|---|---|---|---|
| ២០១១ | ១***** | បន្ទាយមានជ័យ | ០១គម្រោង នៅ១ឃុំ ១ស្រុក ១ខេត្ត |
| ២០១២ | ១០ | កណ្តាល កំពង់ចាម សៀមរាប បាត់ដំបង រតនគិរី កែប កោះកុង បន្ទាយមានជ័យ ប៉ៃលិន មណ្ឌលគិរី | ៣៧គម្រោង នៅ៣៧ឃុំ សង្កាត់ ២៣ក្រុងស្រុក ១០ខេត្ត |
| ២០១៣ | ១៤ | ព្រៃវែង កែប កំពត* បាត់ដំបង* កំពង់ឆ្នាំង តាកែវ* រតនគិរី * បាត់ដំបង* កំពង់ស្ពឺ សៀមរាប និងខេត្តស្វាយរៀង (* ចុះ២ដងក្នុង១ឆ្នាំ) | ៥១គម្រោង នៅ៥០ឃុំ សង្កាត់ ៣១ ក្រុងស្រុក ១១ខេត្ត |

| | | | |
|---|---|---|---|
| ២០១៤ | ៧ | កណ្តាល កោះកុង ស្ទឹងត្រែង កំពង់ចាម កំពង់ធំ ពោធិ៍សាត់ ស្វាយរៀង | ៣៨គម្រោង នៅ៣៦ឃុំ សង្កាត់ ២៨ ក្រុងស្រុក ៧ខេត្ត |
| ២០១៥ | ៤ | ត្បូងឃ្មុំ កំពង់ឆ្នាំង កំពត ឧត្តរមានជ័យ | ១៨គម្រោង នៅ១៧ឃុំ សង្កាត់ ១៥ ក្រុងស្រុក ៤ខេត្ត |
| ២០១៦ | ៥ | កំពង់ស្ពឺ កំពង់ធំ ស្វាយរៀង ក្រចេះ ព្រះវិហារ | ២៥គម្រោង នៅ២៥ឃុំ សង្កាត់ ១៧ ក្រុងស្រុក ៥ខេត្ត |
| ២០១៧ | ១១ | មណ្ឌលគិរី ព្រះសីហនុ កំពង់ស្ពឺ ព្រៃវែង បាត់ដំបង ត្បូងឃ្មុំ តាកែវ កំពង់ឆ្នាំង កោះកុង សៀមរាប ស្ទឹងត្រែង | ៤៤ គម្រោង នៅ៤៣ឃុំ សង្កាត់ ២៥ ក្រុង ស្រុក ១១ខេត្ត (ក្នុងនោះមានគម្រោងក្រុង ស្រុកចំនួន៣) |
| **ភ្នំពេញ បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កណ្តាល ក្រចេះ ព្រៃវែង ពោធិ៍សាត់ ប៉ៃលិន និងខេត្តត្បូងឃ្មុំ** | | | គួរពិចារណាចុះពិនិត្យ បើមានបេសកកម្មឆ្នាំ២០១៨ |

***** ក្នុងឆ្នាំ២០១១ គឺចុះទៅតាមខេត្តដើម្បីបណ្តុះបណ្តាល TSO និងចុះសិក្សាពីស្ថានភាពអគារសាលាស្រុកច្រើន។




## ៣.២.៥. បញ្ហាប្រឈមក្នុងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

### ☞ បញ្ហាចម្បងទូទៅក្នុងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧

- ✓ **បញ្ហាចម្បងទី១៖** ឃុំ សង្កាត់មួយចំនួនបានផ្អាកការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ដោយខ្វះគូរ៉ុម មូលហេតុដោយយោងលើលិខិតលេខ ៣៧៣ សជណ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ ស្តីពីការអនុវត្តគោលការណ៍ និងនីតិវិធីចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬសមាជិកក្រុមប្រឹក្សាក្រុង ស្រុកខណ្ឌដែលបានទៅឈរឈ្មោះជាបេក្ខជនពេញសិទ្ធ ឬបេក្ខជនបម្រុងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

- ✓ **បញ្ហាចម្បងទី២៖** ការបញ្ចូលទិន្នន័យព័ត៌មានគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ទាំងអស់ត្រូវបានអាក់ខានដោយសារប្រព័ន្ធ PID ធ្វើការកែសម្រួល និងមួយទៀតស្ទះដោយសារការគណនាពន្ធបញ្ចូលក្នុងកិច្ចសន្យា (ពន្ធតូច-ពន្ធមធ្យម-ពន្ធធំ)។
- ✓ **បញ្ហាចម្បងទី៣៖** គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ប្រមាណ១៨០គម្រោង (១០%) ដែលបានរៀបចំព័ត៌មានគម្រោងរួចហើយនៅក្នុងអំឡុងខែធ្នូ មិនអាចប្រកាសដេញថ្លៃបានដោយសារមានការផ្លាស់គណៈកម្មការលទ្ធកម្មថ្មីម្តងទៀតចំពោះឃុំ សង្កាត់មួយចំនួន និងមានការផ្លាស់ប្តូរនីតិវិធីថ្មី ដោយចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ទៅ ត្រូវអនុវត្តនីតិវិធីក្នុងភីម២០១៧។
- ✓ **បញ្ហាចម្បងទី៤៖** ការដេញថ្លៃមានការប្រកួតប្រជែងខ្លាំងប្រមាណ៤៨%នៃគម្រោងដែលបានដេញថ្លៃហើយ១.៥៤៣ បានដេញចុះពី៣០%-៥០% ធៀបនឹងតម្លៃប៉ាន់ស្មាន *(ករណីដែលចុះខ្លាំងបែបនេះមជ្ឈដ្ឋានទូទៅចោទអ្នកបច្ចេកទេសថាសិក្សាបំប៉ោងតម្លៃ តែបើដេញថ្លៃចុះតិចៗ គេថាអ្នកបច្ចេកទេសត្រូវរ៉ូវគ្នាជាមួយអ្នកទទួលការ)* ការពិតការដេញថ្លៃចុះខ្លាំងនេះគឺជាល្បិចថ្មីរបស់អ្នកទទួលការគឺ**ដេញដើម្បីបន្តលទ្ធផលគម្រោងដែលពួកគាត់ដាក់ដេញថ្លៃខ្ពស់** និងមួយទៀតគាត់ដេញយកឈ្នះចាញ់គ្នា ឬដេញដើម្បីគម្រាមអ្នកមកពីក្រៅខេត្ត។

☞ **បញ្ហាខ្លះៗ ក្នុងពេលរៀបចំគម្រោង**

- ✓ ខេត្តមួយចំនួនធំខ្វះឧបករណ៍ដើម្បីធ្វើការសិក្សាគម្រោងដូចជា៖ ឧបករណ៍ឋានលេខា ក្តារមៀរ ឧបករណ៍ GPS និងខ្សែម៉ែត្រ ឧបករណ៍ដែលបានផ្តល់ពីមុនបានខូច និងចាស់ៗអស់ខ្លះហើយ។ NIA បានធ្វើការសិក្សា និងប្រមូលទិន្នន័យពីរាជធានី ខេត្តនៅចុងឆ្នាំ២០១៦ពីឧបករណ៍សម្រាប់ជួយគាំទ្រការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ (សូមមើល**ឧបសម្ព័ន្ធទី៤**)។
- ✓ ខេត្តមួយចំនួនមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធមានការផ្លាស់ប្តូរច្រើនក្នុងឆ្នាំនេះ អ្នកថ្មីចូលមកគឺថ្មីសុទ្ធ គ្មានជំនាញបច្ចេកទេសសោះ ទាមទារការបណ្តុះបណ្តាលបណ្តើរ ធ្វើបណ្តើរច្រើន។
- ✓ ការសហការពីម្ចាស់គម្រោងមិនបានពេញលេញ។ ឧទាហរណ៍ៈ ការណាត់ជួប ការកាប់ឆ្ការព្រៃ ការសម្របសម្រួលជាមួយអ្នកទទួលផល ការសិក្សាផលប៉ះពាល់ដីធ្លី និងបរិស្ថាន។ល។
- ✓ មធ្យោបាយធ្វើដំណើរចាស់ៗ សាំង និងការផ្តល់ក្រដាសដល់ TSO តិចពេកនៅរដូវចុះសិក្សាគម្រោង។

☞ **បញ្ហាខ្លះៗ ក្នុងពេលដេញថ្លៃ**

- ✓ ការដាក់**ប្រាក់ធានាការដេញថ្លៃចំនួនយ៉ាងតិច២%**នៃតម្លៃដាក់ដេញថ្លៃរបស់អ្នកទទួលការ ធ្វើឱ្យមានភាពរញ៉េរញ៉ៃពេលដេញថ្លៃ ដោយអ្នកទទួលការមួយចំនួនបានកក់ប្រាក់តិចតួច តែគាត់មិនដេញថ្លៃទេគ្រាន់តែកាន់លិខិតកក់ប្រាក់មកបង្ហាញ ដើម្បីទារយកទឹកតែពីអ្នកទទួលការដែលចូលរួមដេញ។
- ✓ មានអ្នកទទួលការខ្លះចេញ**លិខិតផ្ទេរសិទ្ធ**២-៣ច្បាប់នៅកន្លែងដេញថ្លៃតែមួយឱ្យបងប្អូន ឬមិត្តភ័ក្តិកាន់ដើម្បីបង្ហាញគេយកទឹកតែ។
- ✓ ខេត្តមួយចំនួនបរិយាកាសមុនពេលដាក់ និងទទួលសំណើដេញថ្លៃនៅខាងមុខអគារប្រជុំដេញថ្លៃ មានភាពរញ៉េរញ៉ៃ អ៊ូអរដោយសារអ្នកដេញថ្លៃមិនបានចូលមកអង្គុយក្នុងសាលប្រជុំដេញថ្លៃ ទោះជាអ្នកសម្របសម្រួលឬ មេឃុំហៅចូលច្រើនដងក៏ដោយ។ អ្នកដេញថ្លៃនៅជជែកតថ្លៃគ្នា ទៅវិញទៅមកនៅខាងក្រៅសាលប្រជុំដេញថ្លៃ បង្កឱ្យការដេញថ្លៃគ្មានសណ្តាប់ធ្នាប់។

☞ បញ្ហាខ្លះៗ ក្នុងពេលអនុវត្តគម្រោង

- ✓ ការគ្រប់គ្រងលិខិតប្រាក់កក់ធានាការអនុវត្តរបស់ម្ចាស់គម្រោង មិនបានត្រឹមត្រូវតាមការកំណត់នៅចំណុច ទី៦នៃទម្រង់ទី៥០ «កិច្ចសន្យាការងារសាងសង់»។ ឧទាហរណ៍: ឱ្យអ្នកទទួលការបានដកយកច្បាប់ដើមបាត់ ទុកតែច្បាប់ថតចម្លង ឬលិខិតប្រាក់កក់ខ្លះហួសសុពលភាពប្រើប្រាស់រក្សាទុកនៅសាលាឃុំ សង្កាត់ ឬករណីខ្លះបាត់រកមិនឃើញនៅសាលាឃុំ សង្កាត់។
- ✓ ការតម្រូវឱ្យអ្នកទទួលការដាក់ប្រាក់កក់ធានាការដេញថ្លៃ ២% និងធានាការអនុវត្ត ១០% ហាក់មានប្រសិទ្ធភាពតិចតួច ដោយម្ចាស់គម្រោងមិនបានយល់ ឬមិនយកចិត្តទុកដាក់រក្សាទុក និងពិនិត្យសុពលភាពនៃលិខិតទាំងនោះ។
- ✓ គម្រោងមួយចំនួនអ្នកទទួលការ មិនបានអនុវត្តត្រឹមត្រូវតាមលទ្ធផលដែលមានបរិយាយក្នុងកិច្ចសន្យា ឧទាហរណ៍ ខ្វះបណ្តោយ ខ្វះទទឹងផ្លូវ និងការកិនបង្ហាប់ដី ឬក្រួសក្រហមមិនគ្រប់តាមស្តង់ដារកំណត់។
- ✓ ខេត្តមួយចំនួនខ្វះឧបករណ៍ DCP និងឧបករណ៍តេស្តបេតុងសម្រាប់ត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដើម្បីពង្រឹងគុណភាពនៃការអនុវត្ត។
- ✓ អ្នកទទួលការមួយចំនួនមានការត្អូញត្អែរថា ពេលដែលគាត់ខំព្យាយាមអនុវត្តគម្រោងចប់ រតនាគារពុំមានថវិកាគ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់ឱ្យគាត់បានទាន់ពេលវេលា។
- ✓ អ្នកទទួលការមួយចំនួនទទួលបានគម្រោងច្រើន តែមានគ្រឿងចក្រតិច ដែលជាហេតុធ្វើឱ្យការងារអនុ-វត្តកិច្ចសន្យាគម្រោងមានការយឺតយ៉ាវ។

☞ បញ្ហាជួបប្រទះក្នុងការចុះតាមដានការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់របស់ក្រុមការងារថ្នាក់ជាតិ

- ✓ សមាជិកក្រុមការងារសម្រាប់គាំទ្រ និងត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ដែលបានរៀបចំបណ្តុះបណ្តាលហើយមានការផ្លាស់ប្តូរការិយាល័យទៅមក ខ្លះបម្រើការងារនៅកន្លែងផ្សេង។ គួររៀបចំពង្រឹងសមាជិកក្រុម និងជ្រើសរើសយកអ្នកដែលមានចំណាប់អារម្មណ៍ក្នុងការងារនេះ។
- ✓ ការអនុវត្តសេចក្តីណែនាំលេខ០០១ សណន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ហាក់មិនទាន់ពេញលេញ តាមនីតិវិធីព្រោះក្រុមការងារធ្វើបានជំហានទី១ ទី២ និងទី៣ តែជំហានទី៤ ធ្វើបានតែពាក់កណ្តាល (បានតែរៀបចំរបាយការណ៍ តែមិនបានដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច) និងជំហានទី៥ មិនទាន់បានធ្វើនៅឡើយ។ គួរដាក់របាយការណ៍ដែលក្រុមការងារបានរៀបចំជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច និងថតចម្លងរបាយការណ៍នេះ ផ្តល់ជូនរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់សាមីដើម្បីដោះស្រាយ និងកែលម្អ (ធ្វើដូចនេះទើបក្រុមការងារដែលចុះត្រួតពិនិត្យគម្រោងមានប្រសិទ្ធិភាពទៅថ្ងៃមុខ)។

## ៣.២.៦. អនុសាសន៍ក្នុងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

- លេខាធិការដ្ឋាន គ.ជ.អ.ប ឬនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ជួយស្នើសុំទិញឧបករណ៍វាស់ស្ទង់ ក្តារមៀរ ខ្សែម៉ែត្រ ឧបករណ៍ឌីស៊ីភី និងឧបករណ៍ GPS ឱ្យរាជធានី ខេត្តដើម្បីអនុវត្តគម្រោងបានលឿន និងស្របតាមតម្រូវការខាងបច្ចេកទេស។
- គួរមានវគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះបច្ចេកទេសនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធដែលបានផ្លាស់ប្តូរ ឬអ្នកដែលគ្មានជំនាញបច្ចេកទេសសោះ និងអ្នកថ្មីសុទ្ធ

- បង្កើនការត្រួតពិនិត្យគម្រោង ដោយបន្ថែមនូវថវិកាឱ្យបានច្រើនបន្តិចសម្រាប់ចុះតាមដានការអនុវត្តគម្រោងនៅថ្នាក់ក្រោមជាតិនៅឆ្នាំ២០១៨
- ពន្យល់ដល់ម្ចាស់គម្រោងឱ្យយល់ពីសារៈសំខាន់នៃលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ២% និងលិខិតធានាប្រាក់កក់ធានាការអនុវត្ត១០% យកចិត្តទុកដាក់រក្សាទុក និងពិនិត្យសុពលភាពនៃលិខិត
- គួរជូនដំណឹងទៅរាជធានី ខេត្តថាត្រូវទំនាក់ទំនងមកអ្នកណានៅថ្នាក់ជាតិដើម្បីជួយដោះស្រាយក្នុងការបញ្ចូលទិន្នន័យគម្រោង ឬការកែសម្រួលពេល PID មានបញ្ហា និងសុំជួយកែសម្រួលក្នុងប្រព័ន្ធ PID ផងចំពោះរូបមន្តបង់ពន្ធថ្មីរបស់ពន្ធដារ។
- លិខិតប្រាក់កក់ធានាការដេញថ្លៃគួរស្មើ២%នៃតម្លៃប៉ាន់ស្មាន ហើយដាក់នៅក្រៅស្រោមសំបុត្រសំណើដេញថ្លៃ និងត្រូវបង្ហាញលិខិត ប្រាក់កក់ធានាការដេញថ្លៃនេះទើបចូលដេញថ្លៃបាន
- តម្រូវឱ្យអ្នកទទួលការដែលមានបំណងដេញថ្លៃចូលអង្គុយស្តាប់ការណែនាំរបស់គណៈកម្មការលទ្ធកម្ម បើអ្នកទទួលការណាមិនចូលស្តាប់ មិនអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃទេ
- មិនគួរអនុញ្ញាតឱ្យបន្តលទ្ធផលគម្រោងដែលមានតម្លៃឯកតាដេញថ្លៃលើសពីតម្លៃឯកតាប៉ាន់ស្មានទេ ព្រោះតម្លៃប៉ាន់ស្មានត្រូវបានគណនាតាមគំនូសប្លង់បច្ចេកទេស និងបទដ្ឋានបច្ចេកទេសត្រឹមត្រូវ
- ការកែសម្រួលកិច្ចសន្យាគួរមានកំណត់ចំនួនដងឱ្យបានច្បាស់លាស់ តែ១ឬ២ដងប៉ុណ្ណោះ ជាទូទៅអ្នកទទួលការតែងតែមិនអនុវត្តតាមផែនការសាងសង់ ហើយកែសម្រួលកិច្ចសន្យាជាញឹកញាប់ ធ្វើឱ្យការអនុវត្តន៍កិច្ចសន្យាមានការយឺតយ៉ាវ និងឆ្លងឆ្នាំ
- សូមបន្ថែមគំនូសប្លង់សំណង់ធារាសាស្ត្រដូចជាលូមូល លូជ្រុងសម្រាប់ឆ្លងកាត់ប្រឡាយ សំណង់ទ្វារទឹកដែលមានឧបករណ៍លើកដាក់ទ្វារទឹក សំណង់បង្ហៀរបេតុង និងសំណង់ស្ទាក់ទឹកតូចៗតាមប្រឡាយ។

# ៤. គាំទ្រដល់ដំណើរការរៀបចំគម្រោងមូលនិធិក្រុង ស្រុក

## ៤.១. ប្រវត្តិនៃមូលនិធិក្រុង ស្រុក

មូលនិធិក្រុង ស្រុកបានបង្កើតឡើងតាមអនុក្រឹត្យលេខ៣៦ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២។ នៅឆ្នាំ ២០១៤ លិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ជម្រើសដល់ការអនុវត្តមូលនិធិនេះត្រូវបានរៀបចំ និងបានដាក់ឱ្យអនុវត្ត ដោយគិតត្រឹមខែមេសា ឆ្នាំ២០១៤ រដ្ឋបាលក្រុង ស្រុកទាំងអស់បានទទួលនូវការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពលើវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក។ ទន្ទឹមនឹងនេះគណកម្មការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរដ្ឋបាលក្រុង ស្រុកត្រូវបានបង្កើតនៅគ្រប់រដ្ឋបាលក្រុង ស្រុកទាំងអស់។ សេចក្តី-ព្រាងអនុក្រឹត្យស្តីពីការចូលរួមធនធានពីថវិការជ្ជទៅក្នុងមូលនិធិក្រុង ស្រុកសម្រាប់រយៈពេលប្រាំឆ្នាំ ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៩ ត្រូវបានរៀបចំ ដោយអត្រាចូលរួមធនធានពីថវិការជ្ជទៅក្នុងមូលនិធិក្រុង ស្រុកនឹងមានអត្រាកំណើនពី ០,៨០% នៃចំណូលចរន្តថវិការជ្ជនៅឆ្នាំ២០១៥ ដល់១%នៅឆ្នាំ២០១៩ (*ស្រង់ចេញពីសៀវភៅផែនការអនុវត្តបីឆ្នាំដំណាក់កាលទីពីរ ២០១៥-២០១៧ នៃគ.ជ.អ.ប ទំព័រ១០៨*)។

## ៤.២. ប្រភពមូលនិធិក្រុង ស្រុក

យោងតាមបទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់ គ.ជ.អ.ប នៅសាលប្រជុំក្រសួងមហាផ្ទៃ ថ្ងៃទី២៤-២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ បានបង្ហាញឱ្យដឹងថារាជរដ្ឋាភិបាលកម្ពុជាបានផ្ទេរថវិការជ្ជទៅគណនីមូលនិធិក្រុង ស្រុកក្នុងកម្រិត

១% ចាប់ពីឆ្នាំ២០១៧ តទៅ នៃចំណូលចរន្តថវិការដ្ឋដែលបានអនុម័តឆ្នាំមុន (អនុក្រឹត្យ ៣៤២)។ យោងតាមបទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសិក្ខាសាលាជាតិស្ដីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ « រាជរដ្ឋាភិបាលកម្ពុជានឹងពិចារណាបង្កើនកម្រិតអត្រាវិភាជន៍មូលនិធិក្រុង ស្រុកពី១% ទៅ ១.៣៤% នៃចំណូលចរន្តថវិការដ្ឋចាប់ពីឆ្នាំ២០១៨ តទៅ»។

☞ មូលនិធិក្រុង ស្រុកសម្រាប់ឆ្នាំ២០១៧ត្រូវបានវិភាជន៍ និងជូនដំណឹងដល់ក្រុង ស្រុកជាពីរសមាសភាគ៖

- ✓ សមាសភាគសម្រាប់រដ្ឋបាល (៧១,៤២%)
- ✓ សមាសភាគសម្រាប់អភិវឌ្ឍន៍ (២៨,៥៨%)

☞ **មូលនិធិក្រុង ស្រុកត្រូវអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក និងបញ្ជាក់អនុលោមភាពដោយអភិបាលខេត្ត។**

**មូលនិធិក្រុង ស្រុក** គឺជាមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ។ នៅឆ្នាំ២០១៧ មូលនិធិនេះមានធនធានសរុបប្រមាណ ១៣៤,០៧៣លានរៀល ឬប្រមាណ៣៣.១០លានដុល្លារ។

☞ ក្រុង ស្រុកនីមួយៗបានទទួលមូលនិធិ៖

- ✓ មធ្យមចំនួន ១៧៨,៩៤៣ដុល្លារ
- ✓ អតិបរមាចំនួន ២៨០,០២៧ដុល្លារ
- ✓ អប្បបរមាចំនួន ១០០,៦៣៧ដុល្លារ

រដ្ឋបាលក្រុង ស្រុកត្រូវចំណាយលើបន្ទុកបុគ្គលិក៦២.៣៥% នៃមូលនិធិសរុបប្រចាំឆ្នាំ។

☞ធនធាននៃសមាសភាគទាំងពីរនៃមូលនិធិក្រុង ស្រុកត្រូវបានបែងចែកទៅតាមរដ្ឋបាលក្រុង ស្រុកនីមួយៗស្របតាមវិធានដូចខាងក្រោម៖

| **ធនធានសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាល** | **ធនធាននៃសមាសភាគសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន** |
|---|---|
| ៤០% សម្រាប់ចំណែកស្មើ | ៤០% សម្រាប់ចំណែកស្មើ |
| ២០% សម្រាប់ចំនួនសមាជិកក្រុមប្រឹក្សាក្រុង ស្រុក | ២០% សម្រាប់ចំនួនប្រជាពលរដ្ឋក្នុងក្រុង ស្រុក |
| ២០% សម្រាប់ចំនួនគណៈអភិបាល | ២០% សម្រាប់សន្ទស្សន៍ភាពក្រីក្រ |
| ២០% សម្រាប់មន្ត្រីបុគ្គលិកសរុប | ២០% សម្រាប់ចំនួនឃុំ សង្កាត់ក្នុងក្រុង ស្រុក |

ប្រភព: អនុក្រឹត្យលេខ៣៤២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក

តារាងខាងក្រោមជាការវិភាជន៍មូលនិធិក្រុង ស្រុករយៈពេល៦ឆ្នាំ(២០១២-២០១៧) ឯកតាជា លានរៀល

| ឆ្នាំ | %នៃ ចំណូលចរន្ត | សមាសភាគរដ្ឋបាល | | សមាសភាគអភិវឌ្ឍន៍ | | សរុបមូលនិធិ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | %កំណើន | ចំនួន | %កំណើន | ចំនួន | %កំណើន |
| 2012 | | 46,651.00 | | 9,969.80 | | 56,620.80 | |
| 2013 | 0.8% | 43,523.46 | -6.70% | 14,881.94 | 49.27% | 58,405.40 | 3.15% |
| 2014 | 0.8% | 51,199.87 | 17.64% | 16,590.13 | 11.48% | 67,790.00 | 16.07% |
| 2015 | 0.8% | 58,715.84 | 14.68% | 18,985.16 | 14.44% | 77,701.00 | 14.62% |
| 2016 | 0.9% | 73,867.00 | 25.80% | 25,265.00 | 33.08% | 99,132.00 | 27.58% |
| 2017 | 1.00% | **95,761.00** | 29.64% | **38,312.00** | 51.64% | **134,073.00** | 35.25% |
| **សរុប** | | **369,718.17** | | **124,004.03** | | **493,722.20** | |




ប្រភព៖ បទបង្ហាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់ គ.ជ.អ.ប នៅក្រសួងមហាផ្ទៃ ថ្ងៃទី២៤-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

## ៤.៣. ការអនុវត្តគម្រោងក្រុង ស្រុក

ការអនុវត្តគម្រោងក្រុង ស្រុកជាទូទៅបានបែងចែកជាបីដំណាក់កាលគឺ**ការរៀបចំគម្រោង ការធ្វើលទ្ធកម្មគម្រោង និងការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង។** ការអនុវត្តគម្រោងក្រុង ស្រុកដល់បច្ចុប្បន្ននេះនៅមិនទាន់បានរលូន និងតាមនីតិវិធីនៅឡើយទេ ដោយនៅដំណាក់កាលការរៀបចំគម្រោងជាការជួយគាំទ្រដោយក្រសួងមហាផ្ទៃ តែការធ្វើលទ្ធកម្មគម្រោង និងការតាមដានត្រួតពិនិត្យការអនុវត្តគម្រោងគាំទ្រដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៤.៣.១. ការរៀបចំគម្រោងក្រុង ស្រុក ដោយប្រើប្រាស់មូលនិធិរាជរដ្ឋាភិបាលឆ្នាំ២០១៧

ការរៀបចំគម្រោងអនុវត្តតាម **សៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង** ស្រុករបស់គណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើប្រាស់តាមសេចក្តីសម្រេចលេខៈ ០៥៣សសរ/គ.ជ.អ.ប ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣។ ការរៀបចំគម្រោងនេះទោះមានការលំបាកយ៉ាងណាក៏ខេត្តទាំង២៤ និងរាជធានីបានប្រឹងប្រែងរៀបចំ ដោយមានការសហការពីម្ចាស់គម្រោង ក្រោមការជួយគាំទ្រពីទីចាត់ការផែនការ និងវិនិយោគ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ (TSO) និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត តែក្រុង ស្រុកខ្លះមិនបានសហការទេ គាត់ធ្វើតាមតែការណែនាំពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តារាងខាងក្រោមជាលទ្ធផលនៃការរៀបចំគម្រោងក្រុង ស្រុកត្រឹមពាក់កណ្តាលខែធ្នូ ឆ្នាំ២០១៧៖

| ការបរិយាយ | ចំនួនគម្រោង | គិតជា% | ផ្សេងៗ |
|---|---|---|---|
| បានចុះកិច្ចសន្យា | ១៩៦ | ៦០% | គម្រោងដែលលើកឡើងសរុបមាន៣២៦ គម្រោង។ នៅដំណាក់កាលអនុវត្តយើងមិនបានតាមដាន ឬដឹងនោះទេ។ |
| បានបញ្ចប់ការសិក្សា | ៥៧ | ១៧% | |
| កំពង់ដំណើរការសិក្សា | ៦៥ | ២១% | |
| មិនទាន់បានសិក្សា | ៨ | ២% | |

ក្រាហ្វិកខាងក្រោមបង្ហាញពីវឌ្ឍនភាពនៃការរៀបចំគម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៧ តាមរាជធានី ខេត្ត

**វឌ្ឍនភាពនៃការរៀបចំគម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧**

| Province GIS Code | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | ផ្ទៀងផ្ទាត់ | គិតជា | ចំនួនគម្រោង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Province Abr | BMC | BAT | KPC | KCH | KSP | KPT | KAM | KDL | KKG | KRT | MKR | PNP | PVR | PVG | PUR | RAT | SRP | SHV | STG | SVR | TAK | OMC | KEP | PLN | TKM | Verify | % | |
| MDF Project Plann in 2017 | 22 | 26 | 22 | 15 | 12 | 9 | 19 | 14 | 11 | 6 | 5 | 29 | 8 | 13 | 11 | 12 | 26 | 7 | 5 | 20 | 10 | 9 | 3 | 2 | 10 | 326 | 100% | 326 |
| Not Yet Study | 0 | 0 | 0 | 1 | 0 | 2 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 8 | 2% | 8 |
| Under Feasibility study/design | 0 | 0 | 1 | 0 | 0 | 4 | 2 | 0 | 0 | 4 | 0 | 29 | 8 | 0 | 1 | 0 | 0 | 7 | 5 | 2 | 0 | 0 | 1 | 0 | 1 | 65 | 20% | 65 |
| Ready for bidding and ann. | 22 | 26 | 21 | 14 | 12 | 3 | 14 | 14 | 11 | 2 | 5 | 0 | 0 | 13 | 10 | 12 | 26 | 0 | 0 | 18 | 10 | 9 | 0 | 2 | 9 | 253 | 17% | 57 |
| Contract signed/impl | 18 | 24 | 21 | 11 | 12 | 0 | 0 | 14 | 9 | 2 | 5 | 0 | 0 | 0 | 10 | 7 | 24 | 0 | 3 | 16 | 0 | 9 | 0 | 2 | 9 | 196 | 60% | 196 |

**សម្គាល់៖** ការរៀបចំគម្រោងក្រុង ស្រុក បានដំណើរដោយលំបាកសម្របសម្រួល និងលាក់លៀមក្នុងការផ្តល់ព័ត៌មានពីវឌ្ឍនភាពនៃគម្រោង។




## ៤.៣.២. ការធ្វើលទ្ធកម្មគម្រោង

ការធ្វើលទ្ធកម្មគម្រោងអនុវត្តតាម **លទ្ធកម្មសាធារណៈ** និងលិខិតបទដ្ឋានមួយចំនួនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលចេញការណែនាំដាច់ដាក់ង់ៗដល់ថ្នាក់ក្រោមជាតិ និងរដ្ឋបាលក្រុង ស្រុក ឧទាហរណ៍ដូចជា៖

- សារាចរណែនាំលេខ០០២ សហវ. អលសា ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤
- សេចក្តីណែនាំលេខ០០២ សហវ. អលសា ស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤
- លិខិតលេខ ៨៥៦១សហវ គោរពជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប ករណីស្តីពីការជំរុញ និងពង្រឹងការរៀបចំ ការអនុវត្តថវិកា និងការរៀបចំ និងអនុវត្តគម្រោងក្រុង ស្រុកឆ្នាំ២០១៤ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤
- លិខិតលេខ ៦៥៥២ សហវ អហក ជម្រាបជូនលោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ស្តីពីការបញ្ជាក់បន្ថែមអំពីការប្រើប្រាស់ថវិកាដែលគាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអ៊ែត (SIDA) ចំពោះគម្រោងអភិវឌ្ឍន៍ក្រុង ស្រុកចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១៥។
- លិខិតលេខ ៩២៥៩ សហវ ជម្រាបជូនលោក លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជ-ធានី ខេត្តស្តីពីការសម្របសម្រួលដំណើរការអនុវត្តនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុកសម្រាប់ដំណាច់ឆ្នាំ២០១៥ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥។
- ឯកសារផ្សេងៗទៀត។ល។

#### ៤.៣.៣. ការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង

ការតាមដានការអនុវត្តគម្រោងមានភាពមិនច្បាស់លាស់រហូតដល់បច្ចុប្បន្ននេះ ពីព្រោះទីចាត់ការផែនការ និងវិនិយោគ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ (TSO) និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត (PIA) មិនមានឈ្មោះ និងតួនាទីទៀតទេក្រោយពីរៀបចំសំណើគម្រោងចប់។ តាមបទបង្ហាញមួយបានសរសេរថា៖

- រដ្ឋបាលក្រុង ស្រុកត្រូវប្រើប្រាស់តួនាទីរបស់គណៈកម្មាធិការលទ្ធកម្មដើម្បីតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោងក្រុង ស្រុក ដោយមានចូលរួមរបស់អ្នកទទួលផល។
- កំណត់ហេតុនៃការតាមដាន និងត្រួតពិនិត្យគម្រោងនឹងត្រូវរៀបចំឡើង ដើម្បីជាយន្តការក្នុងដំណើរការទូទាត់។

### ៤. ៤ បញ្ហាចម្បងខ្លះៗក្នុងការអនុវត្តគម្រោងក្រុង ស្រុក

បញ្ហាខាងក្រោមនេះជាការលើកឡើងពីក្រុមការងារផអ៣ នៅតាមបណ្តាខេត្តទាំងអស់ដែលបានជួបប្រទះ ពេលរៀបចំសំណើគម្រោង ការធ្វើលទ្ធកម្មគម្រោង និងការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង។

#### ៤.៤.១. ការរៀបចំសំណើគម្រោងក្រុង ស្រុក

ខាងក្រោមនេះជាបញ្ហាខ្លះៗដែលកើតឡើងនៅពេលរៀបចំសំណើគម្រោងក្រុង ស្រុក៖

- ក្រុង ស្រុកខ្លះមិនចង់តែងតាំងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធធ្វើជាអ្នកជំនួយបច្ចេកទេសទេ និងស្រុកខ្លះទៀតមានការយឺតយ៉ាវក្នុងការរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង និងការតែងតាំង ឬស្នើសុំអ្នកជំនួយបច្ចេកទេសដើម្បីជួយសិក្សាគម្រោង។
- ក្រុង ស្រុកមួយចំនួនធំហាក់ដូចជាមិនទាន់យល់ច្បាស់ពីនីតិវិធីនៃការរៀបចំគម្រោងក្រុង ស្រុក ដោយមិនមានការឯកភាពគ្នាក្នុងការសម្រេចប្រើមូលនិធិនេះ ដោយក្រុង ស្រុកខ្លះចង់ប្រើមូលនិធិនេះលើគម្រោងបម្រើឱ្យហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុកដូចជា៖ ជួសជុលអគារ ផ្លូវក្នុងសាលាស្រុក ឬសួនច្បារក្នុងបរិវេណសាលាស្រុក និងក្រុង ស្រុកខ្លះប្រើសាងសង់សំណង់សាធារណៈ។
- មានក្រុង ស្រុកខ្លះមិនបានអនុវត្តទៅតាមសៀវភៅណែនាំទេចំពោះការប្រើប្រាស់ថវិការរដ្ឋាភិបាលតែសម្រាប់ថវិកាស៊ីដា ក្រុង ស្រុករៀបចំគម្រោងតាមនីតិវិធី និងសៀវភៅណែនាំ។
- ខេត្តខ្លះតម្រូវឱ្យអ្នកជំនួយបច្ចេកទេសរៀបចំជាតារាងប៉ាន់ស្មានតម្លៃ បន្ថែមពីតារាងប៉ាន់ស្មានតម្លៃដែលមានក្នុងសៀវភៅស្តីពីការរៀបចំគម្រោងក្រុង ស្រុកក្នុងឆ្នាំ២០១៣ រួមទាំងមានភាពមិនទាន់ច្បាស់លាស់ពីការដាក់បញ្ចូលថវិកាសម្រាប់សិក្សាគម្រោងក្នុងឧបសម្ព័ន្ធទី៤ (បញ្ជីប៉ាន់តម្លៃសរុប)
- គម្រោងមួយចំនួនដែលលើកឡើងដោយក្រុង ស្រុកមិនមានគំនូសប្លង់បច្ចេកទេស និងតារាងប៉ាន់ស្មានតម្លៃលម្អិតក្នុង NCDD Template របស់ គ.ជ.អ.ប ដែលជាបញ្ហាលំបាកដល់អ្នកជំនួយបច្ចេកទេសមិនអាចជួយសិក្សាបាន ហើយការងារនេះធ្លាក់បន្ទុកមកលើទីប្រឹក្សា PIA ត្រូវតែជួយសិក្សា ដែលកិច្ចការនេះត្រូវចំណាយពេលច្រើនក្នុងការគូរប្លង់ និងសិក្សាតម្លៃលម្អិត។
- នីតិវិធី ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ណែនាំដល់ក្រុង ស្រុកក្នុងការរៀបចំគម្រោងមិនស្របតាមសៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុងស្រុក ធ្វើឱ្យមានការលំបាក។
- ខេត្តមួយចំនួនការអនុវត្តគម្រោងក្រុង ស្រុកដែលប្រើប្រាស់ថវិការដ្ឋមិនបានឆ្លងកាត់ទីចាត់ការផែនការ និងវិនិយោគដើម្បីធ្វើការត្រួតពិនិត្យដូចក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង

ក្រុងស្រុកទេ ហើយក្រុង ស្រុកនៅតែអាចទូទាត់ថវិកាបានធម្មតា។ ដោយហេតុថាមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យតែលើដំណើរការនៃកិច្ចលទ្ធកម្មតែប៉ុណ្ណោះហើយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏មិនបានដឹងស៊ីជម្រៅអំពីសៀវភៅអនុវត្តគម្រោងនេះដែរ។

### ៤.៤.២. ការធ្វើលទ្ធកម្មគម្រោង

- គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុកមិនទាន់យល់ច្បាស់ពីនីតិវិធីលទ្ធកម្មសាធារណៈដែលសព្វថ្ងៃនៅពឹងផ្អែកលើមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តជាអ្នកចាត់ចែង
- ការប្រើប្រាស់ទម្រង់ប៉ាន់ស្មានតម្លៃលម្អិតដែលមាននៅក្នុងសៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុក ដែលមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធបានជួយសិក្សា និងរៀបចំហើយ មិនអាចប្រើជាឯកសារដេញថ្លៃបាននៅឡើយទេ ដោយសៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុកណែនាំឱ្យរៀបចំតាមទម្រង់ទី៩ សម្រាប់ប៉ាន់ស្មានតម្លៃសម្រាប់សំណង់ និងទម្រង់ទី១០ សម្រាប់ការងារដី តែការណែនាំពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតាមឯកសារលទ្ធកម្មសាធាណៈឱ្យរៀប-ចំតាមឧបសម្ព័ន្ធទី៤ ដែលមាន (១)បញ្ជីប៉ាន់ស្មានសរុប (២)បញ្ជីលេខ១ បញ្ជីប៉ាន់តម្លៃពលកម្ម និង(៣)បញ្ជីលេខ២ បញ្ជីប៉ាន់តម្លៃសម្ភារ។
- ក្រោយការរៀបចំគម្រោងបានបញ្ចប់ក្រុង ស្រុកភាគច្រើនមិនបានឱ្យមន្ត្រីបច្ចេកទេសហេដ្ឋា-រចនាសម្ព័ន្ធចូលរួមបន្តទៀតទេ ចំពោះការងារលទ្ធកម្ម និងការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង ហើយទីចាត់ការផែនការ និងវិនិយោគខេត្តក៏មិនបានដឹងជាផ្លូវការទាក់ទងនឹងការធ្វើលទ្ធកម្ម និងការអនុវត្តគម្រោងដែរ។

### ៤.៤.៣. ការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង

ជាទូទៅមន្ត្រីទីចាត់ការផែនការ និងវិនិយោគ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ និងទីប្រឹក្សាហេដ្ឋា-រចនាសម្ព័ន្ធខេត្តមិនបានដឹងពីការអនុវត្តគម្រោងក្រុង ស្រុករបស់អ្នកទទួលការឡើយ បានជួយត្រឹមតែការសិក្សាលទ្ធភាព និងរៀបចំព័ត៌មានគម្រោងប៉ុណ្ណោះ។ ខាងក្រោមនេះជាបញ្ហាខ្លះៗលើកឡើងដោយក្រុមការងារផអ៣ យើងក្នុងការការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង៖

- ដោយសារនីតិវិធីនៃការគាំទ្របានត្រឹមតែរៀបចំគម្រោងចប់ ដូចនេះចាប់ពីលទ្ធកម្មទៅគឺគណកម្ម-ការគ្រប់គ្រងគម្រោងក្រុង ស្រុកលែងមានទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធពីមុនៗហើយ។ ដូច្នេះការតាមដានត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក គណៈកម្មាការគ្រប់គ្រងគម្រោងមិនបានអញ្ជើញទីចាត់ការផែនការ និងវិនិយោគខេត្ត ឬមន្ត្រីបច្ចេកទេសចូលរួមតាមដានត្រួតពិនិត្យការអនុវត្តគម្រោងទេ។
- តាមការសង្កេតជាក់ស្តែងក្រុង ស្រុកមួយចំនួនពេលគម្រោងបានអនុវត្តចប់១០០% ពុំបានឱ្យអ្នកត្រួតពិនិត្យបច្ចេកទេសចុះពិនិត្យធ្វើតេស្ត និងវាយតម្លៃជាមុនទេ រួចធ្វើការទូទាត់ថវិកាឱ្យអ្នកទទួលការតែម្តង។

## ៤.៥. អនុសាសន៍ និងដំណោះស្រាយ

ដើម្បីឱ្យគម្រោងក្រុង ស្រុកអនុវត្តទៅដោយរលូន ក្រសួងមហាផ្ទៃ ដែលមាននាយកដ្ឋានកិច្ចការរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរពិភាក្សាបន្ទាប់បញ្ចូលគ្នាឡើងវិញនូវសៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុកដែលបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៣ដោយក្រសួងមហាផ្ទៃ និងនីតិវិធីធ្វើលទ្ធកម្មសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យចេញជាសៀវភៅណែនាំតែមួយដើម្បីអនុវត្តនៅថ្នាក់ក្រោមជាតិទាំងអស់គ្នា។ បន្ទាប់មក គ.ជ.អ.ប គួររៀបចំឱ្យមានវគ្គបណ្តុះ-បណ្តាលដល់មន្ត្រីសាលាខេត្ត ក្រុង ស្រុកពីសៀវភៅណែនាំថ្មីនេះដោយមានការចូលរួមសម្របសម្រួលពីមន្ត្រីក្រសួងមហាផ្ទៃ និងមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ខាងក្រោមនេះជាអនុសាសន៍ខ្លះៗលើកឡើងដោយក្រុមការងារផអ៣ទី២យើងក្នុងការអនុវត្តគម្រោងក្រុង ស្រុកៈ

### ៤.៥.១. ការរៀបចំសំណើគម្រោងក្រុង ស្រុក

- មូលនិធិក្រុង ស្រុកគួរទម្លាក់/ផ្ទេរមកក្រុង ស្រុកដូចមូលនិធិឃុំ សង្កាត់ ដើម្បីមានភាពងាយស្រួលដល់អ្នកជំនួយបច្ចេកទេសបានដឹងឆាប់ និងជួយសិក្សាបានលឿន ក៏ដូចជាបង្កភាពងាយស្រួលក្នុងការទូទាត់ជូនអ្នកទទួលការបន្ទាប់ពីការងារសាងសង់បានបញ្ចប់៥០% ឬ១០០%
- ក្រុង ស្រុកត្រូវរួសរាន់រៀបចំបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង និងតែងតាំង ឬស្នើសុំមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធធ្វើជាអ្នកជំនួយបច្ចេកទេសដើម្បីជួយសិក្សាគម្រោង
- ក្រុង ស្រុកត្រូវពន្លឿនការរៀបចំគម្រោងដោយអនុវត្តឱ្យបានត្រឹមត្រូវតាមសៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុក មុននឹងធ្វើកិច្ចលទ្ធកម្មគម្រោង
- អភិបាលក្រុង ស្រុក គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក និងអ្នកពាក់ព័ន្ធត្រូវស្វែងយល់ឱ្យស៊ីជម្រៅអំពីដំណើរការរៀបចំគម្រោងក្រុង ស្រុកបន្ថែមទៀត។

### ៤.៥.២. ការធ្វើលទ្ធកម្មគម្រោង

- សុំឱ្យការប្រកាសដេញថ្លៃគម្រោងមូលនិធិក្រុង ស្រុក បិទផ្សាយឱ្យបានទូលំទូលាយដូចគម្រោងឃុំ សង្កាត់ដែរ (មានផ្សាយតាមគេហទំព័រ គ.ជ.អ.ប និងកាសែតផ្សេងៗ)
- ដំណើរការដេញថ្លៃគម្រោងគួរឱ្យមានមន្ត្រីជំនួយការបច្ចេកទេសដែលតែងតាំងដោយខេត្ត ឬទីប្រឹ-ក្សាហេដ្ឋារចនាសម្ព័ន្ធបានចូលរួមផង ដើម្បីងាយស្រួលក្នុងការជួយគាំទ្រផ្នែកគំនូសប្លង់បច្ចេកទេសពេលអ្នកទទួលការមានការងឿងឆ្ងល់ ឬមិនយល់ពីប្លង់បច្ចេកទេស និងអាចជួយត្រួតពិនិត្យពីដំណើរការលទ្ធកម្មគម្រោងឱ្យមានតម្លាភាពផងដែរ
- សូមឱ្យថ្នាក់ជាតិជួយពង្រឹងដល់អង្គភាពលទ្ធកម្មក្រុង ស្រុកពីនីតិវិធីលទ្ធកម្មសាធារណៈ និងឯកសារផ្សេងៗទាក់ទងនឹងលទ្ធកម្ម។

### ៤.៥.៣. ការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង

- ប្រសិនជាអាចគួរតែឱ្យអ្នកជំនួយបច្ចេកទេស ឬទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្តបានចូលរួមក្នុងពេលអនុវត្តគម្រោងក្រុង ស្រុកផង ដើម្បីជួយត្រួតពិនិត្យ ធ្វើតេស្តលើគុណភាព ពិនិត្យលើលទ្ធផលគម្រោងធៀបនឹងកិច្ចសន្យា និងជួយពង្រឹងនូវគុណភាពនៃការអនុវត្តគម្រោង។

- រាល់គម្រោងមូលនិធិក្រុង ស្រុកពេលចាប់ផ្តើមបើកការដ្ឋានរហូតដល់ការអនុវត្តគម្រោងបញ្ចប់ ៥០% និង១០០% ត្រូវអញ្ជើញអ្នកជំនួយបច្ចេកទេសចូលរួមត្រួតពិនិត្យ និងវាយតម្លៃមុននឹងធ្វើការទូទាត់ជូនអ្នកទទួលការក្នុងដំណាក់កាលនីមួយៗ
- ត្រូវមានប្រព័ន្ធទិន្នន័យ (Database) សម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោងក្រុង ស្រុក ឱ្យបានច្បាស់លាស់ដោយមានការចូលរួមគ្រប់អ្នកពាក់ព័ន្ធ។

របាយការណ៍សង្ខេបនេះបានមកពីឯកសារបទបង្ហាញនានា និងពីក្រុមការងារផអ៣ទី២នៅតាមខេត្ត ពិសេសមន្ត្រីទីចាត់ការផែនការ និងវិនិយោគ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្តដែលបានជួយគាំទ្រក្នុងការអនុវត្តគម្រោងក្រុង ស្រុកកន្លងមកនេះ។

តារាងខាងក្រោមបង្ហាញពីចំនួនគម្រោងក្រុង ស្រុកដែលបានអនុវត្តក្នុងឆ្នាំ២០១៥-២០១៧

| ល.រ | ឆ្នាំ | ចំនួនគម្រោងមូលនិធិក្រុង ស្រុក | កំណត់សម្គាល់ |
|---|---|---|---|
| 1 | 2013 | គ្មានទិន្នន័យ | គម្រោងក្រុង ស្រុកឆ្នាំ២០១៣ និង២០១៤ អនុវត្តតាមការណែនាំ MEF |
| 2 | 2014 | គ្មានទិន្នន័យ | |
| 3 | 2015 | 454 | ២៦៨ គម្រោងថវិការដ្ឋ និង១៨៦គម្រោងថវិកា SIDA |
| 4 | 2016 | 291 | ថវិការដ្ឋទាំងអស់ |
| 5 | 2017 | 326 | ថវិការដ្ឋទាំងអស់ |
| សរុប | | **1.071** | |

# ៥. គាំទ្រនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត

## ៥.១. ការរៀបចំគម្រោងរាជធានី ខេត្ត

យោងតាមសេចក្តីសម្រេចលេខៈ ០៥៧សសរ/គ.ជ.អ.ប ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ របស់គណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត និងយោងលិខិតលេខៈ២៦៣៧សជណ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការណែនាំឱ្យប្រើប្រាស់សំណុំឯកសារសម្រាប់សំណើគម្រោងរាជធានីខេត្ត ដើម្បីស្នើសុំផ្តល់អនុលោមភាពពីក្រសួងមហាផ្ទៃ។ ក្នុងកិច្ចការរៀបចំគម្រោងរាជធានី ខេត្តទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិមានតួនាទីជាអ្នកផ្តល់នូវចម្លល់ ឬជួយបកស្រាយមួយចំនួនដល់មន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តក្នុងការប្រើប្រាស់សៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្តឱ្យបានត្រឹមត្រូវតាមការណែនាំ។

## ៥.២. រៀបចំបញ្ជីតម្លៃសម្ភារស្តង់ដា

ជួយរៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីតម្លៃសម្ភារស្តង់ដាសម្រាប់ឆ្នាំ២០១៨ ដោយបន្ថែមនូវមុខទំនិញថ្មីមួយចំនួនក្នុងបញ្ជីស្រង់តម្លៃសម្ភារ(ទម្រង់ទី៥) និងបញ្ជីតម្លៃសម្ភារស្តង់ដា(ទម្រង់ទី៦) ដើម្បីធ្វើជូនរដ្ឋបាលរាជធានី ខេត្តអនុវត្ត (បានធ្វើជូនទៅរាជធានី ខេត្តនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧)។ មុខទំនិញថ្មីដែលបាន

បន្ថែមនោះ សម្រាប់ប្រើប្រាស់ក្នុងការរៀបចំគម្រោងរាជធានី ខេត្ត និងក្រុង ស្រុក តែទោះជាយ៉ាងណាក៏នៅតែមិនទាន់បានគ្រប់មុខទំនិញដែរ។ គិតមកដល់ជិតដំណាច់ខែធ្នូ ឆ្នាំ២០១៧នេះ មានតែ១៥រាជធានី ខេត្តទេដែលបានបញ្ចប់ និងអនុម័តពីអភិបាលរាជធានី ខេត្ត ហើយមិនទាន់បានបង្ហោះនៅលើគេហទំព័រ គ.ជ.អ.ប ដោយគេហទំព័រនេះកំពុងតែកែសម្រួល។

## ៥.៣. គាំទ្រលើការងារត្រួតពិនិត្យ និងពង្រឹងសមត្ថភាព

ឆ្នាំ២០១៧ជាឆ្នាំទី៣នៃការអនុវត្តតាមសៀវភៅណែនាំស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិបានជួយធ្វើបទបង្ហាញឆ្លុះបញ្ចាំង និងឆ្លើយសំណួរខ្លះៗកាលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ដែលមន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តប្រមូលបានពេលចុះត្រួតពិនិត្យក្នុងអំឡុងពេល និងក្រោយពេលអនុវត្តគម្រោងអភិវឌ្ឍរាជធានី ខណ្ឌ និងខេត្តឆ្នាំ២០១៦ និងជួយឆ្លើយសំណួរតាមទូរស័ព្ទជាលក្ខណៈប្រយោលពេលក្រុមការងារមានចម្ងល់ក្នុងពេលចុះតាមដានការអនុវត្តគម្រោងរាជធានី ខេត្តជាក់ស្តែង។

# ៦. សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប

## ៦.១. ប្រវត្តិនៃការសហការកែសម្រួលគំនូសប្លង់

ឆ្នាំ២០១៧ជាឆ្នាំទី៤ហើយដែលមានសកម្មភាពសំខាន់ៗបានសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប គឺការកែសម្រួលគំនូសប្លង់បច្ចេកទេស និងតារាងប៉ាន់ស្មានតម្លៃលម្អិតក្នុង NCDD Template។ គំនូសប្លង់បច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ និងតារាងប៉ាន់ស្មានតម្លៃលម្អិតឬហៅថា NCDD Template ដែលប្រើបច្ចុប្បន្នគឺជាមរតកនៃកម្មវិធីសិលា និងបន្ទាប់មកបានកែតម្រូវបន្ថែមដោយក្រុមហ៊ុនអារុណានៅឆ្នាំ២០០៩។

គំនូសប្លង់មួយចំនួននៅក្នុង NCDD Template ដែលគ្រោងឡើងដោយក្រុមហ៊ុនអារុណា ដូចជាសំណង់លូទោល លូភ្លោះ លូជ្រុង អគារសិក្សាធ្វើអំពីឥដ្ឋ និងផ្លូវថ្នល់ ផ្លូវបេតុងជាដើម ការគ្រោងប្លង់ និងការគណនាមានកំហុសជាលក្ខណៈបច្ចេកទេសមួយចំនួនតូចដែលតម្រូវឱ្យធ្វើការកែសម្រួល ដោយការបង្កើនភាពធន់នៃការសាងសង់សំណង់ដែលមិនចាំបាច់មួយចំនួនបង្ករឱ្យមានការកើនឡើងនូវតម្លៃគម្រោងក្នុងការគណនាក្នុងតារាងប៉ាន់ស្មានតម្លៃលម្អិតដែលធ្វើឱ្យខាតបង់នូវថវិការបស់ឃុំ សង្កាត់ ក្រុង ស្រុក និងយោងតាមរយៈនៃការសិក្សារបស់ទីប្រឹក្សាជំនាញលោក Hans Van Kampen on Technical Audit 2010 និងបទពិសោធន៍អនុវត្តគម្រោងកន្លងមករបស់កម្មវិធី គ.ជ.អ.ប សំណង់លូទោល លូភ្លោះ លូជ្រុង ក្នុងកម្មវិធី Seila Template មានលក្ខណៈល្អប្រសើរច្រើន ដោយគ្រាន់តែជាគំនូសប្លង់បច្ចេកទេសងាប់ (មិនអាចកែសម្រួលបន្តិចបន្តួចបានតាមស្ថានភាពជាក់ស្តែងនៅទីតាំងគម្រោងបាន) និងគណនាខ្វះនូវសម្ភារមួយចំនួនដែលទាមទារត្រូវធ្វើការកែសម្រួលបញ្ចូលទៅក្នុង NCDD Template។

ដើម្បីដោះស្រាយ និងជួយសម្រួលបញ្ហាខាងលើអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ខេត្តចំនួន៥រូប និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធកម្មវិធីដាច់ដោយឡែក បានរៀបចំកិច្ចប្រជុំបច្ចេកទេសចំនួន៣ឆ្នាំហើយ គឺនៅឆ្នាំ២០១៤ក្រុមបច្ចេកទេសយើងបានកែសម្រួលសៀវភៅណែនាំស្តីពី បទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ភាគទី២៖ ការបរិយាយលម្អិតលក្ខណៈបច្ចេកទេស និងបានបោះពុម្ពចែកជូនរាជធានី ខេត្តប្រើប្រាស់សព្វថ្ងៃ។

នៅឆ្នាំ២០១៥ក្រុមបច្ចេកទេសយើងបានកែសម្រួល១៥គំនូសប្លង់បច្ចេកទេស និងតារាងប៉ាន់ស្មានតម្លៃ និងនៅឆ្នាំ២០១៦ក្រុមបច្ចេកទេសយើងបានកែសម្រួលលើប្លង់ចាស់ចំនួន៩ និងប្លង់ថ្មីចំនួន៦ទៀត។

## ៦.២. គោលបំណងនៃការកែសម្រួល

- ធ្វើឱ្យប្រសើរឡើងនូវគំនូសប្លង់បច្ចេកទេសគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងតារាងប៉ាន់ស្មានតម្លៃលម្អិតមួយចំនួនក្នុង NCDD Template ដែលទុកចោលមិនប្រើឱ្យវាអាចប្រើបាន និងមានតម្លៃសមរម្យ និងបង្កើតប្លង់ថ្មីឱ្យស្របតាមស្ថានភាពជាក់ស្តែង។
- អាចប្រើប្រាស់បានចំពោះ ៖




## ៦.៣. លទ្ធផលនៃការកែសម្រួលឆ្នាំ២០១៧

ឆ្នាំ២០១៧ ក្រោមកិច្ចសហការជាមួយអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិនៃអគ្គនាយកដ្ឋានរដ្ឋបាល និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់រាជធានី ខេត្ត ចំនួន៤រូប មកពីខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ មណ្ឌលគិរី និងរាជធានីភ្នំពេញ ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធកម្មវិធី ASPIRE ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធគម្រោង SRL ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធគម្រោង DRR បានសហការគ្នាកែសម្រួលគំនូសប្លង់ចំនួន១៥ ក្នុងនោះលទ្ធផលជាប្រភេទ សំណង់កាត់ផ្លូវ សំណង់សិល្បការសម្រាប់ប្រព័ន្ធស្រោចស្រពខ្នាតតូច សំណង់ប្រព័ន្ធបង្ហូរទឹក និងប្រភេទសំណង់សម្រាប់ទឹកជំនន់។

គំនូសប្លង់បច្ចេកទេស និងតារាងប៉ាន់ស្មានតម្លៃលម្អិតបានកែសម្រួលសរុបមាន១៥ ក្នុងនោះកែសម្រួលលើប្លង់ចាស់ចំនួន៦ ប្លង់ថ្មីចំនួន៩ និងបន្តបង្កើយគំនូសប្លង់បច្ចេកទេស និងតារាងប៉ាន់ស្មានតម្លៃលម្អិតសល់ពីឆ្នាំ២០១៦ចំនួន៤ សរុបទាំងអស់១៩គំនូសប្លង់។ លទ្ធផលជារួមដែលទទួលបានបន្ទាប់ពីកិច្ចប្រជុំលើកទី១ លើកទី២និងការធ្វើបន្តរៀងៗខ្លួនដល់ពាក់កណ្តាលខែធ្នូ ឆ្នាំ២០១៧នេះក្រុមការងារបច្ចេកទេសយើងបានរៀបចំគំនូសប្លង់បច្ចេកទេសសម្រេចបាន៨៧% និងតារាងប៉ាន់ស្មានតម្លៃលម្អិតសម្រេចបាន៥0% ការងារនេះយើងខកខានមិនបានរៀបចំធ្វើកិច្ចប្រជុំកែសម្រួលលើកទី៣ទេ ដោយសារមានការផ្លាស់ប្តូរផែនការការងារបន្ទាន់។

| | លេខកូដ | ការពិពណ៌នា | គំនូសប្លង់ | BoQ | សម្គាល់ |
|---|---|---|---|---|---|
| 1 | 1010802 | ផ្លូវបង្ហៀរទឹកដែលមានលូ | 100% | 70% | អាចប្រើបណ្តោះអាសន្នបាន |
| 2 | 1011001 | ចិញ្ចើមផ្លូវដើរ (ការ៉ូឡា បេតុង កៅស៊ូអាស់ស្វាល់) | 100% | 10% | ទើបមានប្លង់ (បីប្លង់) |
| 3 | 1010512 | ស្ពានបេតុង (Use excel drawing) | 100% | 90% | អាចប្រើបាន |

| | | | | | |
|---|---|---|---|---|---|
| 4 | 1020101 | ប្រឡាយដី | 100% | 70% | អាចប្រើបណ្តោះអាសន្នបាន |
| 5 | 1020105 | ប្រឡាយបេតុងរាងចតុកោណកែង | 50% | 20% | អាចប្រើបណ្តោះអាសន្នបាន |
| 6 | 1030401 | ស្រះមិនមានចម្រោះ | 30% | 0% | មិនទាន់បានកែប្លង់ទេ |
| 7 | 1020208 | លូមូលទោល ០,៨ម ឆ្លងកាត់ប្រឡាយ (ថ្មី) | 70% | 0% | មានប្លង់ (មិនទាន់ផ្ញើឱ្យ) |
| 8 | 1020209 | លូមូលទោល ១,០ម ឆ្លងកាត់ប្រឡាយ (ថ្មី) | 100% | 20% | មានប្លង់ (មិនទាន់ឆ្លងបញ្ចប់) |
| 9 | 1020210 | លូមូលភ្លោះ ១,០ម ឆ្លងកាត់ប្រឡាយ (ថ្មី) | 90% | 20% | មានប្លង់ (មិនទាន់ឆ្លងបញ្ចប់) |
| 10 | 1020262 | សំណង់ស្ទាក់ទឹក (ថ្មី) | 90% | 20% | មានប្លង់ (មិនទាន់ឆ្លងបញ្ចប់) |
| 11 | 1010304 | លូមូលកាត់ផ្លូវភ្លោះ ០,៦ម (ថ្មី) | 50% | 0% | ប្លង់ថ្មី ទើបគូសបានខ្លះ |
| 12 | 1020301 | ទំនប់ដី | 100% | 70% | អាចប្រើបណ្តោះអាសន្នបាន |
| 13 | 1110102 | ជើងទេរច្រាំងការពារការហូរច្រោះបេតុងអាមេ | 90% | 30% | មានប្លង់ (មិនទាន់ឆ្លងបញ្ចប់) |
| 14 | 1110104 | ជញ្ជាំងបេតុងអាមេទប់ដី | 90% | 20% | មានប្លង់ (មិនទាន់ឆ្លងបញ្ចប់) |
| 15 | 1120307 | ស្លាកសញ្ញាគម្រោង | 100% | 100% | អាចប្រើបាន |
| 16 | 1100404 | លូជ្រុងដោះទឹក (០៨មx១ម មានគម្រប) | បានបង្ហើយគំនូសប្លង់បច្ចេកទេស និងតារាងប៉ាន់ស្មានតម្លៃលម្អិតចំនួន៤ពីឆ្នាំ២០១៦ ដូចនេះប្លង់ទាំង៤អាចប្រើបានក្នុងឆ្នាំ២០១៨។ | | |
| 17 | 1100405 | លូស្គរដោះទឹក (Drum) អង្កត់ផ្ចិត១ម | | | |
| 18 | 1020205 | លូមូលទោល០,៦ម មានទ្វារទឹកនិយ័តករ | | | |
| 19 | 1020206 | លូមូលទោល០,៨ម មានទ្វារទឹកនិយ័តករ | | | |

សម្គាល់៖ កិច្ចការបន្តបង្ហើយគំនូសប្លង់បច្ចេកទេស និងតារាងប៉ាន់ស្មានតម្លៃលម្អិតនឹងបញ្ចប់ក្នុងឆ្នាំ២០១៨ បើមានឱកាស

## ៦.៤. ផែនការឆ្នាំ២០១៨ ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប

យោងលើបញ្ជីលទ្ធផលគម្រោងស្តង់ដាសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និង NCDD Template មានគំនូសប្លង់ជាច្រើនត្រូវបានធ្វើការកែសម្រួលឱ្យស្របតាមការវិវត្តន៍នៃគម្រោងដែលចេះតែទាមទារនូវគុណ-ភាពខ្ពស់ និងប្លង់ច្បាស់លាស់ ដូច្នេះក្នុងឆ្នាំ២០១៨ យើងគ្រោង (១). ធ្វើការកែសម្រួលបន្តនូវលទ្ធផលគំនូស-ប្លង់បច្ចេកទេសគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងតារាងប៉ាន់ស្មានតម្លៃលម្អិតដែលបានគ្រោងក្នុងឆ្នាំ២០១៧ (២). ផ្សព្វផ្សាយពីគំនូសប្លង់ និងតារាងប៉ាន់ស្មានតម្លៃដែលបានកែសម្រួលដល់ថ្នាក់ក្រោមជាតិ (Workshop) និង (៣). ចងក្រងជាសៀវភៅណែនាំនូវឯកសារបណ្តុះបណ្តាលស្តីពី មូលដ្ឋានគ្រឹះបច្ចេកទេសគម្រោងហេដ្ឋារចនាសម្ព័ន្ធ របស់ គ.ជ.អ.ប (ដែលសព្វថ្ងៃជា PowerPoint File)។

# ៧. ការគាំទ្ររបស់ PIA ដល់ថ្នាក់ក្រោមជាតិ

បច្ចុប្បន្ននេះ PIA គឺជា**ឆ្អឹងខ្នងមួយដ៏សំខាន់**របស់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ (TSO) ជាជំនួយការពិសេសរបស់ទីចាត់ការផែនការ និងវិនិយោគដែលជាសេនាធិការរបស់ខេត្តនីមួយៗ។ PIA ជួយគាំទ្រ តម្រង់ទិស និងពង្រឹងបន្ថែមដល់ TSO នៅគន្លឹះបច្ចេកទេសដែល TSO មិនអាចធ្វើបានលើការសិក្សាគម្រោង ហើយ PIA ជួយគាំទ្រ TSO ប្រកបដោយឆន្ទះល្អលើការងារត្រួតពិនិត្យគម្រោងទាំងបរិមាណ និងគុណភាពគម្រោង មិនបណ្តែតបណ្តោយតាមអារម្មណ៍លើការងារត្រួតពិនិត្យគម្រោង។ តែ PIA ក៏**ជាឆ្អឹងទទឹងករមួយ**របស់ក្រុមការងារខេត្តមួយចំនួនដែលស្វែងរកលាភសក្ការៈពីការអនុវត្តគម្រោង ហើយក្រុមគាត់ក៏ចង់ដក PIA ចេញដែរ តែក្រុមគាត់មិនបានគិតពីផលលំបាកបន្ទាប់ពីដក PIA ចេញនោះទេ។

## ៧.១ តួនាទី PIA ក្នុងការជួយគាំទ្រវិមជ្ឈការនៅថ្នាក់ក្រោមជាតិ

- សម្របសម្រួល និងគាំទ្រដល់ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តក្នុងកិច្ចដំណើរការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ និងធ្វើបច្ចុប្បន្នភាពបញ្ជីតម្លៃសម្ភារស្តង់ដាប្រចាំឆ្នាំ។
- សម្របសម្រួល និងគាំទ្រដល់ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តក្នុងកិច្ចសហការណ៍ ការសិក្សាគម្រោង រៀបចំគំនូសប្លង់បច្ចេកទេស និងរៀបចំសំណុំឯកសារសំណើគម្រោងហេដ្ឋារចនាសម្ព័ន្ធរាជធានី ខណ្ឌ ខេត្ត និងឬគាំទ្រការអនុវត្តគម្រោងនានាដែលចុះកិច្ចសន្យាជាមួយរដ្ឋបាលរាជធានី ខណ្ឌ ខេត្ត។
- សម្របសម្រួល និងគាំទ្រដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ ក្នុងការជួយគាំទ្រដល់ការិយាល័យគាំទ្រមូលដ្ឋានឃុំ សង្កាត់ក្នុងការសិក្សាគម្រោង រៀបចំគំនូសប្លង់បច្ចេកទេស និងរៀបចំសំណុំឯកសារសំណើគម្រោង ដំណើរការរៀបចំធ្វើលទ្ធកម្ម រៀបចំឯកសារកិច្ចសន្យា និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុង ស្រុក ឃុំ សង្កាត់។
- សម្របសម្រួល និងគាំទ្រដល់ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តក្នុងការបញ្ចូលព័ត៌មានទិន្នន័យនៃការអនុវត្តគម្រោង (PID)។
- ជួយគាំទ្រដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធក្នុងការ៖
    - ✓ សិក្សាគម្រោង រៀបចំគំនូសប្លង់បច្ចេកទេស និងរៀបចំសំណុំឯកសារសំណើគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋានដែលប្រើមូលនិធិឃុំ សង្កាត់ និងក្រុង ស្រុក។
    - ✓ រៀបចំការដេញថ្លៃគម្រោង ការចុះកិច្ចសន្យា ការអនុវត្តកិច្ចសន្យា និងការត្រួតពិនិត្យកិច្ចសន្យាគម្រោងមូលនិធិឃុំ សង្កាត់ និងក្រុង ស្រុក។
    - ✓ អភិវឌ្ឍសមត្ថភាពមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធតាមរយៈការបណ្តុះបណ្តាលផ្ទាល់ និងការរៀនបណ្តើរធ្វើបណ្តើរទាក់ទងនឹងការប្រើប្រាស់ NCDD Template សៀវភៅណែនាំបច្ចេកទេសឃុំ សង្កាត់ សៀវភៅណែនាំស្តីពីបទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ គ.ជ.អ.ប និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ (PIM)។
    - ✓ ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់អ្នកទទួលការពីគោលការណ៍ណែនាំ នីតិវិធីគ្រប់គ្រងកិច្ចសន្យាការយល់ដឹងផ្នែកបច្ចេកទេស និងការកែលម្អការអនុវត្តការងារ។
    - ✓ សហការជាមួយមន្ត្រីការិយាល័យគាំទ្រគម្រោងឃុំ សង្កាត់ក្នុងការអភិវឌ្ឍសមត្ថភាពដល់គណៈកម្មការគ្រប់គ្រងគម្រោង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការត្រួតពិនិត្យការអនុវត្តកិច្ចសន្យា។
    - ✓ បណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការដោះស្រាយតម្រូវការលើការថែទាំគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ។
    - ✓ រៀបចំសិក្ខាសាលាយ៉ាងតិច១ដងក្នុង១ឆ្នាំជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ នៅថ្នាក់ក្រុង ស្រុកអំពីបញ្ហា នានាពាក់ព័ន្ធនឹងការរៀបចំគ្រោងការគម្រោង ការធ្វើលទ្ធកម្មគម្រោង ការអនុវត្ត និងការតាមដានការអនុវត្តកិច្ចសន្យាគម្រោងក្រុង ស្រុក និងឃុំ សង្កាត់ព្រមទាំងកំណត់អំពីការខ្វះចន្លោះផ្នែកសមត្ថភាព និងរៀបចំអនុសាស៍សម្រាប់កែលម្អការអនុវត្ត។

## ៧.២ បញ្ហាប្រឈមចម្បងបើអវត្តមាន PIA

- ការសិក្សាគម្រោងនឹងយឺត ឬអូសបន្លាយរយៈពេលយូរ
  - ✓ ការសិក្សាលទ្ធភាពនៅទីតាំងគម្រោងនូវតែត្រូវការ PIA ជួយព្រោះគម្រោងមូលនិធិឃុំ សង្កាត់ប្រហែល ៧%ជាគម្រោងផ្នែកធារាសាស្ត្រ ១២%ជាគម្រោងផ្លូវបេតុង ផ្លូវអ៊ុតកៅស៊ូ ១%ជាគម្រោងប្រព័ន្ធលូដោះទឹក និងគម្រោងអគារតូចៗ ដែលTSO មិនអាចធ្វើបាន ហើយបច្ចុប្បន្ននេះគម្រោងនៅថ្នាក់ក្រុង ស្រុក និងខេត្តមានគម្រោងប្រភេទនេះច្រើនដែលត្រូវការ PIA ជួយសិក្សា និងគូសប្លង់បច្ចេកទេស។ ករណីជួយរៀបចំរបាយការណ៍បរិស្ថាន ដីធ្លី ជនជាតិដើមភាគតិច បើគ្មានPIA ជួយនោះគម្រោងដើរទៅមុខយឺតណាស់។
  - ✓ នៅក្នុង NCDD Template ត្រូវការនូវបច្ចេកវិទ្យាថ្មីដើម្បីឱ្យវាដំណើរការបានល្អ ដូចជាកម្មវិធី AutoCAD, Excel Professional ដើម្បីធ្វើការគណនាតម្លៃគម្រោង កិច្ចការទាំងនេះTSO ភាគច្រើន (៧៦%) មិនមានមូលដ្ឋានជាវិស្វករ ដែលអាចដោះស្រាយនូវរាល់បញ្ហាដែលអាចកើតឡើងពេលសិក្សាគម្រោងស្មុគស្មាញ ឬពេល NCDD Template ដើរមិនប្រក្រតី។
  - ✓ គម្រោងក្រុង ស្រុក និងខេត្តមួយចំនួនមិនទាន់មានលទ្ធភាពអាចធ្វើការនេះដោយខ្លួនឯងដោយគ្មានជំនួយពី PIA ឡើយ បានន័យថាក្រុង ស្រុក ឬខេត្តមិនទាន់មានធនធានមនុស្សគ្រប់គ្រាន់សម្រាប់ការងារនេះ។
  - ✓ មានគម្រោងមួយចំនួននៅឃុំ សង្កាត់ក៏ដូចជាថ្នាក់ក្រុង ស្រុក ខណ្ឌដែរមានលក្ខណៈពិសេស គឺមិនអាចយកគំនូសប្លង់ក្នុង NCDD Template មកប្រើបានតែម្តងបានទេ គឺតម្រូវឱ្យមានការសិក្សា និងគូសប្លង់បន្ថែម ដូចនេះតម្រូវការទីប្រឹក្សា PIA ជួយផ្តល់យោបល់ និងជួយគូស កែប្លង់បន្ថែម និងប៉ាន់ស្មានតម្លៃលម្អិត។
  - ✓ ផ្ទៀងផ្ទាត់នូវតម្លៃឯកតាក្នុងតារាងប៉ាន់ស្មានតម្លៃឱ្យស្របតាមបញ្ជីតម្លៃសម្ភារស្តង់ដាប្រចាំឆ្នាំ
- **ការដេញថ្លៃគម្រោងនឹងឆកល្វែង ឬមិនមានតម្លាភាព**
  - ✓ PIAជួយផ្តល់នូវនីតិវិធីសមស្របតាមគោលការណ៍ណែនាំដើម្បីដោះស្រាយបញ្ហាដែលកើតឡើងភ្លាមៗ ក្នុងអំឡុងពេលដេញថ្លៃ
  - ✓ ជួយទប់ស្កាត់នូវការឃុបឃិតគ្នារបស់អ្នកទទួលការក្នុងពេលដេញថ្លៃ ដើម្បីបង្កើនការប្រកួតប្រជែង និងតម្លាភាព
  - ✓ សៀវភៅភីម២០១៧ថ្មីទើបនឹងចេញឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៨ មន្ត្រី TSO និងអ្នកពាក់ព័ន្ធមួយចំនួននៅមិនទាន់យល់ច្បាស់អំពីដំណើរការរៀបចំឯកសារសំណើគម្រោង ឯកសារកិច្ចសន្យាពិសេសកិច្ចលទ្ធកម្មមានការផ្លាស់ប្តូរច្រើនបើគ្មាន PIA ពិបាកហើយ។
- **ជួយពង្រឹងយន្តការនៃការត្រួតពិនិត្យបរិមាណ និងគុណភាពនៃការអនុវត្តកិច្ចសន្យា**
  - ✓ ការអនុវត្តកិច្ចសន្យា ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃគម្រោងមិនអាចរលូន មានតម្លាភាព ទៅតាមបទដ្ឋានបច្ចេកទេស ហើយអាចបង្ករជាហានិភ័យច្រើនដល់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ប្រសិនគ្មាន PIAជួយគាំទ្រ
  - ✓ មន្ត្រីTSO ភាគច្រើននឹងពិបាកក្នុងការពន្យល់ម្ចាស់គម្រោង ឬណែនាំអ្នកទទួលការពីគំនូសប្លង់បច្ចេកទេស និងជជែកតតាំងជាមួយអ្នកទទួលការពីបច្ចេកទេសនៃការអនុវត្តគម្រោង

- ✓ ពេលវាយតម្លៃគម្រោងបញ្ចប់៥០% ឬ ១០០% TSO ភាគច្រើនមិនសូវយកចិត្តទុកដាក់ក្នុងការតាមដានការអនុវត្តគម្រោងរបស់អ្នកទទួលការ និងវាស់វែងផ្ទៀងផ្ទាត់ពីបរិមាណ និងគុណភាពគម្រោងទេ បើអវត្តមានPIA, ម្ចាស់គម្រោង មន្ត្រីបច្ចេកទេស TSO និងអ្នកពាក់ព័ន្ធពិនិត្យគម្រោងតាមបែបអ្នកទេសចរណ៍ (មិនធ្វើតេស្ត មិនវាស់កម្រាស់ ទទឹង បណ្តោយ។ល។)

- **ការងារផ្សេងទៀតដែល PIA ត្រូវជួយ**
  - ✓ រៀបចំបញ្ជីឈ្មោះអ្នកទទួលការ និងបញ្ជីតម្លៃសម្ភារស្តង់ដាប្រចាំឆ្នាំ
  - ✓ ជួយជម្រុញការបញ្ចូលប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោង (PID) និងវឌ្ឍនភាពនៃការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក
  - ✓ ជួយសិក្សាគម្រោងមួយចំនួនរបស់រាជធានី ខេត្តដែលពឹងឱ្យជួយរៀបចំសំណើគម្រោង
  - ✓ ជួយបណ្តុះបណ្តាលដល់គ្រប់ភាគីអ្នកពាក់ព័ន្ធក្នុងការរៀបចំគម្រោង ពិសេសលើការត្រួតពិនិត្យគុណភាពគម្រោងមុនធ្វើការទូទាត់ជូនអ្នកទទួលការ។

# ៨. កត្តាដែលធ្វើឱ្យការអនុវត្តគម្រោងបានល្អ

**តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ទៅថ្ងៃអនាគតបានប្រសើរ និងមានគុណភាព?** បើនិយាយថា ធ្វើយ៉ាងណាដើម្បីឱ្យការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ទៅថ្ងៃអនាគតបានប្រសើរ និងមានគុណភាពល្អនោះយើងត្រូវគិត និងសិក្សាពីកត្តាមួយចំនួនដែលបានជះឥទ្ធិពលមកលើការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់របស់យើងដូចខាងក្រោម៖

## ៨.១. មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ (TSO)

- ✓ គួរតែតែងតាំង ឬក៏ជ្រើសរើសមន្ត្រីបច្ចេកទេសដែលមានជំនាញច្បាស់លាស់ យ៉ាងហោចណាស់ក៏បានឆ្លងកាត់វគ្គបច្ចេកទេសមធ្យម (មានសញ្ញាបត្រត្រឹមត្រូវ) ដើម្បីទទួលតួនាទីក្នុងការងារនេះ។ (កន្លងមកមន្ត្រីបច្ចេកទេសភាគច្រើនពុំមានចំណេះដឹង ឬជំនាញលើផ្នែកបច្ចេកទេសនេះអ្វីបន្តិចសោះ តែគាត់ត្រូវបានគេតែងតាំងជាមន្ត្រីបច្ចេកទេសប្រចាំស្រុក ធ្វើឱ្យពួកគាត់មានការពិបាកនឹងទទួលយកនូវចំណេះដឹងថ្មីៗបន្ថែមទាក់ទងនឹងបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធនេះណាស់ នៅពេលដែលយើងបង្ហាត់បង្រៀនដល់គាត់។
- ✓ ត្រូវតែរំលឹកឡើងវិញនូវមេរៀនដែលទាក់ទងទៅនឹងបច្ចេកទេសក្នុងការតាមដានការអនុវត្តគម្រោង ឬបើកវគ្គរំលឹកឡើងវិញស្តីពីការចុះសិក្សា និងត្រួតពិនិត្យការអនុវត្តគម្រោងនៅដើមឆ្នាំនីមួយៗដើម្បីឱ្យមន្ត្រីមានឱកាសបានផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ពិសេសមន្ត្រីបច្ចេកទេសហេដ្ឋារចនា-សម្ព័ន្ធទើបចូលថ្មីៗ អាចស្វែងយល់ និងរៀនបណ្តើរ អនុវត្តបណ្តើរ។
- ✓ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ ត្រូវមានផែនការចុះត្រួតពិនិត្យការអនុវត្តរបស់អ្នកទទួលការឱ្យបានច្បាស់លាស់ និងរាល់ការចុះត្រួតពិនិត្យការអនុវត្តគម្រោងមន្ត្រីហេដ្ឋារចនាសម្ព័ន្ធត្រូវមានឯកសារកិច្ចសន្យាដើម្បីផ្ទៀងផ្ទាត់លទ្ធផលកិច្ចសន្យា បទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគំនូសប្លង់បច្ចេកទេសដែលបានចុះកិច្ចសន្យារវាងម្ចាស់គម្រោង និងអ្នកទទួលការ។

- ✓ កុំឱ្យមានសម្ពាធពីថ្នាក់ដឹកនាំលើមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ (មានន័យថាកុំឱ្យថ្នាក់ដឹកនាំកាង អ្នកទទួលការ ហើយបង្ខំមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធឱ្យទទួលយកលទ្ធផលគម្រោង)។
- ✓ គ្រប់គម្រោងទាំងអស់ដែលបញ្ចប់ការសាងសង់៥០% ឬ១០០% TSO ត្រូវសហការជាមួយទីប្រឹក្សាម្ចាស់គម្រោង និងអ្នកពាក់ព័ន្ធធ្វើការវាស់វែងពីបរិមាណការងារ និងធ្វើតេស្តដើម្បីពិនិត្យពីគុណភាពនៃការសាងសង់ធៀបនឹងកិច្ចសន្យា។ បើមិនត្រឹមត្រូវតាមកិច្ចសន្យាទេ នោះមិនអនុញ្ញាតឱ្យធ្វើការទូទាត់ឡើយ។

## ៨.២. អ្នកទទួលការ

- ✓ ត្រូវមានកម្មវិធីអញ្ជើញអ្នកទទួលការឱ្យចូលមកសិក្សាពីគោលការណ៍លទ្ធកម្មថ្មីៗ បទដ្ឋានបច្ចេកទេស គ.ជ.អ.ប និងការទទួលខុសត្រូវក្នុងការអនុវត្តរបស់អ្នកទទួលការដើម្បីបង្កើនគុណភាពគម្រោង។
- ✓ គួរតែជ្រើសរើសអ្នកទទួលការដែលមានគ្រឿងចក្រ ឬសម្ភារបរិក្ខារផ្ទាល់ខ្លួន នឹងមានរចនាសម្ព័ន្ធបុគ្គលិកត្រឹមត្រូវ ដោយមានសមាជិកជាអ្នកបច្ចេកទេស ដែលមានសញ្ញាបត្របច្ចេកទេសចេញពីសាលាច្បាស់លាស់ទាក់ទងទៅនឹងប្រភេទនីមួយៗ ដែលគាត់បានដាក់។

## ៨.៣. គណៈកម្មការគ្រប់គ្រងគម្រោង

- ✓ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធត្រូវណែនាំ និងបង្រៀនបច្ចេកទេសសាមញ្ញងាយៗដោយផ្ទាល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការគ្រប់គ្រងគម្រោង និងជនបង្គោលអំពីការតាមដាន ត្រួតពិនិត្យបច្ចេកទេសនៃការសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចជាការវាស់ផ្ទៀងផ្ទាត់ប្រវែងបណ្តោយ ទទឹងទ្រូងផ្លូវ កម្រាស់ កម្ពស់ ការកិនបង្ហាប់ ការលាយបេតុង និងភាពធន់របស់បេតុង។ល។
- ✓ ត្រូវបណ្តុះបណ្តាលអំពីមូលដ្ឋានគ្រឹះបច្ចេកទេសដល់មេឃុំ ចៅសង្កាត់ និងគណៈកម្មាការគ្រប់គ្រងគម្រោងអំពីការតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង (6 in 1 Plus)
- ✓ សមាជិកគណៈកម្មការគ្រប់គ្រងគម្រោងគួរតែមានការឧបត្ថម្ភលើកទឹកចិត្តខ្លះដោយប្រើចំណាយចរន្តក្នុងរយៈពេលតាមដានការអនុវត្តគម្រោង។
- ✓ ត្រូវជំរុញឱ្យមានការចូលរួមតាមដានការអនុវត្ត និងថែទាំពីគណៈកម្មាការគ្រប់គ្រងគម្រោងឃុំ សង្កាត់ ក្រុង ស្រុក និងរាជធានី ខេត្ត
- ✓ មេឃុំ ចៅសង្កាត់អាចជួលអ្នកបច្ចេកទេសឯកជន ដែលមានសញ្ញាបត្រវិស្វករ បច្ចេកទេសសំណង់ដើម្បីតាមដានត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

## ៨.៤. ឧបករណ៍ត្រួតពិនិត្យបច្ចេកទេស

- ✓ ឧបករណ៍ត្រួតពិនិត្យគុណភាពគម្រោងត្រូវតែមានគ្រប់គ្រាន់ និងប្រកបដោយគុណភាព។ ត្រូវយកឧបករណ៍ធ្វើតេស្តគម្រោងតាមជំហ៊ាននៃការអនុវត្ត។
- ✓ រាល់គម្រោងបញ្ចប់ការសាងសង់៥០% ឬ១០០% ត្រូវមានឧបករណ៍បច្ចេកទេសដូចជាខ្សែម៉ែត្រ ឋានលេខា ឌីស៊ីភី តេស្តបេតុងដើម្បីត្រួតពិនិត្យលទ្ធផលគម្រោងធៀបនឹងកិច្ចសន្យា។

### ៨.៥. ចុះពិនិត្យពីថ្នាក់ជាតិ

- ✓ ការចុះត្រួតពិនិត្យការអនុវត្តគម្រោងពីក្រុមការងារថ្នាក់ជាតិជាប្រចាំ ឬចុះពិនិត្យក្នុងករណីមិនត្រូវផ្តល់ដំណឹងមុន (Sport Check) ជាការចាំបាច់
- ✓ ការបណ្តុះបណ្តាលថ្មី និងរំលឹកដល់មន្ត្រីដែលជួយគាំទ្រនៅកម្រិតថ្នាក់ជាតិឱ្យបានយ៉ាងតិចម្តងក្នុងមួយឆ្នាំ ដើម្បីមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការបំពេញភារកិច្ចគាំទ្រដល់មូលដ្ឋាន
- ✓ របកគំហើញថ្មី ពីចំណុចខ្វះខាត និងបទពិសោធន៍ល្អពីខេត្តមួយទៅខេត្តមួយ គួរត្រូវបានចែករំលែកគ្នាតាមរយៈសិក្ខាសាលាប្រចាំឆ្នាំ ឬពេលណាមួយសមស្រប
- ✓ កែសម្រួល និងធ្វើបច្ចុប្បន្នភាពលើគំនូសប្លង់បច្ចេកទេស ការប៉ាន់ស្មានតម្លៃ និងបទដ្ឋានបច្ចេកទេសមួយចំនួនដែលមានចែងក្នុងសៀវភៅបទដ្ឋានបច្ចេកទេសគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

### ៨.៦. កត្តាផ្សេងៗទៀត

- ✓ ការចូលរួមត្រួតពិនិត្យពីអ្នកទទួលផល និងប្រជាពលរដ្ឋនៅមូលដ្ឋានដែលត្រូវសាងសង់
- ✓ គួរមានប្រាក់ឧបត្ថម្ភបន្ថែមដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធសម្រាប់គម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត
- ✓ គួរមានការលើកទឹកចិត្តមន្ត្រីបច្ចេកទេស និងអ្នកពាក់ព័ន្ធក្នុងគម្រោង ដូចជាទស្សនៈកិច្ចសិក្សាប្រចាំឆ្នាំ
- ✓ ត្រូវបន្ថែមប្រាក់ឧបត្ថម្ភដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធឱ្យបានសមរម្យ ដើម្បីឱ្យពួកគេមានលទ្ធភាពចុះពិនិត្យការងារអនុវត្តគម្រោងឱ្យបានញឹកញាប់ក្នុងដំណាក់កាលសាងសង់ដើម្បីពិនិត្យមើលថាតើអ្នកទទួលការបានអនុវត្តតាមការបរិយាយលម្អិតលក្ខណៈបច្ចេកទេសដែរឬទេ
- ✓ គួរផ្តល់នូវមធ្យោបាយធ្វើដំណើរតាមដែលអាចធ្វើបានដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធក្នុងការចុះត្រួតពិនិត្យតាមដានគុណភាពនៃការអនុវត្តគម្រោង (កន្លងមកមន្ត្រីបច្ចេកទេសតាមស្រុកនីមួយៗមានការលំបាកច្រើន ក្នុងការរកយានជំនិះដឹកឧបករណ៍យកទៅត្រួតពិនិត្យតាមដានគុណភាពគម្រោងនៅទីតាំងសាងសង់)។
- ✓ ការដាក់ពិន័យ ឬទណ្ឌកម្មដល់អ្នកទទួលការ និងអ្នកពាក់ព័ន្ធដែលបានប្រព្រឹត្តិខុសគោលការណ៍ណែនាំបទដ្ឋានបច្ចេកទេស ក្រមសីលធម៌ ការប្រព្រឹត្តអំពើពុករលួយឱ្យបានតឹងរ៉ឹង។

## ៩. សំណូមពរ

- ✓ ខេត្តកែប ជាខេត្តតូចមានមួយក្រុង ៣សង្កាត់ និងមួយស្រុក ២ឃុំ ហើយខេត្តនេះមានស្ថានភាពភូមិសាស្ត្រ ស្ថិតនៅក្នុងខេត្តកំពត ទំនិញភាគច្រើនយកពីខេត្តកំពត ដូច្នេះដើម្បីកុំឱ្យខាតពេលវេលាគួរមិនចាំបាច់រៀបចំធ្វើបញ្ជីតម្លៃសម្ភារស្តង់ដាទេ ដោយយកបញ្ជីតម្លៃសម្ភារស្តង់ដារបស់ខេត្តកំពតមកប្រើតែម្តងទៅ។ រីឯបញ្ជីឈ្មោះអ្នកទទួលការប្រចាំឆ្នាំខេត្តកែបមានតែពីរ ឬបីក្រុមហ៊ុនប៉ុណ្ណោះក្នុងមួយឆ្នាំៗ ហើយភីមយើងក៏បើកទូលាយដែរ (អ្នកទទួលការទាំងឡាយដែលមានឈ្មោះក្នុងបញ្ជីអ្នកទទួលការ គឺជាអ្នកទទួលការប្រភេទទី១ ទី២ ឬទី៣ មានសិទ្ធដាក់សំណើដេញថ្លៃគ្រប់កិច្ចសន្យាឃុំ សង្កាត់នៅទូទាំងប្រទេសកម្ពុជាដោយស្វ័យប្រវត្តិទៅតាមប្រភេទរបស់ខ្លួន...ភីមទំព័រ១៧៥) ដូច្នេះខេត្តកែបគួរតែមិនចាំបាច់ធ្វើបញ្ជីឈ្មោះអ្នកទទួលការប្រចាំឆ្នាំទេ។

- ✓ ក្នុងការចុះគាំទ្រដល់ដំណើរការរៀបចំ និងអនុវត្តការត្រួតពិនិត្យគម្រោងមូលនិធិឃុំ សង្កាត់ សុំឱ្យបន្តនូវយន្តការតាមសេចក្តីណែនាំលេខៈ០០១សណន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ពីការត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឱ្យមាននិរន្តភាព។
- ✓ សុំលេខាធិការដ្ឋាន គ.ជ.អ.ប ជួយទិញឧបករណ៍ឋានលេខា ខ្សែម៉ែត្រ ក្តារមៀរ និងឧបករណ៍តេស្តបេតុងបន្ថែមទៀត ព្រោះគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់ ក្រុង ស្រុកជាគម្រោងទាមទារការសិក្សាលក្ខណៈបច្ចេកទេសប្រាកដប្រជា នឹងមានតម្លាភាពក្នុងការគណនាតម្លៃប៉ាន់ស្មានគម្រោងចំពោះម្ចាស់គម្រោង និងអ្នកពាក់ព័ន្ធ។ នៅក្នុងការរៀបចំការគ្រោងប្លង់តាម NCDD Template ទាមទារនូវការប្រើប្រាស់ឧបករណ៍ដែលបានរៀបរាប់ខាងលើ។
- ✓ គម្រោងដាច់ដោយឡែក (Stay alone project) ដូចជាគម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុជំហានទី២ (Local Government and Climate Change project (LGCCII), កម្មវិធី ASPIRE គម្រោង SRL គម្រោង DRR គួរតែអនុវត្តនីតិវិធី PIM ២០១៧ ដូចគ្នាទាំងអស់ទៅ។

## ១០. ផែនការឆ្នាំ ២០១៨

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តបន្តផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី៣ ពីឆ្នាំ២០១៨ ដល់ ២០២០ (**ផអ៣ទី៣**) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការឱ្យកាន់តែប្រសើរឡើង។ **ផអ៣ទី៣** មានគោលបំណងបន្តពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានស្វ័យភាព និងគណនេយ្យភាពក្នុងការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យកាន់តែប្រសើរថែមទៀត។

ដើម្បីចូលរួមក្នុងចក្ខុវិស័យរបស់ផអ៣ដំណាក់កាលទី៣នេះ ក្រុមការងារបច្ចេកទេសគាំទ្រ និងត្រួត-ពិនិត្យការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់របស់នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់នៃក្រសួងមហាផ្ទៃនឹងខិតខំជួយគាំទ្រ និងពង្រឹងនូវការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិ។

ឆ្លើយតបនូវគោលបំណង និងគោលដៅរបស់ផអ៣ទី៣ ក្នុងនាមទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិត្រៀមខ្លួនសហការជាមួយនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានផែនការមួយចំនួនសម្រាប់ពង្រឹង និងគាំទ្រនូវការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិដូចខាងក្រោមៈ

- ✓ បន្តការគាំទ្រដល់ដំណើរការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងក្រុង ស្រុកដោយសហ-ការជាមួយក្រុមសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និង ជនជាតិដើមភាគតិច។
- ✓ សហការជាមួយនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់អនុវត្តការត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក។
- ✓ គាំទ្រដល់ថ្នាក់រាជធានី ខេត្តក្នុងការរៀបចំបញ្ជីតម្លៃសម្ភារស្តង់ដាសម្រាប់ឆ្នាំ២០១៩ (សហការជាមួយនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត)។
- ✓ សហការជាមួយអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប លើការងារទាក់ទងនឹងបទដ្ឋានបច្ចេកទេស ការកែសម្រួលគំនូសប្លង់បច្ចេកទេស តារាងប៉ាន់ស្មានតម្លៃលម្អិតគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៩។

- ✓ បណ្តុះបណ្តាល TSO សាលាខេត្តប្រមាណ៦៧% នៃTSOសរុប ស្តីពីមូលដ្ឋានគ្រឹះបច្ចេកទេសនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ៕

## ១១. ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ របាយការណ៍នៃការចុះតាមដានការអនុវត្តគម្រោង

ឧបសម្ព័ន្ធទី២ ៖ របាយការណ៍ស្តីពីការសិក្សាពីករណីមិនប្រក្រតី និងអនុសាសន៍

ឧបសម្ព័ន្ធទី៣ ៖ រូបភាពមួយចំនួនស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

ឧបសម្ព័ន្ធទី៤ ៖ ឧបករណ៍សម្រាប់ជួយគាំទ្រការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ

ឧបសម្ព័ន្ធទី៥ ៖ បញ្ជីទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងអ្នកពាក់ព័ន្ធការងារ

# ឧបសម្ព័ន្ធទី១

## របាយការណ៍នៃការចុះតាមដានការអនុវត្តគម្រោង

1. របាយការណ៍នៃការចុះតាមដានការអនុវត្តគម្រោងនៅខេត្តត្បូងឃ្មុំ
2. ការឆ្លើយឆ្លងតាមអ៊ីម៉ែលក្នុងការជូនព័ត៌មានទៅខេត្ត
3. របាយការណ៍បំភ្លឺ / បកស្រាយពីខេត្ត

# របាយការណ៍ ស្តីពីការចុះតាមដានការអនុវត្តគម្រោង
# មូលនិធិឃុំ សង្កាត់នៅខេត្តត្បូងឃ្មុំ ថ្ងៃទី ២៦-៣០ ខែមិថុនា ឆ្នាំ២០១៧

## ១. សេចក្តីផ្តើម

យោងសេចក្តីណែនាំលេខ០០១សណន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ចុះហត្ថលេខាដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងយោងលិខិតបេសសកម្មលេខៈ ៦៣៩ លបក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានចាត់តាំងមន្ត្រីការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ (ន.ស.ឃ) ចំនួន៣រូប និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ១រូប ឱ្យទៅបំពេញបេសកម្មស្តីពីការចុះតាមដានការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ នៅខេត្តត្បូងឃ្មុំ។ ការចុះបំពេញបេសកម្មនេះគឺ ដើម្បីពន្លឿនការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ ដែលនៅសល់មួយគម្រោង និងពិនិត្យមើលការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ មួយចំនួនទៀតរបស់រដ្ឋបាលឃុំ សង្កាត់ (៣គម្រោងឆ្នាំ២០១៦មិនទាន់ចុះអនុវត្ត) ឱ្យអនុវត្តបានទាន់ពេលវេលា ត្រឹមត្រូវតាមនីតិវិធី និងបទដ្ឋានបច្ចេកទេស។

## ២. គោលបំណង

ការចុះបេសសកម្មនេះស្ថិតក្នុងសកម្មភាពលេខ ២.៤.២.១.៥ នៃសេចក្តីសម្រេចរួម 27/MoI/1701-00 (IP3-II) ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ក្រោមក្របខណ្ឌផអ៣ទី២មានគោលបំណង៖

- ✓ ពង្រឹងការអនុវត្តតួនាទី ភារកិច្ចដល់អ្នកពាក់ព័ន្ធក្នុងដំណើរការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ✓ ជំរុញការអនុវត្តគម្រោងឱ្យទាន់ពេលវេលា និងត្រឹមត្រូវតាមនីតិវិធី និងបទដ្ឋានបច្ចេកទេស
- ✓ ស្វែងរកភាពមិនប្រក្រតី និងចំណុចខ្វះខាតនានាក្នុងការអនុវត្តគម្រោង និងធ្វើការកែលម្អ

## ៣. សង្ខេបសកម្មភាពការងារ

សមាសភាពមន្ត្រី និងទីប្រឹក្សាដែលបានចុះបេសសកម្មជាក់ស្តែងមានចំនួន៤រូប ដូចខាងក្រោម៖

| ល.រ | ឈ្មោះមន្ត្រី | តួនាទី | អង្គភាព |
|---|---|---|---|
| ១ | លោក មិន ស៊ីថា | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| ២ | លោក សាយ ស៊ីនួន | អនុប្រធានការិយាល័យ | នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| ៣ | លោក ចៅ ស៊ុំ | អនុប្រធានការិយាល័យ | នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| ៤ | លោក អ៊ុច ច័ន្ទវុឌ្ឍី | ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ | MoI/NCDD |

ក្នុងការចុះត្រួតពិនិត្យនេះក្រុមការងារ ន.ស.ឃ បានបែងចែកជាពីរដំណាក់កាល នៅដំណាក់កាលទីមួយគឺពិនិត្យឯកសារគម្រោង និងដំណាក់កាលទីពីរគឺចុះពិនិត្យនៅទីតាំងសាងសង់គម្រោងជាក់ស្តែង។ ក្នុងដំណាក់កាលពិនិត្យឯកសារគម្រោងក្រុមការងារ ន.ស.ឃ បានជ្រើសរើស និងពិនិត្យឯកសារចំនួន៤គម្រោង និងចុះត្រួតពិនិត្យផ្ទាល់នៅទីតាំងអនុវត្តគម្រោងជាក់ស្តែងទាំង៤គម្រោង ស្មើនឹង៣ឃុំ ១ស្រុក គឺនៅឃុំបឹងព្រួល និងឃុំជប់ស្ថិតក្នុងស្រុកត្បូងឃ្មុំ ឃុំត្រមូង ស្ថិតក្នុងស្រុកមេមត់ (គម្រោងសាងសង់សាលារៀនឆ្នាំ២០១៥ អនុវត្ត

យឺត) និងគម្រោងស្រុកអូររាំងឪ។ ក្នុងឱកាសនោះដែរក្រុមការងារបច្ចេកទេស ន.ស.ឃ បានចូលរួមពិនិត្យមើលការដេញថ្លៃនៅឃុំវាលម្លូរ និងឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

ក្រោយពីបានពិនិត្យឯកសារចំនួន៤គម្រោងក្រុមការងារបានរកឃើញដូចបង្ហាញខាងក្រោម៖

- សំណុំឯកសារព័ត៌មានគម្រោង និងកិច្ចសន្យា មិនរៀបតាមមាតិកាដែលបានណែនាំ (មានដាក់មាតិកា តែមិនរៀបតាម)
- សំណុំឯកសារព័ត៌មានគម្រោង កិច្ចសន្យាមិនបានកៀបជាសៀវភៅ
- មិនបានប្រថាប់ត្រារដ្ឋបាលខេត្តលើផែនទីទីតាំងគម្រោងមួយចំនួន
- ការដាក់ឈ្មោះគម្រោងបានល្អចំពោះគម្រោងតែមួយ
- មិនបានដាក់ ការបរិយាយលម្អិតបច្ចេកទេសសម្រាប់សាងសង់ នៅក្នុងកិច្ចសន្យា
- លិខិតធានាប្រាក់កក់អនុវត្តមិនមានសុពលភាពគ្រប់៦ខែក្រោយបញ្ចប់ការសាងសង់ (ឃុំជប់ ឃុំបឹងព្រួល)
- លិខិតផ្ទេរសិទ្ធដេញថ្លៃមិនបានបញ្ជាក់ឈ្មោះឃុំ សង្កាត់ឱ្យបានច្បាស់លាស់ និងមិនបានដាក់ថ្ងៃខែឆ្នាំលើឯកសារខ្លះ។

ក្រោយពីបានពិនិត្យឯកសាររួចរាល់ហើយក្រុមការងារបានចុះត្រួតពិនិត្យផ្ទាល់នៅទីតាំងអនុវត្តគម្រោងជាក់ស្តែងចំនួន៤គម្រោង លទ្ធផលដែលបានរកឃើញបង្ហាញតាមគម្រោងនីមួយៗដូចខាងក្រោម៖

### ៣.១. ឃុំបឹងព្រួល ស្រុកត្បូងឃ្មុំ

- កិច្ចសន្យា៖ ស្តារស្រះ ១កន្លែង ទំហំ L=100m, W= 30 & H=3m ត្រឹមត្រូវតាមកិច្ចសន្យា
- ជាក់ស្តែង៖ គម្រោងបានអនុវត្តហើយ១០០% តាមផែនការ និងមានដាក់ស្លាកសញ្ញាគម្រោង
- ការជីកស្រះនេះសម្រាប់បម្រើផលប្រយោជន៍ខាងកសិកម្ម
- មានការសហការល្អរវាងក្រុមប្រឹក្សាឃុំ និងក្រុមការងារបច្ចេកទេស





### ៣.២. ឃុំជប់ ស្រុកត្បូងឃ្មុំ

- កិច្ចសន្យា៖ ផ្លូវបេតុងអាមេ L =120 m W=3m & T= 0.15m
- ជាក់ស្តែង៖ សាងសង់ហើយ ១០០% ប្រវែងបណ្តោយ និងទទឹងគ្រប់តាមកិច្ចសន្យា និងគុណភាពទទួលយកបាន (៣៤ > ៣០ Mpa) គម្រោងស្ថិតក្នុងរយៈពេលធានាការអនុវត្ត៦ខែ។
- មានស្លាកសញ្ញាគម្រោង...តែត្រូវគេបុក ឬវាយបែកសរសរ

- មិនបានចាក់បំពេញដីក្រួសក្រហមនៅស្មាផ្លូវ
- គណៈកម្មការគ្រប់គ្រងគម្រោង និងក្រុមប្រឹក្សាឃុំសហការគ្នាបានល្អ





### ៣.៣. ឃុំត្រមូង ស្រុកមេមត់

- កិច្ចសន្យា៖ សាងសង់សាលារៀន ២បន្ទប់ + សង្ហារិម (តុសិស្ស=៤០ មាន តែតុកៅអីគ្រូ=២កំពង់ធ្វើ )
- ជាក់ស្តែង៖ អនុវត្តបាន ៨៥% នៃតាមកិច្ចសន្យា អ្នកទទួលការអនុវត្តយឺត (២០១៥-២០១៧)។ មូលហេតុដែលអនុវត្តយឺតដោយសារពីមុនផ្លូវលំបាក ភ្លៀងច្រើនពិបាកដឹកសម្ភារៈសាងសង់ចូលការដ្ឋាន ពេលចាប់ផ្តើមធ្វើម្តងៗពិបាកប្រមូលក្រុមជាង
- គុណភាពទ្វារល្អបង្អួរ តែបង្អួចមួយចំនួនបានពុកផុយ
- គុណភាពបេតុងសរសរ ៣០-៣៤ Mpa, ល្អ
- មានស្លាកសញ្ញាគម្រោងមិនទាន់បានសរសេរ, គុណភាពសាងសង់ ទទួលយកបាន !
- អ្នកទទួលការបានប្តេជ្ញានឹងពន្លឿនការអនុវត្តគម្រោងឱ្យបានចប់មុន**ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៧**





កិច្ចប្រជុំពិភាក្សា និងពន្លឿនការអនុវត្តគម្រោងនៅឃុំត្រមូង ស្រុកមេមត់នៅទីតាំងសាងសង់គម្រោង

## ៣.៤. គម្រោងស្រុកអូររាំងឪ

- ផ្លូវបេតុងអាមេ L = 172m W= 4.5m & T= 0.15m ប្រវែង និងទទឹងគ្រប់តាមកិច្ចសន្យា និងគុណភាពទទួលយកបាន។
- ការរៀបចំសំណើគម្រោងល្អ តាមសៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុក
- ភាពធន់នៃបេតុងពី២៨-៣0Mpa ទទួលយកបាន តែទឹកដៃសាងសង់នៅមានកម្រិត ស្លាកសញ្ញាគម្រោងល្អ សហការបានល្អ។




## ៣.៥. ចូលរួមអង្កេតការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ ក្រុមការងារ ន.ស.យ បានចូលរួមអង្កេតសកម្មភាពដេញថ្លៃ២ឃុំ មានឃុំវាលម្លូរ និងឃុំក្រែក ស្រុកពញាក្រែក។ លទ្ធផលនៃការអង្កេតបង្ហាញជូនខាងក្រោម៖

- ទិដ្ឋភាពទូទៅក្នុងដំណើរការដេញថ្លៃដំណើរការបានល្អបង្គួរ ពុំមានអ្នកទទួលការដកសំណើ ឬបង្កភាពរញ៉េរញ៉ៃក្នុងបរិវេណដេញថ្លៃ មានអ្នកទទួលការចូលរួមដេញថ្លៃច្រើន
- មិនមានរបៀបវារៈនៃកិច្ចប្រជុំដេញថ្លៃ អ្នកសម្របសម្រួលយូរៗបានប្រាប់ម៉ោងដែលនៅសល់ម្តង
- អ្នកទទួលការមួយចំនួនមិនបានចូលមកអង្គុយក្នុងបន្ទប់ប្រជុំដេញថ្លៃ ព្រោះខ្វះកៅអី អ្នកទទួលការខ្លះនៅឈរខាងក្រៅបន្ទប់ដេញថ្លៃ
- រយៈពេលនៃការដាក់សំណើ១០នាទី តែអ្នកទទួលការសំរុកដាក់សំណើដេញថ្លៃនៅ២-៣នាទីចុងក្រោយ បណ្តាលឱ្យពួកគាត់ឈរផ្តុំគ្នាច្រើននៅមុខតុគណៈកម្មការលទ្ធកម្ម ហើយអ្នកសម្របសម្រួលមិនមានចំណាត់ការចំពោះអ្នកទទួលការដែលនៅឈរជជែកគ្នានោះទេ ទុកឱ្យអ្នកទទួលការធ្វើតាមចិត្ត
- អ្នកទទួលការហាក់មិនយកចិត្តទុកដាក់ស្តាប់ការអានគោលការណ៍សំខាន់ៗនៃការដេញថ្លៃ
- មិនបានឱ្យអ្នកទទួលការដែលឈ្នះឡើងបង្ហាញមុខ និងធ្វើការប្តេជ្ញាចិត្តក្នុងការអនុវត្តកិច្ចសន្យា




លទ្ធផលនៃការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងខ្លាំងនៅឃុំក្រែក និងមិនសូវប្រកួតប្រជែងនៅឃុំវាលម្លូរ





!

## ៣.៦. គម្រោងមូលនិធិឃុំឆ្នាំ២០១៦ ដែលមិនទាន់បានចុះអនុវត្ត

ក្រុមការងារបច្ចេកទេស ន.ស.ឃ ក៏បានពិភាក្សា និងពន្លឿនការអនុវត្តចំនួន៣ដែលមិនទាន់អនុវត្តជាមួយក្រុមការងារខេត្ត ហើយលទ្ធផលបង្ហាញក្នុងតារាងខាងក្រោម។

| ល.រ | ឈ្មោះឃុំ/ស្រុក | ឈ្មោះគម្រោង | មូលហេតុមិនទាន់អនុវត្ត | អាចចុះអនុវត្ត |
|---|---|---|---|---|
| ១ | ឃុំជាំតាម៉ៅ ស្រុកមេមត់ | សាងសង់ទំនប់ និងទ្វារទឹក | ដឹកសម្ភារៈ និងគ្រឿងចក្រចូលការដ្ឋានពុំរួចដោយឆ្នាំនេះភ្លៀងធ្លាក់ច្រើន | ថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១៨ |
| ២ | | ស្ពានប្រឡាយ | | |
| ៣ | ឃុំកោះពីរ ស្រុកក្រូចឆ្មារ | សាងសង់ផ្លូវដី | ដឹកគ្រឿងចក្រឆ្លងទូកដរពុំរួចដោយអ្នកទទួលការមានតែគ្រឿងចក្រប្រភេទធំៗ ហើយរកជួលគ្រឿងចក្រប្រភេទតូចមិនទាន់បាន។ | ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០១៨ |

## ៤. កិច្ចប្រជុំឆ្លុះបញ្ចាំង

ក្រោយពីបានពិនិត្យឯកសារសំណើគម្រោង ឯកសារកិច្ចសន្យា និងលទ្ធផលនៃចុះត្រួតពិនិត្យផ្ទាល់នៅទីតាំងអនុវត្តគម្រោង ក្រុមការងារថ្នាក់ជាតិបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងដើម្បីបង្ហាញលទ្ធផលនៃការត្រួតពិនិត្យដល់ថ្នាក់ខេត្ត ដើម្បីរាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យដែលមានការចូលរួមពី នាយករងរដ្ឋបាលសាលាខេត្ត នាយករងទីចាត់ការផែនការនិងវិនិយោគខេត្ត ប្រធានទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ មន្ត្រីគាំទ្រឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធទាំងអស់ក្នុងខេត្ត។

ការបង្ហាញបានលើកឡើងនូវចំណុចដែលបានអនុវត្តល្អ និងចំណុចដែលអនុវត្តមិនបានត្រឹមត្រូវដើម្បីកែលម្អការអនុវត្ត និងផ្តល់អនុសាសន៍មួយចំនួន។ ក្នុងកិច្ចប្រជុំនេះក៏បានស្តាប់នូវការបកស្រាយ និងធ្វើការកែតម្រូវនូវអ្វីដែលក្រុមការងារថ្នាក់ខេត្តបានពន្យល់សមហេតុផល។ ខេត្តសន្យាថានឹងខិតខំបន្តទៀត និងយកចិត្តទុកដាក់ពង្រឹងគុណភាពលើការអនុវត្តគម្រោងនៅថ្ងៃអនាគត។

## ៥. សំណូមពរពីខេត្ត

ដោយមានឧបទ្ទវហេតុអគ្គីភ័យឆាបឆេះបន្ទប់ធ្វើការរបស់មន្ត្រីបច្ចេកទេស និងបន្ទប់ទីចាត់ការផែនការ និងវិនិយោគខេត្ត (នៅសាលាខេត្តចាស់-ស្រុកពញាក្រែក) នៅយប់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ បានធ្វើឱ្យឆេះខូចខាតឯកសារគម្រោងភាគច្រើនឆេះ និងត្រូវទឹកសើមខូចអស់ កុំព្យូទ័រលើតុ៧គ្រឿង ព្រីនធ័រ A3 មួយគ្រឿង ព្រីនធ័រ A4 មួយគ្រឿង។ ចំណែកឧបករណ៍ វាស់ស្ទង់ (ម៉ាស៊ីនតូប៉ូ) ឌីស៊ីភី និងឧបករណ៍តេស្តបេតុងមិនខូចខាតទេ។ ខេត្តសំណូមពរឱ្យថ្នាក់ជាតិ/លេខាធិការដ្ឋាន គ.ជ.អ.ប ជួយផ្តល់កុំព្យូទ័រលើតុ និងព្រីនធ័រ A3/A4 សម្រាប់បន្តការងារជួយគាំទ្រឃុំ សង្កាត់ទៅមុខទៀត។

## ៦. អនុសាសន៍

- ពន្លឿនការអនុវត្តគម្រោងឃុំត្រមូង ស្រុកមេមត់ឱ្យបានចប់មុនថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៧ (អ្នកទទួលការបានសន្យា)។ រៀបចំធ្វើការកែសម្រួលកិច្ចសន្យាឱ្យមានសុពលភាពឡើងវិញ បង្អួចដែលពុកផុយមួយចំនួនត្រូវប្តូរថ្មី ឬប្តូរស្លាបព្រិលដែលពុកចេញ ធ្នឹមបេតុងផ្នែកខាងលើនៃអគារសាលារៀនត្រូវសម្អាត និងលាបឱ្យស្អាត ពត់ដែកដែលទុកបន្តបន្ទប់ថ្មីនៅខាងក្រៅអគារ កុំឱ្យគ្រោះថ្នាក់ដល់កុមារ និងសម្អាតបរិវេណជុំវិញអគារឱ្យស្អាតមុនបើកលុយ១០០%។ ក្រោយបញ្ចប់ការសាងសង់ខេត្តរៀបចំរបាយការណ៍សង្ខេបខ្លី និងរូបថតមួយចំនួនផ្ញើមកក្រុមការងារបច្ចេកទេស ន.ស.យ។ ក្នុងករណីពន្យាដល់ថ្ងៃ ៣០ ខែកក្កដា ឆ្នាំ២០១៧ ក្រុមប្រឹក្សាឃុំគួរតែប្រជុំលុបកិច្ចសន្យានេះ រួចយកថវិកានៅសល់រៀបចំគម្រោងថ្មីបន្តទៀត កុំអូសបន្លាយកិច្ចសន្យាយូរពេក។
- គួរឱ្យអ្នកទទួលការដែលឈ្នះក្នុងការដេញថ្លៃឡើងបង្ហាញមុខ និងធ្វើការប្តេជ្ញាចិត្តក្នុងការអនុវត្តកិច្ចសន្យាស្របតាមបទដ្ឋានបច្ចេកទេស គ.ជ.អ.ប និងមានគុណភាពល្អ។
- បន្តរៀបចំសំណុំឯកសារព័ត៌មានគម្រោង និងសំណុំឯកសារកិច្ចសន្យាតាមមាតិកាដែលបានណែនាំ
- បើកវគ្គបណ្តុះបណ្តាលដល់គណៈកម្មការគ្រប់គ្រងគម្រោងពីបច្ចេកទេសនៃការត្រួតពិនិត្យការអនុវត្តគម្រោង (បណ្តោយ ទទឹង កម្រាស់ ការបង្ហាប់...គុណភាពបេតុង .... 6 in 1 Plus)
- TSO ស្មៀន និងអ្នកពាក់ព័ន្ធជួយត្រួតពិនិត្យឯកសារ មុននឹងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។
- ពង្រឹងបន្ថែមអ្នកទទួលការនូវគុណភាព និងទឹកដៃនៃការអនុវត្តកិច្ចសន្យា
- ជួយពន្យល់ ណែនាំដល់គណៈកម្មការគ្រប់គ្រងគម្រោង លោកមេឃុំ ចៅសង្កាត់គួរពិនិត្យ និងជួយថែរក្សាគម្រោងដែលបានសាងសង់រួចហើយ ឱ្យការប្រើប្រាស់មានស្ថេរភាពបានយូរ។
- PIA ជួយបណ្តុះបណ្តាលដល់ TSO ក្នុងការប្រើប្រាស់ប្លង់ថ្មីៗក្នុង NCDD Template ដែលបានកែសម្រួលកន្លងមក និងបទបង្ហាញ 6 in 1 Plus ក្នុងការតាមដានការអនុវត្តគម្រោង
- TSO ទាំងអស់ត្រូវព្យាយាមសិក្សា ស្វែងយល់ឱ្យបានច្រើនពី PIA
- ជួយជំរុញការអនុវត្តគម្រោងក្រុង ស្រុក តាមនីតិវិធី
- ពិចារណាលើសុពលភាពលិខិតប្រាក់កក់ធានាការអនុវត្ត
- ការបញ្ចូលទិន្នន័យក្នុង PID មានការយឺតយ៉ាវ ( 77/69 and 44/69)... លុប ៨សំណើគម្រោង និងបញ្ចូល ២៥កិច្ចសន្យាបន្ថែម។

☞ ក្រុមការងារ ន.ស.យ នឹងចុះពិនិត្យ និងផ្ទៀងផ្ទាត់លើអនុសាសន៍នេះនៅឆ្នាំក្រោយៗ ទៀត។

ក្រុមការងារការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សូមថ្លែងអំណរគុណចំពោះក្រុមការងារខេត្តត្បូងឃ្មុំដែលបានអនុញ្ញាត និងសម្របសម្រួលដំណើរការចុះត្រួតពិនិត្យនេះទទួលបានលទ្ធផលល្អប្រសើរប្រកបដោយកិច្ចសហការជួយជ្រោមជ្រែងពីលោកនាយក នាយករងទីចាត់ការផែនការនិងវិនិយោគខេត្ត លោកទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត លោកទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទោះបីមានភារកិច្ចច្រើនក្នុងខេត្តក៏ឆ្លៀតចូលរួមដែរ នេះជាការជួយពង្រឹងវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិទាំងអស់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧

អ្នកធ្វើរបាយការណ៍

**មិន ស៊ីថា**



កិច្ចប្រជុំឆ្លុះបញ្ចាំងពីលទ្ធផលនៃការតាមដានត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ខេត្តត្បូងឃ្មុំ

## Uch Chan Vuthy

| | |
|---|---|
| **From:** | Uch Chan Vuthy |
| **Sent:** | Tuesday, 11 July, 2017 8:23 AM |
| **To:** | 'va.kimheng@tkm.ncdd.gov.kh'; Bunytry |
| **Cc:** | Lim Haing Kry; 'bunhengbunheng@yahoo.com'; 'min.sitha@yahoo.com'; 'saysinoun@gmail.com'; 'Mang Hong Kry' |
| **Subject:** | Summary report of Mission to TKM follow up CSF & DMF Implementation |
| **Attachments:** | Summary Report of CSF & MDF Monitoring in TKM .pdf |

សួស្តី បងគឹមហេង និងលោកប៊ុនអ៊ី,
ក្រុមការងារបច្ចេកទេស ន.ស.យ បានរៀបចំរបាយការណ៍ដែលយើងបានចុះត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់នៅខេត្តត្បូងឃ្មុំរួចហើយ ខ្ញុំសូមផ្ញើជូនបងៗជ្រាបជាព័ត៌មាន និងអនុវត្តបន្តនូវអ្វីដែលខ្វះខាតតាមអនុសាសន៍ដើម្បីធ្វើការកែលម្អការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ស្របតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។
សូមអរគុណណាស់ចំពោះការសហការក្នុងបេសកកម្មនេះ !
អ៊ុច ច័ន្ទវុឌ្ឍី

---

**From:** Uch Chan Vuthy
**Sent:** Tuesday, 20 June, 2017 11:14 AM
**To:** Bunytry
**Subject:** RE: Mission to TKM follow up CSF 2016 Implementation

Dear Bun Y,
Thanks for your confirmed.
See you next week !
Vuthy

---

**From:** trybuny [mailto:bunytry@tkm.ncdd.gov.kh]
**Sent:** Tuesday, 20 June, 2017 11:07 AM
**To:** Uch Chan Vuthy; va.kimheng@tkm.ncdd.gov.kh
**Cc:** 'Mang Hong Kry'; Lim Haing Kry; bunhengbunheng@yahoo.com; min.sitha@yahoo.com; saysinoun@gmail.com
**Subject:** RE: Mission to TKM follow up CSF 2016 Implementation

Dear Bong Chanvuthy,
Be confirmed to receive and action.
Regards,

Mr.Try Bun Y
Provincial Program Management Adviser (PPMA)
National Committee for Sub-National Democratic Development (NCDD)
Salakhet Compound, Tboung Khmum Province.
Email:bunytry@tkm.ncdd.gov.kh
Personal email:bunytry@gmail.com
Tel: 012 573 003/081 450 818

---

**From:** Uch Chan Vuthy [mailto:chanvuthy@ncdd.gov.kh]
**Sent:** Tuesday, June 20, 2017 10:44 Morning
**To:** va.kimheng@tkm.ncdd.gov.kh; Bunytry

**Cc:** 'Mang Hong Kry'; Lim Haing Kry; bunhengbunheng@yahoo.com; min.sitha@yahoo.com; saysinoun@gmail.com
**Subject:** Mission to TKM follow up CSF 2016 Implementation

សួស្តីបងគឹមហេង និងលោកប៊ុនអ៊ី,

ជូសមុខឱ្យក្រុមការងារនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ ខ្ញុំសូមជម្រាបជូនក្រុមការងារផអ៣ ខេត្តត្បូងឃ្មុំថា ក្រុមការងារបច្ចេកទេសការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់នឹងចុះពិនិត្យ និងតាមដានការអនុវត្ត គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ នៅខេត្តត្បូងឃ្មុំ ចាប់ពីថ្ងៃទី២៦ ដល់ទី៣០ ខែមិថុនា ឆ្នាំ២០១៧ ដូចបង្ហាញជូនក្នុង លិខិតបង្គាប់ការ។ ក្រុមការងារបច្ចេកទេសគាំទ្រគម្រោងលក្រុង ស្រុក ឃុំ សង្កាត់នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់នឹងពិនិត្យលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងស្រុកឆ្នាំ២០១៦ មួយចំនួនដូចមានបង្ហាញក្នុងកាល វិភាគសកម្មភាពការងារដែលភ្ជាប់ជូន រួមទាំងគម្រោងឆ្នាំ២០១៧។

<u>សម្គាល់</u>៖

- សូមរៀបចំឯកសារសំណើគម្រោងមូលនិធិឃុំ សង្កាត់ និងឯកសារកិច្ចសន្យានៃគម្រោងទាំង៧ឃុំ សង្កាត់ និងស្រុក មួយ សម្រាប់ក្រុមការងារថ្នាក់ជាតិពិនិត្យ។
- ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត ជួយរៀបចំឧបករណ៍ DCP មួយគ្រឿង ឧបករណ៍តេស្តបេតុងមួយគ្រឿង និងខ្សែម៉ែត្រ ៧,៥ម និង៥0ម សម្រាប់ចុះពិនិត្យជាក់ស្តែង។

សូមអរគុណទុកជាមុនចំពោះកិច្ចសហការ !

អ៊ុច ច័ន្ទវុឌ្ឍី

---

Virus-free. www.avast.com

# របាយការណ៍សង្ខេបស្តីពីចូលរួមតាមដាន និងវាយតម្លៃគម្រោង
# សាងសង់អគារសិក្សា ឆ្នាំ២០១៥ នៅឃុំត្រមូង ស្រុកមេមត់

## ១. សេចក្តីផ្តើម

យោងរបាយការណ៍ស្តីពីការចុះតាមដានការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់នៅខេត្តត្បូងឃ្មុំកាលពីថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រុមការងារសវនកម្មក្រសួងមហាផ្ទៃ និងយោងអនុសាសន៍ក្រុមការងារក្រសួងមហាផ្ទៃ ក្រុមការងារថ្នាក់ខេត្តដែលមានទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ និងគណៈកម្មការគ្រប់គ្រងគម្រោងឃុំត្រមូងព្រមទាំងតំណាងអ្នកទទួលផលមួយចំនួនទៀតបានចូលរួមពិនិត្យនិងវាយតម្លៃបញ្ចប់១០០% គម្រោងសាងសង់អគារសិក្សា ឆ្នាំ២០១៥ នៅទីតាំងគម្រោងក្នុងឃុំត្រមូង ស្រុកមេមត់។

## ២. គោលបំណង

ការចូលរួមពិនិត្យគម្រោងសាងសង់អគារសិក្សាឆ្នាំ២០១៥ ដែលបានបន្លាយពេលវេលាយ៉ាងយូររបស់អ្នកទទួលការមានគោលបំណង៖

- ✓ ពិនិត្យមើលការសាងសង់បំពេញបន្ថែមរាល់ចំនុចខ្វះខាតមួយចំនួនដែលនៅសេសសល់តាមការណែនាំរបស់ក្រុមការងារក្រសួងមហាផ្ទៃ និងតាមការសន្យារបស់អ្នកទទួលការក្នុងអង្គប្រជុំកាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៧ នៅទីតាំងគម្រោង។
- ✓ ចូលរួមប្រជុំជាមួយគណៈកម្មការគ្រប់គ្រងគម្រោងដើម្បីលុបកិច្ចសន្យាចោលតាមការណែនាំរបស់ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធក្រសួងមហាផ្ទៃប្រសិនបើអ្នកទទួលការមិនបានបញ្ចប់ការងារដែលនៅសេសសល់ត្រឹមថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ ទេនោះ ។
- ✓ ចូលរួមប្រជុំវាយតម្លៃគម្រោងបញ្ចប់ការសាងសង់១០០% ប្រសិនបើចំនុចខ្វះខាតដែលនៅសេសសល់ត្រូវបានបញ្ចប់ ។

## ៣. សង្ខេបសកម្មភាពការងារ

សកម្មភាពមន្ត្រី ទីប្រឹក្សា គណៈកម្មការគ្រប់គ្រងគម្រោង និងអ្នកពាក់ព័ន្ធ៖

| ល.រ | ឈ្មោះអ្នកចូលរួម | តួនាទី | អង្គភាព |
|---|---|---|---|
| ១ | លោក វិញ នី | មេឃុំត្រមូង និងជាប្រធានគណៈកម្មការគ្រប់គ្រងគម្រោង | ឃុំត្រមូង ស្រុកមេមត់ |
| ២ | លោកស្រី សៀក ហេង | សមាជិកគណៈកម្មការគ្រប់គ្រងគម្រោងឃុំ | ឃុំត្រមូង ស្រុកមេមត់ |
| ៣ | លោកស្រី យឹម គឹមស៊ាន | សមាជិកគណៈកម្មការគ្រប់គ្រងគម្រោងឃុំ | ឃុំត្រមូង ស្រុកមេមត់ |
| ៣ | លោក ឈិត ហៃ | ស្មៀនឃុំត្រមូង | ឃុំត្រមូង ស្រុកមេមត់ |
| ៤ | លោក មិត្ត ផល្លី | មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធប្រចាំស្រុកមេមត់ | សាលាខេត្តត្បូងឃ្មុំ |
| ៥ | លោក ម៉ង់ ហុងគ្រី | ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្តត្បូងឃ្មុំ | ក្រសួងមហាផ្ទៃ/គ.ជ.អ.ប |

ក្នុងការចុះពិនិត្យ និងវាយតម្លៃនេះមានពីរជំហ៊ាន៖

- ✓ ពិនិត្យមើលការបំពេញបន្ថែមចំនុចខ្វះខាតដែលនៅសេសសល់ដែលបានណែនាំដោយក្រុមការងារក្រសួងមហាផ្ទៃក្នុងអង្គប្រជុំកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ នៅទីតាំងគម្រោង។
- ✓ ប្រជុំវាយតម្លៃ និងសម្រេចរបស់គណៈកម្មការគ្រប់គ្រងគម្រោងដើម្បីបញ្ចប់ការសាងសង់១០០%

## ៤. ការងារដែលបានបំពេញបន្ថែម

- ✓ តុគ្រូចំនួន២ និងកៅគ្រូចំនួន២ បានសាងសង់រួច
- ✓ ធ្នឹមបេតុងបានបូកសម្អាត និងលាបថ្នាំរួចតាមការណែនាំ
- ✓ ស្លាបព្រិលទ្វារ និងបង្អួចដែលពុកខូចខាតត្រូវបានជួសជុលនិងប្តូរថ្មីរួច
- ✓ ការសម្អាតមុខអគារសិក្សាបានបញ្ចប់

## ៥. ការងារដែលមិនទាន់បានបញ្ចប់

- ✓ កន្ទុយដែកដែលទុកបន្តអគារថ្មីនៅខាងក្រៅអគារមិនទាន់បានពត់តាមការណែនាំ
- ✓ ជម្រាលសម្រាប់សិស្សពិការមិនទាន់បានកែសម្រួលតាមការណែនាំ

✓ ស្លាកសញ្ញាគម្រោងមិនទាន់បានបំពាក់តាមការណែនាំ

## ៦. អនុសាសន៍

អ្នកទទួលការត្រូវបំពេញបន្ថែមការងារដែលនៅសេសសល់ដូចបានរៀបរាប់ក្នុងចំនុចទី៥ ឲ្យបានចប់១០០% ជាមុនសិនមុនធ្វើការទូទាត់ជូនអ្នកទទួលការ ។

ត្បូងឃ្មុំ ថ្ងៃទី០២ ខែ សីហា ឆ្នាំ២០១៧

អ្នកធ្វើរបាយការណ៍

**ម៉ង់ ហុងគ្រី**

## ៦.ឧបសម្ព័ន្ធ រូបថត

- ទ្វារនិងបង្អួចបានជួសជុលរួច





- ការចូលរួមប្រជុំជាមួយគណៈកម្មការគ្រប់គ្រងគម្រោង





- តុ និងកៅអីគ្រូបានបំពាក់រួច



- ធ្នឹមបេតុងបានបូកសម្អាត និងបានលាបថ្នាំ



- កន្ទុំដែកខាងក្រៅអគារមិនទាន់បានពត់ឲ្យបានត្រឹមត្រូវ



# ឧបសម្ព័ន្ធទី២

## របាយការណ៍ស្តីពីការសិក្សាពីករណីមិនប្រក្រតី និងអនុសាសន៍

**ក) នៅខេត្តព្រៃវែង (ករណីគម្រោងអនុវត្តយឺត)**

1. របាយការណ៍ស្តីពីការចុះតាមដានការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់នៅខេត្តព្រៃវែង
2. ការបំភ្លឺពីខេត្តព្រៃវែងតាមអនុសាសន៍ណែនាំក្នុងរបាយការណ៍

**ខ) នៅរាជធានីភ្នំពេញ (ករណីអ្នកទទួលការប្តឹង)**

1. បណ្តឹងរបស់អ្នកទទួលការ (ក្រុមហ៊ុន VP)
2. របាយការណ៍ស្តីពីការសិក្សាស្រាវជ្រាវពាក្យបណ្តឹងរបស់ក្រុមហ៊ុន VP នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
3. លិខិតជម្រាបជូនឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ
4. លិខិតជម្រាបជូនលោកអភិបាលនៃគណៈអភិបាលខណ្ឌសែនសុខ

# របាយការណ៍ ស្តីពីការចុះតាមដានការអនុវត្តគម្រោង
# មូលនិធិឃុំ សង្កាត់នៅខេត្តព្រៃវែង ថ្ងៃទី ០៨-១២ ខែឧសភា ឆ្នាំ២០១៧

## ១. សេចក្តីផ្តើម

យោងសេចក្តីណែនាំលេខ០០១សណន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ចុះហត្ថលេខាដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងយោងលិខិតបេសសកម្មលេខៈ ៥៦០លបក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានចាត់តាំងមន្ត្រីការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ (ន.ស.ឃ) ចំនួន៣រូប និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ១រូប ឱ្យទៅបំពេញបេសកកម្មស្តីពីការចុះតាមដានការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់រយៈពេលចាប់ពីថ្ងៃទី០៨ ដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧ នៅខេត្តព្រៃវែង។ ការចុះបំពេញបេសកម្មនេះគឺ ដើម្បីពន្លឿនការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ ដែលនៅសេសសល់របស់រដ្ឋបាលឃុំ សង្កាត់បានទាន់ពេលវេលា ត្រឹមត្រូវតាមនីតិវិធី និងបទដ្ឋានបច្ចេកទេស។

## ២. គោលបំណង

ការចុះបេសសកម្មនេះស្ថិតក្នុងសកម្មភាពលេខ ២.៤.២.១.៥ នៃសេចក្តីសម្រេចរួម 27/MoI/1701-00 (IP3-II) ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ក្រោមក្របខណ្ឌផអ៣ទី២មានគោលបំណង៖

- ✓ ពង្រឹងការអនុវត្តតួនាទី ភារកិច្ចដល់អ្នកពាក់ព័ន្ធក្នុងដំណើរការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ✓ ជំរុញការអនុវត្តគម្រោងឱ្យទាន់ពេលវេលា និងត្រឹមត្រូវតាមនីតិវិធី និងបទដ្ឋានបច្ចេកទេស
- ✓ ស្វែងរកភាពមិនប្រក្រតី និងចំណុចខ្វះខាតនានាក្នុងការអនុវត្តគម្រោង និងធ្វើការកែលម្អ

## ៣. សង្ខេបសកម្មភាពការងារ

សមាសភាពមន្ត្រី និងទីប្រឹក្សាដែលបានចុះបេសសកម្មជាក់ស្តែងមានចំនួន៤រូប ដូចខាងក្រោម៖

| ល.រ | ឈ្មោះមន្ត្រី | តួនាទី | អង្គភាព |
|---|---|---|---|
| ១ | លោក មិន ស៊ីថា | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| ២ | លោក សាយ ស៊ីនួន | អនុប្រធានការិយាល័យ | នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| ៣ | លោក ចំរើន ពិសិដ្ឋ | មន្ត្រីការិយាល័យរដ្ឋបាល | នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ |
| ៤ | លោក អ៊ុច ច័ន្ទវុឌ្ឍី | ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ | MoI/NCDD |

ក្នុងការចុះត្រួតពិនិត្យនេះក្រុមការងារ ន.ស.ឃ បានបែងចែកជាពីរដំណាក់កាល នៅដំណាក់កាលទីមួយគឺពិនិត្យឯកសារគម្រោង និងដំណាក់កាលទីពីរគឺចុះពិនិត្យនៅទីតាំងសាងសង់គម្រោងជាក់ស្តែង។ ក្នុងដំណាក់កាលពិនិត្យឯកសារគម្រោងក្រុមការងារ ន.ស.ឃ បានជ្រើសរើស និងពិនិត្យឯកសារចំនួន៤គម្រោង និងចុះត្រួតពិនិត្យផ្ទាល់នៅទីតាំងអនុវត្តគម្រោងជាក់ស្តែងទាំង៤គម្រោង ស្មើនឹង៣ឃុំ ១ស្រុក គឺនៅឃុំរំចេក ក្នុងស្រុកព្រះស្តេច ឃុំព្រែកខ្សាយ ក ក្នុងស្រុកពាមរក៍ ឃុំព្រែកចង្ក្រាន ក្នុងស្រុកស៊ីធរកណ្តាល និងគម្រោងស្រុកស៊ីធរកណ្តាល ក្នុងខេត្តព្រៃវែង។

ក្រោយពីបានពិនិត្យឯកសារចំនួន៧គម្រោងក្រុមការងារបានរកឃើញដូចបង្ហាញខាងក្រោម៖

- មានសំណុំឯកសារព័ត៌មានគម្រោង និងកិច្ចសន្យាគ្រប់ឃុំ សង្កាត់
- សំណុំឯកសារព័ត៌មានគម្រោង និងកិច្ចសន្យាមិនរៀបតាមមាតិកាដែលបានណែនាំ(មានដាក់មាតិកា តែមិនរៀបតាម) និងមិនបានកៀបជាសៀវភៅ (គ្រាន់តែកៀបដោយ Binder Clip)
- ការដាក់ឈ្មោះគម្រោងមិនដូចគ្នា ចំពោះគម្រោងតែមួយ
- មិនបានប្រថាប់ត្រារដ្ឋបាលខេត្តលើផែនទីគម្រោងទេ ( ពិបាកសុំប្រថាត្រាខេត្ត ដូច្នេះសម្រេចប្រថាប់ត្រាឃុំគ្រប់គម្រោងទាំងអស់)
- មិនបានដាក់ការបរិយាយលម្អិតបច្ចេកទេសសម្រាប់សាងសង់នៅក្នុងកិច្ចសន្យាខ្លះ
- លិខិតធានាប្រាក់កក់អនុវត្តមិនមានសុពលភាពគ្រប់៦ខែក្រោយបញ្ចប់ការសាងសង់ )បានដកលិខិតធានាប្រាក់កក់អនុវត្តឱ្យ TSO រក្សាទុក)

ក្រោយពីបានពិនិត្យឯកសាររួចរាល់ហើយក្រុមការងារបានចុះត្រួតពិនិត្យផ្ទាល់នៅទីតាំងអនុវត្តគម្រោងជាក់ស្តែងចំនួន៤គម្រោង លទ្ធផលដែលបានរកឃើញបង្ហាញតាមគម្រោងនីមួយៗដូច ខាងក្រោម៖

### ៣.១. ឃុំរំចេក ស្រុកព្រះស្តេច

- <u>កិច្ចសន្យា</u>៖ ជួសជុលផ្លូវលំដីស និងក្រាលខ្សាច់ភ្នំ ៣.៤០០ម ទទឹង៦ម ដាក់លូមូល១កន្លែង
- <u>ជាក់ស្តែង</u>៖ ចុះពិនិត្យនៅពេលអនុវត្តគម្រោងបាន > ៥០% និងមិនទាន់ដាក់លូគម្រោងកំពុងអនុវត្តបានប្រមាណ(>៥០%) និងមិនបានពន្យាកិច្ចសន្យាទេ (ក្នុងកិច្ចសន្យាចាប់ផ្តើមអនុវត្តថ្ងៃទី២០/០៨/២០១៦ ដល់ថ្ងៃទី២០/១០/២០១៦)
- មូលហេតុអនុវត្តយឺតដោយសារ ១) ទីតាំងយកដីស ក្បែរផ្លូវប្រជាជនមិនទាន់ច្រូតស្រូវ និងមានទឹក ២) ដីដែលកាយដាក់លើផ្លូវហើយ តែសើម មិនអាចឈូសឆាយបាន គួបផ្សំភ្លៀងឆ្នាំនេះធ្លាក់ដើមឆ្នាំផង ៣) ពេលដឹកខ្សាច់ចូលការដ្ឋាន ឡានដឹកខ្សាច់ត្រូវដឹកតាមផ្លូវជាតិលេខ១ ដឹកខ្សាច់ហួសកម្រិតទម្ងន់កំណត់ខាងជញ្ជីងចល័តចាប់ (ដឹកតាមការកំណត់របស់ក្រសួងមិនចំណេញ)។
- ក្រុមការងារ ន.ស.យ និងក្រុមការងារខេត្តបានជួបជាមួយលោកមេឃុំ មេភូមិ គណៈកម្មការគ្រប់គ្រងគម្រោង តំណាងអ្នកទទួលការ និងសំណូមពរឱ្យជួយពន្លឿនការអនុវត្តឱ្យបានចប់មុនថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧នេះ ហើយតំណាងអ្នកទទួលការក៏បានសន្យាថានឹងព្យាយាមបញ្ចប់ឆាប់ៗនេះដែរ។
- លទ្ធផល៖ បានចាក់ និងឈូសឆាយ កិនបង្ហាប់ដីសរួចរាល់អស់ហើយ និងបានចាក់ខ្សាច់ភ្នំ ឈូសឆាយពង្រាយបាន៥/៦នៃប្រវែងផ្លូវហើយ (កាលពីថ្ងៃទី០៩/០៥/២០១៧)។







កិច្ចប្រជុំពិភាក្សា និងពន្លឿនការអនុវត្តគម្រោងនៅឃុំរំចេក ស្រុកព្រះស្តេច

## ៣.២. ឃុំព្រែកខ្សាយ ក ស្រុកពាមរក៍

- <u>កិច្ចសន្យា</u>៖ សាងសង់លូដោះទឹកជ្រុង ប្រវែង៣២២ម ទទឹង០.៥ម។
- <u>ជាក់ស្តែង</u>៖ សាងសង់ហើយ ១០០% ប្រវែងបណ្តោយ និងទទឹងគ្រប់តាមកិច្ចសន្យា និងគុណភាព ទទួលយកបាន គម្រោងស្ថិតក្នុងរយៈពេលធានាការអនុវត្ត៦ខែ។
- មានស្លាកសញ្ញាគម្រោងល្អ...តែដាក់លើតួផ្លូវ
- គណៈកម្មការគ្រប់គ្រងគម្រោង និងក្រុមប្រឹក្សាឃុំសហការគ្នាបានល្អ





## ៣.៣. ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្តាល

- <u>កិច្ចសន្យា</u>៖ ជួសជុលផ្លូវដីស ប្រវែង ១.១០០ម ទទឹង៤ម និងដាក់លូមូល១កន្លែង
- <u>ជាក់ស្តែង</u>៖ អនុវត្តហើយ ១០០% **ត្រឹមត្រូវតាមកិច្ចសន្យា។** ផុតរយៈពេលថែទាំ៦ខែ
- ភាពធន់នៃបេតុងលូ ពី២៥-៣០Mpa ទទួលយកបាន តែទឹកដៃសាងសង់ នៅមានកម្រិត។
- ស្លាកសញ្ញាគម្រោងល្អ។ ការដេញថ្លៃមិនមានការប្រកួតប្រជែង (ចុះ0.៦៧%)





### ៣.៤. គម្រោងស្រុកស៊ីធរកណ្ដាល

- ផ្លូវក្រាលខ្សាច់ភ្នំ ប្រវែង ១.១០០ម ទទឹង៤,៥ម។ សាងសង់បញ្ចប់១០០% តែស្ថិតក្នុងរយៈពេលថែទាំ
- ប្រវែងបណ្ដោយវាស់ជាក់ស្ដែងបាន ១.២៣០ម លើស ១៣០ម
- ជាទូទៅទទឹងផ្លូវបានតែ ៤-៤,១ម ខ្លះទទឹងផ្លូវពី ០,៥ម
- មានស្លាកសញ្ញាគម្រោងល្អ, គុណភាពផ្លូវ ទទួលយកបាន !





## ៤. កិច្ចប្រជុំឆ្លុះបញ្ចាំង

ក្រោយពីបានពិនិត្យឯកសារសំណើគម្រោង ឯកសារកិច្ចសន្យា និងលទ្ធផលនៃចុះត្រួតពិនិត្យផ្ទាល់នៅទីតាំងអនុវត្តគម្រោង ក្រុមការងារថ្នាក់ជាតិបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងដើម្បីបង្ហាញលទ្ធផលនៃការត្រួតពិនិត្យដល់ថ្នាក់ខេត្ត ដើម្បីរាយការណ៍ អំពីលទ្ធផលនៃការត្រួតពិនិត្យដែលមានការចូលរួមពី នាយក នាយករងទីចាត់ការផែនការនិងវិនិយោគខេត្ត ប្រធានទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ មន្ត្រីគាំទ្រឃុំ សង្កាត់និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធទាំងអស់ក្នុងខេត្ត។

ការបង្ហាញបានលើកឡើងនូវចំណុចដែលបានអនុវត្តល្អ និងចំណុចដែលអនុវត្តមិនបានត្រឹមត្រូវដើម្បីកែលម្អការអនុវត្ត និងផ្ដល់អនុសាសន៍មួយចំនួន។ ក្នុងកិច្ចប្រជុំនេះក៏បានស្ដាប់នូវការបកស្រាយ និងធ្វើការកែតម្រូវនូវអ្វីដែលក្រុមការងារថ្នាក់ខេត្តបានពន្យល់សមហេតុផល។ ខេត្តសន្យាថានឹងខិតខំបន្តទៀត និងយកចិត្តទុកដាក់ពង្រឹងគុណភាពលើការអនុវត្តគម្រោងនៅថ្ងៃអនាគត។

## ៥. សំណូមពរពីខេត្ត

ស្នើសុំឧបករណ៍ វាស់ស្ទង់ (ម៉ាស៊ីនតូប៉ូ) និងឌីស៊ីភី

## ៦. អនុសាសន៍

- ពន្លឿនការអនុវត្តគម្រោងឃុំរំចេកឱ្យបានចប់មុនថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០១៧ ! ពិនិត្យឡើងវិញនូវទទឹងផ្លូវ ក្រោយគៀរ កិនបង្ហាប់ខ្សាច់ភ្នំ ជើងទេរផ្លូវសងខាងត្រូវគៀរ និងបង្ហាប់មុនដាំស្មៅ រៀបចំធ្វើការកែសម្រួលកិច្ចសន្យា ឱ្យមានសុពលភាពឡើងវិញ។
- បន្តរៀបចំសំណុំឯកសារព័ត៌មានគម្រោង និងសំណុំឯកសារកិច្ចសន្យាតាមមាតិកាដែលបានណែនាំ
- ការដាក់ឈ្មោះគម្រោងគួរឱ្យសមរម្យ និងដូចគ្នាចំពោះគម្រោងតែមួយ

- បើកវគ្គបណ្តុះបណ្តាលដល់គណៈកម្មការគ្រប់គ្រងគម្រោងពីបច្ចេកទេសនៃការត្រួតពិនិត្យការអនុវត្តគម្រោង (បណ្តោយ ទទឹង កម្រាស់ ការបង្ហាប់...គុណភាពបេតុង .... 6 in 1 Plus)
- គួរបង្កើនការត្រួតពិនិត្យវាស់បណ្តោយ និងទទឹងផ្លូវឱ្យបានត្រឹមត្រូវតាមកិច្ចសន្យា
- TSO ស្មៀន និងអ្នកពាក់ព័ន្ធជួយត្រួតពិនិត្យឯកសារ មុននឹងដាក់ជូនថ្នាក់ដឹក ពិនិត្យ និងសម្រេច។
- ករណីទទឹងផ្លូវគម្រោងស្រុកស៊ីធរកណ្តាលដែលខ្វះ ០,៥ម អ្នកបច្ចេកទេសគួរពិភាក្សាជាមួយអភិបាលស្រុកឱ្យអ្នកទទួលការធ្វើសង ដោយវាស់បរិមាណម៉ែត្រការ៉េទទឹងដែលខ្វះ (០,៥ម x ១.១០០ម = ៥៥០ម²) រួចធ្វើសងដោយជាបណ្តោយផ្លូវវិញប្រវែង ៥៥០ម² ចែកនឹង៤ម =១៣៨ម។ ករណីមួយទៀតក្រុមការងារបានវាស់ឃើញបណ្តោយផ្លូវលើស១៣០ម **ដូច្នេះអ្នកទទួលការត្រូវធ្វើសងតែ៨ម បណ្តោយ និងបំពេញកន្លែងផ្លូវរទេះដែលបែកចេញពីផ្លូវនេះមួយចំនួន** (ព្រោះកន្លែងនោះផត)។
- ពង្រឹងបន្ថែមអ្នកទទួលការនូវគុណភាព និងទឹកដៃនៃការអនុវត្តកិច្ចសន្យា
- ជួយពន្យល់ ណែនាំដល់គណៈកម្មការគ្រប់គ្រងគម្រោង លោកមេឃុំ ចៅសង្កាត់គួរពិនិត្យ និងជួយថែរក្សាគម្រោងដែលបានសាងសង់រួចហើយ ឱ្យការប្រើប្រាស់មានស្ថេរភាពបានយូរ។
- PIA ជួយបណ្តុះបណ្តាលដល់ TSO ក្នុងការប្រើប្រាស់ប្លង់ថ្មីៗក្នុង NCDD Template ដែលបានកែសម្រួលកន្លងមក និងបទបង្ហាញ 6 in 1 Plus ក្នុងការតាមដានការអនុវត្តគម្រោង
- TSO ទាំងអស់ត្រូវព្យាយាមសិក្សា ស្វែងយល់ឱ្យបានច្រើនពី PIA
- ជួយជំរុញការអនុវត្តគម្រោងក្រុង ស្រុក តាមនិតិវិធី
- បង្កើតគណៈកម្មការសវនកម្មបច្ចេកទេសខេត្ត ដើម្បីត្រួតពិនិត្យការអនុវត្តគម្រោង !

☞ ក្រុមការងារ ន.ស.យ នឹងចុះពិនិត្យ និងផ្ទៀងផ្ទាត់លើអនុសាសន៍នេះនៅឆ្នាំក្រោយៗ ទៀត។

ក្រុមការងារការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សូមថ្លែងអំណរគុណចំពោះក្រុមការងារខេត្តព្រៃវែងដែលបានអនុញ្ញាត និងសម្របសម្រួលដំណើរការចុះត្រួតពិនិត្យនេះទទួលបានលទ្ធផលល្អប្រសើរប្រកបដោយកិច្ចសហការជួយជ្រោមជ្រែងពីលោកនាយក នាយករងទីចាត់ការផែនការនិងវិនិយោគ លោកទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត លោកទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទោះបីមានភារកិច្ចច្រើនក្នុងខេត្តក៏ឆ្លៀតចូលរួមដែរ នេះជាការជួយពង្រឹងវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិទាំងអស់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧

អ្នកធ្វើរបាយការណ៍



**សាយ ស៊ីនួន**

# ការបំភ្លឺពីខេត្តព្រៃវែង

## តាមអនុសាសន៍ណែនាំក្នុងរបាយការណ៍




សកម្មភាពចុះត្រួតពិនិត្យបញ្ចប់ការអនុវត្តគម្រោងជួសជុលផ្លូវក្រាលខ្សាច់ភ្នំ ៣.៤០០ម៉ែត្រ របស់ទីចាត់ការផែនការ និងវិនិយោគខេត្ត និងក្រុមការងារបច្ចេកទេស កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧




ស្ថានភាពផ្លូវក្រោយចាក់ក្រាលខ្សាច់ភ្នំ គៀរ កិនបង្ហាប់រួចរាល់ (ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧)








សូមអរគុណក្រុមការងារផអពខេត្តព្រៃវែងក្នុងការជួយជម្រុញការងារគម្រោងមូលនិធិឃុំ សង្កាត់អនុវត្តទាន់ពេលវេលា និងមានគុណភាពល្អ។

នាយកដ្ឋានកិច្ចការ
រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
ចូល
លេខ:....244....ម៉ោង........
ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ២០ 17
បញ្ជូនទៅ.........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹង

ខ្ញុំបាទឈ្មោះ សេន ហេង ភេទប្រុស អាយុ៥៩ឆ្នាំ ជាប្រធានក្រុមហ៊ុន VP មានលេខរៀង 38 ចុះបញ្ជីក្នុងខេត្តកំពង់ស្ពឺ ។

### សូមគោរពជូន

លោកប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់

កម្មវត្ថុ: សម្រេចប្ដឹង ប្រធានគណៈកម្មការលទ្ធកម្មសង្កាត់ ភ្នំពេញ ថ្មីបានបញ្ឈប់កិច្ចសន្យាជាមួយក្រុមហ៊ុន VPខ្ញុំបាទលើគម្រោងមូលនិធិសង្កាត់ឆ្នាំ២០១៧ ។

សេចក្ដីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា៖ គម្រោងមូលនិធិសង្កាត់ភ្នំពេញថ្មីឆ្នាំ២០១៧ ខ្ញុំបាទធ្វើការដេញថ្លៃក្នុងតម្លៃ 499 696 000រៀលទាបទី១ កាលពីថ្ងៃ២៥ខែឧសភាឆ្នាំ២០១៧តែរហូតដល់ពេលនេះ ចៅសង្កាត់មិនព្រមចុះកិច្ចសន្យាគម្រោងទេ ដោយមានការឃុបឃិតជាមួយអ្នកទទួលការដេញថ្លៃជាប់ លំដាប់លេខរៀងទី២អនុញ្ញាតអោយដកលិខិតកក់ប្រាក់ធានាការដេញថ្លៃ២%ក្រោយពេលបញ្ចប់ការប្រកាសលទ្ធផលភ្លាមៗ និងបានបង្ខំអោយក្រុមហ៊ុនខ្ញុំបាទអនុវត្តខុសជាច្រើនដូចក្រោម៖

១/ ចៅសង្កាត់បានបង្ខំអោយនាំគ្រឿងចក្រមកបើកការដ្ឋានសាងសង់មុនចុះកិច្ចសន្យាចំនួនពីរដងគឺនៅថ្ងៃទី៣១ខែឧសភាឆ្នាំ២០១៧នៅភូមិរោងចក្រម្ដង និងលើកទីពីរ ថ្ងៃទី០១ខែមិថុនាឆ្នាំ២០១៧នៅភូមិទំនប់ដែលមានសមាសភាពចូលរួម លោកអភិបាលខ័ណ្ឌសែនសុខ លោកមន្ត្រីបច្ចេកទេសរាជធានី លោកចៅសង្កាត់ លោកមេភូមិ ប្រជាពលរដ្ឋនិង អ្នកសារព័ត៌មាន(ដូចមានភ្ជាប់រូបថតបើកការដ្ឋានសាងសង់ខាងក្រោយស្រាប់)។

២/ នៅថ្ងៃទី២៦ខែមិថុនាឆ្នាំ២០១៧ដោយយោងតាមលិខិតទម្រង់៨៨ចុះលេខ០០៥ស.ជ.ណ.ខ្ញុំបាទជាអ្នកទទួលការបានមកដល់សាលាសង្កាត់ភ្នំពេញថ្មីដើម្បីចុះកិច្ចសន្យាគម្រោងមូលនិធិសង្កាត់ឆ្នាំ២០១៧មិនបានជួបចៅសង្កាត់ក្នុងពេលម៉ោងធ្វើការងារនោះទេហើយជួបតែមន្ត្រីបច្ចេកទេសរាជធានី និង ស្មៀនសង្កាត់ ហេតុដូច្នេះហើយបានជាក្រុមហ៊ុនខ្ញុំបាទមិនបានចុះកិច្ចសន្យា។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកប្រធាន** មេត្តា ជួយផ្ដល់អនុសាសន៍និងបន្តការចុះកិច្ចសន្យាគម្រោងជាមួយចៅសង្កាត់ភ្នំពេញថ្មីដោយសេចក្ដីនុគ្រោះផងចុះ ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរព រាប់អានដ៏ខ្ពង់ខ្ពស់អំពី ខ្ញុំបាទ ។

ធ្វើនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៧

ប្រធានក្រុមហ៊ុនVP

ក្រុមហ៊ុន V.P

សេន_ហេង

30/06/17

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល
នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
លេខ...២៨៥២...ស.ក/ន.ស.យ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល
លេខ 1059 ម៉ោង 10h30
ថ្ងៃទី 09 ខែ 08
ចុះថ្ងៃទី 28.08.17

រាជធានីភ្នំពេញ ថ្ងៃទី...០៩......ខែ...សីហា.....ឆ្នាំ២០១៧

## សូមគោរពជូន

**ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីការចុះសិក្សាស្រាវជ្រាវតាមពាក្យបណ្តឹងរបស់ក្រុមហ៊ុនVPនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

III.04.09-

**យោង** ÷ - ពាក្យបណ្តឹងរបស់ក្រុមហ៊ុន VP ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧
- លិខិតបង្គាប់ការលេខ ៦៨៧ ល.ប.ក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមអនុញ្ញាតគោរពជម្រាបជូនឯកឧត្តមអគ្គនាយក មេត្តាជ្រាបថា ក្រុមការងាររបស់នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធក្រសួងមហាផ្ទៃ បានចុះធ្វើការសិក្សាស្រាវជ្រាវតាមពាក្យបណ្តឹងរបស់ក្រុមហ៊ុន VP លើការអនុវត្តនីតិវិធីលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ក្រុមការងាររបស់នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធក្រសួងមហាផ្ទៃ បានជួបជាមួយគណៈកម្មការលទ្ធកម្ម ចៅសង្កាត់ចាស់ ចៅសង្កាត់ថ្មី មេភូមិដែលទទួលផលពីគម្រោង មន្ត្រីគាំទ្រសង្កាត់នៃទីចាត់ការផែនការ និងវិនិយោគរាជធានីភ្នំពេញ ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធរាជធានីភ្នំពេញ និងអ្នកពាក់ព័ន្ធមួយចំនួនទៀតសរុប ១៤នាក់។

ផ្អែកតាមចម្លើយ និងការស្រាយបំភ្លឺពីលោកចៅសង្កាត់ចាស់ (លោក ជុំ សារ៉ាយ) និងអ្នកពាក់ព័ន្ធ ក្រុមការងាររបស់នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធក្រសួងមហាផ្ទៃ បានរកឃើញថា៖

១. ការដេញថ្លៃបានប្រព្រឹត្តិទៅដោយជោគជ័យនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ដោយមានអ្នកទទួលការចូលរួមដេញចំនួន៧ក្រុមហ៊ុន។ លទ្ធផលដែលមានតម្លៃទាប និងឈ្នះក្នុងការដេញថ្លៃបានមកលើក្រុមហ៊ុន VP (មានតម្លៃទាបទី១) ក្នុងទឹកប្រាក់ ៤៩៩.៦៩៦.០០០រៀល។

២. តាមពាក្យបណ្តឹងរបស់អ្នកទទួលការបានសរសេរថា ចៅសង្កាត់បានបង្ខំឱ្យអ្នកទទួលការដាក់គ្រឿងចក្របើកការដ្ឋានពីរដង ម្តងនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ នៅភូមិរោងចក្រ និងម្តងទៀតនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ នៅភូមិទំនប់ ដោយមិនទាន់ចុះកិច្ចសន្យាសាងសង់។

៣. នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ចៅសង្កាត់ចាស់បានចេញលិខិតលេខ០០៥ សជណ ស្តីពីការសម្រេចផ្តល់កិច្ចសន្យាដល់ក្រុមហ៊ុន VP (មានតម្លៃទាបទី១) ក្នុងទឹកប្រាក់ ៤៩៩.៦៩៦.០០០ រៀល និងអញ្ជើញមកចុះកិច្ចសន្យានៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង៨:០០ព្រឹក នៅសាលាសង្កាត់ភ្នំពេញថ្មី។ ដល់ព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ លោកចៅសង្កាត់ គណៈ-

កម្មការគ្រប់គ្រងគម្រោងបានរង់ចាំអ្នកទទួលការឈ្មោះ **សេន ហេង** ក្រុមហ៊ុន VP ដល់ម៉ោង ៩:៤០នាទីមិនឃើញមកក៏នាំគ្នារំសាយកិច្ចប្រជុំចុះកិច្ចសន្យានេះចោល(មិនបានប្រជុំទេ)។ ចំណែកអ្នកទទួលការបានបញ្ជាក់ក្នុងពាក្យបណ្ដឹងរបស់ខ្លួនថា បានទៅដល់សង្កាត់ភ្នំពេញថ្មី ក្នុងពេលម៉ោងធ្វើការតែមិនបានជួបចៅសង្កាត់ បានជួបតែមន្ត្រីបច្ចេកទេស និងស្មៀនសង្កាត់ នាថ្ងៃខែឆ្នាំដដែល។

៤. នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ ដដែលចៅសង្កាត់ចាស់បានរៀបចំលិខិត មួយលេខ០០៩ ល.ស/អណព ស្ដីពីសម្រេចបញ្ឈប់ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុន VP លើគម្រោងមូលនិធិសង្កាត់ឆ្នាំ២០១៧ ជម្រាបជូនឯកឧត្តមប្រធានគណៈកម្មការប្រតិបត្តិ និងជាអភិបាលនៃគណៈ-អភិបាលរាជធានីភ្នំពេញ ដើម្បីផ្ដល់អនុសាសន៍ដោយមិនមានការប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងដូចយោងក្នុងកំណត់ហេតុក្នុងលិខិតចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ នោះទេ។

៥. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ ចៅសង្កាត់បានចេញលិខិតលេខ០០៧ សជណ ស្ដីពីការសម្រេចផ្ដល់កិច្ចសន្យាដល់ក្រុមហ៊ុនហែម៉ានីម៉ិចខនស្ត្រាក់សិនក្នុងទឹកប្រាក់៩៤៧.៧៨៨.៨៧២ រៀលដោយមិនរង់ចាំការអនុសាសន៍ពីអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញឡើយ។ សូមបញ្ជាក់ថាក្រុមហ៊ុនហែម៉ានីម៉ិចខនស្ត្រាក់សិនមានតម្លៃទាបទី២ ក្នុងទឹកប្រាក់ដែលបានដេញថ្លៃ ៩៧៥.២១៣.៨៤៧រៀល ដែលមានតម្លៃថ្លៃជាងអ្នកមានតម្លៃទាបទី១ចំនួន៧៥.៥១៧.៨៤៧រៀល។

៦. តាមប្រសាសន៍លោក ជុំ សារ៉ាយ ចៅសង្កាត់ចាស់ថា កិច្ចសន្យាដែលផ្ដល់ដល់អ្នកមានតម្លៃទាបទី២នោះមិនទាន់ចុះអនុវត្តទេ។

**សន្និដ្ឋាន និងយោបល់** ÷ តាមរយៈការរកឃើញទាំង៦ចំណុចខាងលើបញ្ជាក់ថា កិច្ចលទ្ធកម្មនេះមិនស្របតាមនីតិវិធី ហើយហួតមកដល់ពេលនេះសំណើដេញថ្លៃទាំងអស់ត្រូវអស់សុពលភាពគឺលើស៤៥ថ្ងៃ ម្យ៉ាងវិញទៀតការផ្ដល់កិច្ចសន្យាឱ្យអ្នកឈ្នះទី២មិនមានតម្លាភាពទេដូចបានជម្រាបជូនក្នុង(ចំណុចទី៥)ខាងលើ។ ដូច្នេះ ជាយោបល់របស់នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ យល់ឃើញថាអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញគួរចេញសេចក្ដីណែនាំទៅរដ្ឋបាលសង្កាត់ភ្នំពេញថ្មីឱ្យលុបលទ្ធផលដេញថ្លៃនេះចោល ហើយប្រកាសដេញថ្លៃសារជាថ្មីទៅលើទីតាំងគម្រោងដដែល។ ចំពោះប្រាក់កក់ធានាការដេញថ្លៃត្រូវប្រគល់ទៅឱ្យអ្នកទទួលការទាំងអស់វិញ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គនាយក មេត្តាជ្រាបជារបាយការណ៍ និងមានមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។៕

**ប្រធាននាយកដ្ឋាន**

**ជា_ម៉ុនរេន**

អគ្គនាយក

14/09/2017

[illegible] សំរឿន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ: [illegible] អ.រ.ប

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧

## សូមជម្រាបជូន

### ឯកឧត្តម អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

**កម្មវត្ថុ** ៖ សំណើសុំរដ្ឋបាលរាជធានីភ្នំពេញ ចេញសេចក្តីសម្រេចលុបចោលលទ្ធផលដេញថ្លៃនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលសង្កាត់ភ្នំពេញថ្មី និងណែនាំឱ្យរដ្ឋបាលសង្កាត់ភ្នំពេញថ្មី ប្រកាសដេញថ្លៃឡើងវិញនូវគម្រោងមូលនិធិសង្កាត់។

**យោង** ៖ - ពាក្យបណ្តឹងរបស់ក្រុមហ៊ុន VP ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧

- លិខិតបង្គាប់ការលេខ ៦៨៧ ល.ប.ក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តមអភិបាលនៃគណៈ-អភិបាលរាជធានីភ្នំពេញ មេត្តាជ្រាបថា ក្រោយពីបានទទួលនូវពាក្យបណ្តឹងរបស់ក្រុមហ៊ុន VP ក្រុមមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានចុះធ្វើការសិក្សាស្រាវជ្រាវពាក្យបណ្តឹងរបស់ក្រុមហ៊ុន VP លើការអនុវត្តនីតិវិធីលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ក្រុមការងារនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានជួបជាមួយគណៈកម្មការលទ្ធកម្ម ចៅសង្កាត់ចាស់ ចៅសង្កាត់ថ្មី មេភូមិដែលទទួលផលពីគម្រោង មន្ត្រីគាំទ្រសង្កាត់នៃទីចាត់ការផែនការ និងវិនិយោគរាជធានីភ្នំពេញ ទីប្រឹក្សាហេដ្ឋា-រចនាសម្ព័ន្ធរាជធានីភ្នំពេញ និងអ្នកពាក់ព័ន្ធមួយចំនួន។

ផ្អែកតាមការចុះស្រាវជ្រាវ និងជួបពិភាក្សាជាមួយអ្នកពាក់ព័ន្ធ អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ពិនិត្យឃើញថា ៖

១. ការដេញថ្លៃបានប្រព្រឹត្តិទៅកាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ បានត្រឹមត្រូវតាមនីតិវិធី។ លទ្ធផលដែលមានតម្លៃទាប និងឈ្នះក្នុងការដេញថ្លៃបានទៅលើក្រុមហ៊ុន VP (មានតម្លៃទាបទី១) ក្នុងទឹកប្រាក់ ៤៩៩.៦៩៦.០០០រៀល។

២. ចៅសង្កាត់បានចេញលិខិតលេខ០០៥ សជណ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការសម្រេចផ្តល់កិច្ចសន្យាដល់ក្រុមហ៊ុន VP (មានតម្លៃទាបទី១) ក្នុងទឹកប្រាក់ ៤៩៩.៦៩៦.០០០រៀល និងអញ្ជើញក្រុមហ៊ុនមកចុះកិច្ចសន្យានៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង៨:០០ព្រឹក នៅសាលាសង្កាត់ភ្នំពេញថ្មី តែអ្នកទទួលការឈ្មោះ **សេន ហេង** មកពីក្រុមហ៊ុន VP មកយឺត ក្រុមប្រឹក្សាសង្កាត់រង់ចាំរហូតដល់ម៉ោង៩:៤០នាទីមិនឃើញ ក៏រំសាយកិច្ចប្រជុំចុះកិច្ចសន្យានោះ (មិនបានប្រជុំទេ)។ ចំណែកក្នុងពាក្យបណ្តឹងអ្នកទទួលការបានបញ្ជាក់ថា ខ្លួនបានទៅដល់សង្កាត់ភ្នំពេញថ្មីយឺតតែស្ថិតក្នុងម៉ោងធ្វើការតែមិនបានជួបចៅសង្កាត់ទេ បានជួបតែមន្ត្រីបច្ចេក-ទេស និងស្មៀនសង្កាត់ នាថ្ងៃខែឆ្នាំដដែល។

៣. ចៅសង្កាត់បានចេញលិខិតមួយលេខ០០៩ ល.ស/អណា៣ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីសម្រេចបញ្ឈប់ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុន VP លើគម្រោងមូលនិធិសង្កាត់ឆ្នាំ២០១៧ ដោយជម្រាបជូនឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញដើម្បីផ្តល់អនុសាសន៍ ដោយមិនមានការប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងដូចយោងក្នុងកំណត់ហេតុក្នុងលិខិតចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ នោះទេ។

៤. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ ចៅសង្កាត់បានចេញលិខិតលេខ០០៧ សជណ ស្តីពីការសម្រេចផ្តល់កិច្ចសន្យាដល់ក្រុមហ៊ុនហៃម៉ានីម៉ិចខនស្ត្រាក់សិនមានតម្លៃទាបទី២ក្នុងទឹកប្រាក់ ៥៧៥.២១៣.៨៤៧រៀល ដោយមិនរង់ចាំការផ្តល់អនុសាសន៍ពីអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញឡើយ។ ក្នុងទឹកប្រាក់ដែលបានដេញថ្លៃ៥៧៥.២១៣.៨៤៧រៀល ដែលមានតម្លៃថ្លៃជាងអ្នកមានតម្លៃទាបទី១ចំនួន៧៥.៥១៧. ៨៤៧ រៀល។

៥. កិច្ចសន្យាដែលផ្តល់ឱ្យក្រុមហ៊ុនមានតម្លៃទាបទី២នោះមិនទាន់ចាប់ផ្តើមអនុវត្តទេ។

ផ្អែកតាមមូលដ្ឋានខាងលើ ការប្រគល់លិខិតកិច្ចសន្យាឱ្យក្រុមហ៊ុនហៃម៉ានីម៉ិចខនស្ត្រាក់សិនមិនស្របតាមនីតិវិធី និងគ្មានតម្លាភាព ដោយសុពលភាពនៃសំណើដេញថ្លៃទាំងអស់បានលើសរយៈពេល៤៥ថ្ងៃ។ ដូច្នេះ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ស្នើឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញចេញសេចក្តីណែនាំទៅរដ្ឋបាលសង្កាត់ភ្នំពេញថ្មីឱ្យលុបលទ្ធផលដេញថ្លៃនេះចោល ហើយប្រកាសដេញថ្លៃសារជាថ្មីចំពោះគម្រោងដដែល។ ចំពោះប្រាក់កក់ធានាការដេញថ្លៃត្រូវប្រគល់ទៅឱ្យអ្នកទទួលការទាំងអស់វិញ។

អាស្រ័យហេតុនេះ សូមឯកឧត្តមអភិបាលរាជធានីភ្នំពេញមេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានពីខ្ញុំ៕

អគ្គនាយក

ប្រាក់ សំអឿន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ: ៣៦៤/១៧ សរ.ជ

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៧

**ជម្រាបមក**

**លោកអភិបាល នៃគណៈអភិបាលខណ្ឌសែនសុខ**

**កម្មវត្ថុ:** ស្តីពីការរៀបចំដេញថ្លៃគម្រោងមូលនិធិសង្កាត់ភ្នំពេញថ្មីឡើងវិញ។

**យោង:** លិខិតលេខ៣០៩៩ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកអភិបាលខណ្ឌ ជ្រាបថា: អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ បានស្នើឲ្យរដ្ឋបាលរាជធានីភ្នំពេញ ចេញសេចក្តីសម្រេចលុបចោលលទ្ធផលដេញថ្លៃ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ របស់រដ្ឋបាលសង្កាត់ភ្នំពេញថ្មី និងណែនាំឲ្យរដ្ឋបាលសង្កាត់ភ្នំពេញថ្មី ប្រកាសដេញថ្លៃឡើងវិញនូវគម្រោងមូលនិធិសង្កាត់ ឆ្នាំ២០១៧ ឡើងវិញ ដោយហេតុថាការដេញថ្លៃកន្លងមក មិនស្របតាមនីតិវិធី និងគ្មានតម្លាភាព។

ដើម្បីឲ្យការដេញថ្លៃគម្រោងមូលនិធិសង្កាត់ភ្នំពេញថ្មីឡើងវិញ ស្របតាមនីតិវិធី និងមានតម្លាភាព រដ្ឋបាលរាជធានីភ្នំពេញ ស្នើឲ្យលោកអភិបាលខណ្ឌ រៀបចំចាត់ចែងដេញថ្លៃឡើងវិញឲ្យបានឆាប់។

អាស្រ័យហេតុនេះ សូមលោកអភិបាល ជ្រាប និងអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារខាងលើ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**ចម្លងជូន:**
- ក្រសួងមហាផ្ទៃ
  -ដើម្បីជូនជ្រាប-
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

## រូបភាពមួយចំនួនស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

1. សកម្មភាពនៃការរៀបចំការសិក្សាគម្រោង
2. សកម្មភាពដេញថ្លៃ
3. សកម្មភាពតាមដានពេលកំពុងអនុវត្ត
4. សកម្មភាពចុះពិនិត្យពេលបញ្ចប់គម្រោង
5. សកម្មភាពចុះជួយគាំទ្រតាមខេត្ត
6. រូបភាពសមិទ្ធិផលថ្មីមួយចំនួនស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧

# សកម្មភាពសិក្សាគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ ២០១៧ ខេត្តកំពង់ធំ




ការចូលរួមរបស់ក្រុមប្រឹក្សាឃុំក្នុងការចុះពិនិត្យទីតាំង និងសិក្សាគម្រោងសាងសង់លូដោះទឹក និងប្រឡាយ នៅភូមិនាងល្អ ឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ជាគម្រោងអាទិភាពក្នុងកម្មវិធីវិនិយោគ ដែលក្រុមប្រឹក្សាប្រជុំអនុម័ត មានក្នុងផែនការថវិកាប្រចាំឆ្នាំ និងបានបញ្ចូលក្នុងផែនការសិក្សាគម្រោងរបស់ទីចាត់ការផែនការ និងវិនិយោគខេត្ត។






ការសិក្សាគម្រោងសាងសង់លូដោះទឹក និង ប្រឡាយ ដោយប្រើប្រាស់ឧបករណ៍ ឋានលេខា ខ្សែម៉ែត្រ និងGPS ដែលបានកត់ត្រានូវកម្រិតកម្ពស់ និងទិន្នន័យសម្រាប់ការគណនាតម្លៃប៉ាន់ស្មានគម្រោងរបស់ឃុំ ទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ

# សកម្មភាពសិក្សាគម្រោងមូលនិធិឃុំ សង្កាត់ខេត្តព្រះវិហារ



ប្រជុំបែងចែកការងារមុននឹងចុះធ្វើឋានលេខា មានមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ ក្រុមប្រឹក្សាឃុំ គណៈកម្មការគ្រប់គ្រងគម្រោង និងអ្នកទទួលផលនៅឃុំកំពង់ស្រឡៅ១ និងឃុំសង្កែ២ ស្រុកឆែប ខេត្តព្រះវិហារ









គ្រោងប្លង់ និងប៉ាន់ស្មានតម្លៃបន្ទាប់ពីទទួលបានទិន្នន័យ

សកម្មភាពពេលកំពុងវាស់វែង និងធ្វើឋានលេខាសម្រាប់គម្រោងផ្លូវក្រាលក្រួសធម្មជាតិឆ្នាំ២០១៧ នៅឃុំកំពង់ស្រឡៅ១ និងឃុំសង្កែ២ ស្រុកឆែប ខេត្តព្រះវិហារ

# សកម្មភាពដេញថ្លៃគម្រោងមូលនិធិឃុំពោធិ៍សាត់



សកម្មភាពដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ក្នុងស្រុកក្រគរចំនួន៨គម្រោង (ឃុំ៧) ក្នុងនោះបាន ជោគជ័យ៦គម្រោង និងបរាជ័យ២គម្រោង (ឃុំសម្រេចប្រកាសដេញថ្លៃឡើងវិញ។



តំណាងគណៈកម្មការលទ្ធកម្មទាំង៧ឃុំ



ទិដ្ឋភាពរួមនៃការដេញថ្លៃទាំង៧ឃុំ





លទ្ធផលនៃការដេញថ្លៃ ស្រុកក្រគរ ខេត្តពោធិ៍សាត់

# សកម្មភាពដេញថ្លៃគម្រោងមូលនិធិឃុំ សែនមនោរម្យ



សមាសភាពគណៈកម្មការលទ្ធកម្ម និងមតិចូលរួមរបស់លោកស្រីមេឃុំស្តីពីគោលការណ៍សំខាន់ៗនៃការដេញថ្លៃ ដល់អ្នកទទួលការមុនប្រកាសដាក់សំណើដេញថ្លៃ នៅឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី





ការបើកសំណើដេញថ្លៃ



ការពិនិត្យផ្ទៀងផ្ទាត់តម្លៃនៃការដេញថ្លៃ



លទ្ធផលដេញថ្លៃ

ការបើកសំណើដេញថ្លៃ និងផ្ទៀងផ្ទាត់តម្លៃឯកតា តម្លៃសរុប និងពិនិត្យសុពលភាពនៃការដេញថ្លៃរបស់គណៈកម្មការលទ្ធកម្ម និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ

## សកម្មភាពដេញថ្លៃគម្រោងមូលនិធិឃុំ នៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ



សកម្មភាពប្រជុំបើកសំណើដេញថ្លៃ គម្រោងមូលនិធិឃុំចំនួន៣មានឃុំកំពេញ ឃុំអូរត្រេះ និងឃុំទំនប់រលក ការដេញថ្លៃមានការប្រកួតប្រជែង និងទទួលបានជោគជ័យទាំងបីគម្រោង



ទិដ្ឋភាពពេលកំពុងប្រជុំដេញ







តារាងបង្ហាញពីលទ្ធផលនៃការដេញ

# គម្រោងផ្លូវបេតុងអាមេមូលនិធិឃុំឆ្នាំ២០១៧ ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ
# ប្រវែង ១.០៣៤ម ទទឹង៤ម និងកម្រាស់១៥០មម





ការរៀបចំដែក ទំហំ៨លី គម្លាត២០០មម



សកម្មភាពចាក់បេតុងរបស់អ្នកទទួលការ



សកម្មភាពបង្ហាប់បេតុងដោយប្រើឧបករណ៍រំញ័រ



ផ្លូវបេតុងអាមេដែលបានចាក់រួច

# សកម្មភាពត្រួតពិនិត្យគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ខេត្តសៀមរាប





ការត្រួតពិនិត្យគុណភាពបេតុងលូជ្រុងមុខបី របស់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ លើគម្រោងមូលនិធិឃុំ ពង្រក្រោម ស្រុកជីក្រែង ឆ្នាំ២០១៧ ដោយប្រើឧបករណ៍ Concrete Hummer (ពិនិត្យភាពរឹងមាំរបស់បេតុង)



ការត្រួតពិនិត្យទទឹងផ្លូវក្រួសក្រហម



ពិនិត្យគុណភាពការកិនបង្ហាប់ក្រួសក្រហម (DCP Test)



ការត្រួតពិនិត្យកម្រាស់ក្រួសក្រហម



ការប្រជុំជាមួយប្រជាពលរដ្ឋជាអ្នកទទួលផល

ការត្រួតពិនិត្យគុណភាពផ្លូវក្រួសក្រហម របស់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ លើគម្រោងមូលនិធិ ឃុំតាសោម ស្រុកអង្គរជុំ ឆ្នាំ២០១៧ មុនចេញរបាយការណ៍បញ្ចប់១០០% ឱ្យម្ចាស់គម្រោងសម្រេចទទួលយក

# សាងសង់ស្ពានឈើក្បាលបេតុងនៅឃុំ ម៉ាលិក ស្រុកអណ្តូងមាស ខេត្តរតនគិរី





ទីតាំងគម្រោងមុនពេលសាងសង់



ដំណាក់កាលបុកគ្រឹះសរសរស្ពាន





ការចុះត្រួតពិនិត្យគម្រោងពេលកំពង់សាងសង់ និងការពន្យល់ណែនាំដល់មន្ត្រីបច្ចេកទេស និងមេការនៅការដ្ឋាន

# សកម្មភាពត្រួតពិនិត្យគម្រោងសាងសង់លូដោះទឹកទីប្រជុំជន ឆ្នាំ២០១៧

## គម្រោងមូលនិធិឃុំព្រែកខ្សាយ(ក) ស្រុកពាមរក៍ ខេត្តព្រៃវែង






ការងារត្រួតពិនិត្យគម្រោងសាងសង់លូដោះទឹក
មូលនិធិឃុំព្រែកខ្សាយ(ក) ស្រុកពាមរក៍
ខេត្តព្រៃវែងឆ្នាំ២០១៧
ការវាស់វែងចំនួនបរិមាណ គុណភាព
និងសោភ័ណភាពរបស់គម្រោង
សមាសភាពចូលរួមដោយគណៈកម្មការគ្រប់គ្រង
គម្រោងឃុំ អ្នកទទួលការ
អ្នកត្រួតពិនិត្យបច្ចេកទេស
និងមន្ត្រីទីចាត់ការផែនការនិងវិនិយោគខេត្ត

រូបភាព





# រូបភាពសមិទ្ធិផលថ្មីមួយចំនួនស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧



សំណង់ស្ពានបេតុងថ្មីទំហំ ៩ម X ៤ម បានបញ្ចប់ការសាងសង់នៅឃុំទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម (Construction Cost = 80,741,818 Riels) មូលនិធិឃុំឆ្នាំ២០១៧



ទីតាំងសំណង់ស្ពានឈើចាស់ នឹងផ្លាស់ប្តូរមកសាងសង់សំណង់ស្ពានបេតុង ៩ម X ៤ម ដោយប្រើប្រាស់មូលនិធិឃុំឆ្នាំ២០១៧ (Cost Estimate = 79,359,800Riels)



សាងសង់ស្ពានឈើក្បាលបេតុងប្រវែង៥0ម ទទឹង៣,៥ម កម្ពស់ពី៧ ទៅ១២ម នៅឃុំថ្មកែវ
ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង (Contract Cost = 89,221,000 Riels) មូលនិធិឃុំឆ្នាំ២០១៦



ទីតាំងសំណង់ស្ពានឈើចាស់ នឹងផ្លាស់ប្ដូរមកសាងសង់ស្ពានឈើក្បាលបេតុង៥0ម X ៣,៥ម
ដោយប្រើប្រាស់មូលនិធិឃុំឆ្នាំ២០១៦ នៅឃុំថ្មកែវ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង




សំណង់លូជ្រុងមុខបីទំហំ ១,៥មx១,៥មx៦ម បានបញ្ចប់ការសាងសង់នៅឃុំពង្រក្រោម ស្រុកជីក្រែង ខេត្តសៀមរាប (Construction Cost = 35.900.000 Riels) មូលនិធិឃុំឆ្នាំ២០១៧



ទីតាំងស្ពានឈើទ្រុឌទ្រោម នឹងផ្លាស់ប្តូរមកសាងសង់សំណង់លូជ្រុងមុខបីទំហំ ១,៥មx១,៥មx៦ម ដោយប្រើប្រាស់មូលនិធិឃុំឆ្នាំ២០១៧ (Cost Estimate = 37.143.900 Riels)



ចុះសិក្សាស្រាវជ្រាវពាក្យបណ្ដឹងរបស់ក្រុមហ៊ុន VP នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ស្ដីពីការអនុវត្តនិតិវិធីលទ្ធកម្មមូលនិធិសង្កាត់នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ (សមាសភាព៖ ចៅសង្កាត់ ក្រុមប្រឹក្សាសង្កាត តំណាងមេភូមិ តំណាងទីចាត់ការផែនការ និងវិនិយោគរាជធានីភ្នំពេញ PIA និងក្រុមការងារបច្ចេកទេសថ្នាក់ជាតិ)



ចុះទៅធ្វើការសិក្សាស្រាវជ្រាវពីការអនុវត្តយឺតនៅឃុំរំចេក ស្រុកព្រះស្ដេច ខេត្តព្រៃវែង ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងពន្លឿនការអនុវត្តឱ្យបានចប់មុនរដូវវស្សា (សមាសភាព៖ មេឃុំ ក្រុមប្រឹក្សាឃុំ តំណាងអ្នកទទួលការ ទីចាត់ការផែនការ និងវិនិយោគខេត្ត PPMA PIA និងក្រុមការងារបច្ចេកទេសថ្នាក់ជាតិ)




ចុះជួយមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តកំពង់ចាម និងខេត្តកែបដែលអវត្តមានទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធដោយផ្តល់នូវការណែនាំពីគំនូសប្លង់បច្ចេកទេស និងរបៀបគណនាតារាងប៉ាន់ស្មានតម្លៃ សម្រាប់ការសិក្សាគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧ និងធ្វើការដំឡើងនូវកម្មវិធី Auto-CAD ថ្មី ArcReader GPS និងគំនូសប្លង់បច្ចេកទេសថ្មីៗ ទើបកែសម្រួលបញ្ចូលក្នុងកុំព្យូទ័ររបស់ TSO សម្រាប់ប្រើប្រាស់បន្តទៀត






រូបភាពក្រោយសាងសង់រួច គម្រោងផ្លូវបេតុងអាមេ ប្រវែង១៨៥ម ទទឹង៦ម ប្រើប្រាស់មូលនិធិ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឆ្នាំ២០១៧ (តម្លៃកិច្ចសន្យា៖ ៩៨,៦៣៣,០០០៛)



រូបភាពមុនសាងសង់គម្រោងផ្លូវបេតុងអាមេ ប្រវែង១៨៥ម ទទឹង៦ម ប្រើប្រាស់មូលនិធិសង្កាត់ លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឆ្នាំ២០១៧ (តម្លៃប៉ាន់ស្មាន៖ ៩០,២៤៦,០០០៛)




ក្រោយពេលសាងសង់សំណង់លូជ្រុងមានទ្វារទឹកនៅស្ថិតនៅក្នុងឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់
ទំហំប្រវែង ៧,៧៥ម កម្ពស់១,៨៥ម តម្លៃសរុប ៥៩.០០០.០០០៛ គម្រោងមូលនិធិឃុំឆ្នាំ២០១៧




ទីតាំងគម្រោងមុនពេលសាងសង់






សំណង់ស្ពានឈើក្បាលបេតុងប្រវែង១៦ម ទទឹង៣,៥ម ចំនួន២កន្លែង បានបញ្ចប់ការសាងសង់ ១០០% តម្លៃកិច្ចសន្យាសាងសង់៩៧.៩០០.០០០ រៀលគត់ ជាគម្រោងមូលនិធិឃុំឆ្នាំ២០១៧ នៅឃុំឆែប១ ស្រុកឆែប ខេត្តព្រះវិហារ

# ខេត្តត្បូងឃ្មុំ



សាងសង់ផ្លូវបេតុងអាមេប្រវែង១ម នៅឃុំក្រែក ស្រុកពញាក្រែក៤ម ទទឹង០៣៤, ខេត្តត្បូងឃ្មុំ
)Construction Cost= 201,348,000 Riels) មូលនិធិឃុំឆ្នាំ២០១៧



សាងសង់ផ្លូវក្រាលក្រួសក្រហមប្រវែង១ ម៣០០,ទទឹង៤ម នៅឃុំកោងកាង ស្រុកពញាក្រែក
ខេត្តត្បូងឃ្មុំ )Construction cost= 57,860,000 Riels) មូលនិធិឃុំឆ្នាំ២០១៧



ពិធីប្រជុំបិទការដ្ឋានសាងសង់ផ្លូវដីស ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ភូមិត្បែងបង្កៀប ឃុំកញ្ជរ ប្រវែង៣.១៨១ម៉ែត្រ ដោយប្រើប្រាស់មូលនិធិឃុំឆ្នាំ២០១៦



# ឧបសម្ព័ន្ធទី៤

## ឧបករណ៍សម្រាប់ជួយគាំទ្រការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ

- តារាងបង្ហាញពីឧបករណ៍ដែលរាជធានី ខេត្តមានប្រើប្រាស់សព្វថ្ងៃ
- តារាងគណនាចំនួនឧបករណ៍ចាំបាច់ដែលតិចបំផុតសម្រាប់បម្រើការងារហេដ្ឋារចនាសម្ព័ន្ធនៅតាមរាជធានី ខេត្ត និង
- តារាងសំណើរសុំទិញឧបករណ៍បន្ថែម សម្រាប់រាជធានី ខេត្ត

# ឧបសម្ព័ន្ធទី៤

# ឧបករណ៍សម្រាប់ជួយគាំទ្រការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ

ការស្រង់ចំនួនឧបករណ៍នេះធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ២០១៦។ ដើម្បីបំពេញតម្រូវការសិក្សាគម្រោងមូលនិធិឃុំ សង្កាត់ប្រចាំឆ្នាំដែលក្នុងខេត្តនីមួយៗមានចំនួនគម្រោងច្រើន តែឧបករណ៍សម្រាប់ចុះសិក្សាគម្រោងមានចំនួនតិច ដែលជាហេតុបណ្តាលឱ្យមន្រ្តីបច្ចេកទេស TSO យើងមានការលំបាក និងបង្កឱ្យការរៀបចំសិក្សាគម្រោងយឺតយ៉ាវ។ ទាក់ទងបញ្ហានេះទីចាត់ការផែនការ និងវិនិយោគខេត្តភាគច្រើន សំណូមពរដល់ថ្នាក់ជាតិមេត្តាជួយទិញឧបករណ៍សម្រាប់សិក្សាគម្រោង និងតាមដានការអនុវត្តគម្រោង។

តារាងនេះបង្ហាញពីឧបករណ៍ដែលខេត្តមានប្រើប្រាស់សព្វថ្ងៃ

| លេខកូដ | ឈ្មោះខេត្ត | | ប្រភេទឧបករណ៍ | | | | |
|---|---|---|---|---|---|---|---|
| | ខ្មែរ | Abbr. | វាស់ស្ទង់ Automatic Level | ក្តារមៀរ Staff | តេស្តបេតុង Hammer Test | ឌីស៊ីភី DCP | ជីភីអេស GPS |
| 1 | បន្ទាយមានជ័យ | MBC | 1 | 2 | 2 | 3 | 4 |
| 2 | បាត់ដំបង | BAT | 4 | 4 | 2 | 4 | 5 |
| 3 | កំពង់ចាម | KPC | 1 | 3 | 0 | 1 | 0 |
| 4 | កំពង់ឆ្នាំង | KCH | 3 | 4 | 1 | 2 | 1 |
| 5 | កំពង់ស្ពឺ | KSP | 1 | 1 | 2 | 4 | 4 |
| 6 | កំពង់ធំ | KPT | 2 | 4 | 1 | 3 | 4 |
| 7 | កំពត | KAM | 2 | 3 | 1 | 3 | 2 |
| 8 | កណ្តាល | KDL | 5 | 2 | 3 | 5 | 4 |
| 9 | កោះកុង | KKG | 2 | 2 | 2 | 2 | 2 |
| 10 | ក្រចេះ | KRT | 2 | 3 | 1 | 2 | 1 |
| 11 | មណ្ឌលគិរី | MKR | 1 | 2 | 0 | 1 | 0 |
| 12 | ភ្នំពេញ | PNP | 3 | 2 | 1 | 1 | 1 |
| 13 | ព្រះវិហារ | PVR | 2 | 1 | 1 | 1 | 2 |
| 14 | ព្រៃវែង | PVG | 4 | 4 | 1 | 4 | 4 |
| 15 | ពោធិ៍សាត់ | PUR | 2 | 2 | 1 | 2 | 0 |
| 16 | រតនគិរី | RAT | 2 | 1 | 1 | 2 | 1 |
| 17 | សៀមរាប | SRP | 3 | 6 | 2 | 2 | 3 |
| 18 | ព្រះសីហនុ | SHV | 1 | 2 | 1 | 1 | 1 |
| 19 | ស្ទឹងត្រែង | STG | 3 | 3 | 1 | 1 | 1 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 20 | ស្វាយរៀង | SVR | 3 | 3 | 1 | 4 | 3 |
| 21 | តាកែវ | TAK | 4 | 3 | 2 | 2 | 6 |
| 22 | ឧត្តមានជ័យ | OMC | 2 | 1 | 1 | 1 | 0 |
| 23 | កែប | KEP | 1 | 1 | 1 | 1 | 0 |
| 24 | ប៉ៃលិន | PLN | 2 | 1 | 0 | 1 | 0 |
| 25 | ត្បូងឃ្មុំ | TKM | 2 | 2 | 2 | 2 | 2 |
| | សរុបទូទាំងប្រទេស | | **58** | **62** | **31** | **55** | **51** |

តាមការគណនាចំនួនឧបករណ៍ចាំបាច់ដែលតិចបំផុតសម្រាប់បម្រើការងារហេដ្ឋារចនាសម្ព័ន្ធនៅតាមខេត្ត Basic of calculation an equipment minimum need by provinces

- ✓ 3 Municipal/District has one Automatic level and 1 an automatic level has 2 staffs
- ✓ 3 Municipal/District has one concrete test hammer
- ✓ 3 Municipal/District has one DCP

ផ្អែកតាមគោលការណ៍ខាងលើបង្ហាញជូនក្នុងតារាងខាងក្រោមនេះ ៖

| លេខកូដ រាជធានី ខេត្ត | ឈ្មោះខេត្ត | | ចំនួនឧបករណ៍ | | | | |
|---|---|---|---|---|---|---|---|
| | ខ្មែរ | Abbr. | ចំនួន ក្រុង ស្រុក | វាស់ស្ទង់ Automatic Level | ក្តារមៀរ Staff | តេស្តបេតុង Hammer Test | ឌីស៊ីភី DCP |
| 1 | បន្ទាយមានជ័យ | MBC | 9 | 3 | 6 | 3 | 3 |
| 2 | បាត់ដំបង | BAT | 14 | 5 | 9 | 5 | 5 |
| 3 | កំពង់ចាម | KPC | 10 | 3 | 7 | 3 | 3 |
| 4 | កំពង់ឆ្នាំង | KCH | 8 | 3 | 5 | 3 | 3 |
| 5 | កំពង់ស្ពឺ | KSP | 8 | 3 | 5 | 3 | 3 |
| 6 | កំពង់ធំ | KPT | 8 | 3 | 5 | 3 | 3 |
| 7 | កំពត | KAM | 8 | 3 | 5 | 3 | 3 |
| 8 | កណ្តាល | KDL | 11 | 4 | 7 | 4 | 4 |
| 9 | កោះកុង | KKG | 7 | 2 | 5 | 2 | 2 |
| 10 | ក្រចេះ | KRT | 6 | 2 | 4 | 2 | 2 |
| 11 | មណ្ឌលគិរី | MKR | 5 | 2 | 3 | 2 | 2 |
| 12 | ភ្នំពេញ | PNP | 12 | 4 | 8 | 4 | 4 |
| 13 | ព្រះវិហារ | PVR | 8 | 3 | 5 | 3 | 3 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 14 | ព្រៃវែង | PVG | 13 | 4 | 9 | 4 | 4 |
| 15 | ពោធិ៍សាត់ | PUR | 6 | 2 | 4 | 2 | 2 |
| 16 | រតនគិរី | RAT | 9 | 3 | 6 | 3 | 3 |
| 17 | សៀមរាប | SRP | 12 | 4 | 8 | 4 | 4 |
| 18 | ព្រះសីហនុ | SHV | 4 | 1 | 3 | 1 | 1 |
| 19 | ស្ទឹងត្រែង | STG | 5 | 2 | 3 | 2 | 2 |
| 20 | ស្វាយរៀង | SVR | 8 | 3 | 5 | 3 | 3 |
| 21 | តាកែវ | TAK | 10 | 3 | 7 | 3 | 3 |
| 22 | ឧត្តមានជ័យ | OMC | 5 | 2 | 3 | 2 | 2 |
| 23 | កែប | KEP | 2 | 1 | 1 | 1 | 1 |
| 24 | ប៉ៃលិន | PLN | 2 | 1 | 1 | 1 | 1 |
| 25 | ត្បូងឃ្មុំ | TKM | 7 | 2 | 5 | 2 | 2 |
| | | | **197** | **66** | **131** | **66** | **66** |

ដោយយោងលើតារាងចំនួនឧបករណ៍ចាំបាច់ដែលតិចបំផុតសម្រាប់បម្រើការងារហេដ្ឋារចនាសម្ព័ន្ធនៅតាមខេត្ត ធៀបនឹងតារាងស្រង់ឧបករណ៍ដែលខេត្តមានប្រើប្រាស់សព្វថ្ងៃ សំណូមពរទិញបន្ថែមនូវឧបករណ៍មួយចំនួនដូចជា៖១) **ឧបករណ៍វាស់ស្ទង់ ចំនួន១២គ្រឿង ២) ក្តារមៀរ ចំនួន៦៩ដើម នឹងនៅដំណាក់កាលនៃការត្រួតពិនិត្យត្រូវការឧបករណ៍ DCP ចំនួន១៥គ្រឿង និងឧបករណ៍តេស្តបេតុងចំនួន៣៥គ្រឿងបន្ថែមទៀត** សូមជម្រាបថាឧបករណ៍តេស្តបេតុងបានប្រើប្រាស់ច្រើនព្រោះគម្រោងមូលនិធិឃុំ សង្កាត់បច្ចុប្បន្នបានប្តូរមកធ្វើផ្លូវបេតុងអាមេច្រើន។ ចំពោះឧបករណ៍ GPS និង Camera អាចប្រើបានជាមួយទូរស័ព្ទ Smart Phone និងខ្សែម៉ែត្រ ៧.៥ម ឬ៥០ម ខេត្តអាចទិញបាន។

## សំណើរសុំទិញឧបករណ៍បន្ថែម

| លេខកូដ រាជធានី ខេត្ត | ឈ្មោះរាជធានី ខេត្ត | | ចំនួនឧបករណ៍ | | | | |
|---|---|---|---|---|---|---|---|
| | ខ្មែរ | Abbr. | ចំនួន ក្រុង ស្រុក | វាស់ស្ទង់ Automatic Level | ក្តារមៀរ Staff | តេស្តបេតុង Hammer Test | ឌីស៊ីភី DCP |
| 1 | បន្ទាយមានជ័យ | MBC | 9 | 2 | 4 | 1 | 0 |
| 2 | បាត់ដំបង | BAT | 14 | 1 | 5 | 3 | 1 |
| 3 | កំពង់ចាម | KPC | 10 | 2 | 4 | 3 | 2 |
| 4 | កំពង់ឆ្នាំង | KCH | 8 | 0 | 1 | 2 | 1 |
| 5 | កំពង់ស្ពឺ | KSP | 8 | 2 | 4 | 1 | 0 |
| 6 | កំពង់ធំ | KPT | 8 | 1 | 1 | 2 | 0 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 7 | កំពត | KAM | 8 | 1 | 2 | 2 | 0 |
| 8 | កណ្តាល | KDL | 11 | 0 | 5 | 1 | 0 |
| 9 | កោះកុង | KKG | 7 | 0 | 3 | 0 | 0 |
| 10 | ក្រចេះ | KRT | 6 | 0 | 1 | 1 | 0 |
| 11 | មណ្ឌលគិរី | MKR | 5 | 1 | 1 | 2 | 1 |
| 12 | ភ្នំពេញ | PNP | 12 | 1 | 6 | 3 | 3 |
| 13 | ព្រះវិហារ | PVR | 8 | 1 | 4 | 2 | 2 |
| 14 | ព្រៃវែង | PVG | 13 | 0 | 5 | 3 | 0 |
| 15 | ពោធិ៍សាត់ | PUR | 6 | 0 | 2 | 1 | 0 |
| 16 | រតនគិរី | RAT | 9 | 1 | 5 | 2 | 1 |
| 17 | សៀមរាប | SRP | 12 | 1 | 2 | 2 | 2 |
| 18 | ព្រះសីហនុ | SHV | 4 | 0 | 1 | 0 | 0 |
| 19 | ស្ទឹងត្រែង | STG | 5 | 0 | 0 | 1 | 1 |
| 20 | ស្វាយរៀង | SVR | 8 | 0 | 2 | 2 | 0 |
| 21 | តាកែវ | TAK | 10 | 0 | 4 | 1 | 1 |
| 22 | ឧត្តមានជ័យ | OMC | 5 | 0 | 2 | 1 | 1 |
| 23 | កែប | KEP | 2 | 0 | 0 | 0 | 0 |
| 24 | ប៉ៃលិន | PLN | 2 | 0 | 0 | 1 | 0 |
| 25 | ត្បូងឃ្មុំ | TKM | 7 | 0 | 3 | 0 | 0 |
| | | | **197** | **12** | **69** | **35** | **15** |



# ឧបសម្ព័ន្ធទី៥

បញ្ជីទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងអ្នកពាក់ព័ន្ធការងារ

## LIST OF PROVINCIAL INFRASTRUCTURE ADVISOR

**Update: 04 / Dec /2017**

| Pro. GIS | Name in English | ឈ្មោះជាខ្មែរ | Current duty station | SEX | Phone number | EOD | E-mail address |
|---|---|---|---|---|---|---|---|
| NIA | Uch Chan Vuthy | អ៊ុច ច័ន្ទវុឌ្ឍី | GDA/MoI | M | 012 630 281 | 05-Jan-09 | chanvuthy@ncdd.gov.kh |
| 1 | Kea Channy | គា ចាន់នី | BMC | M | 012 820 760 | 01-Jul-13 | kea.channy@bmc.ncdd.gov.kh |
| 2 | | | BAT | | | | |
| 3 | So Saran (2) | សូ សារ៉ន | KPC | M | 012 381 960 | 15-Aug-17 | sosaran@kpc.ncdd.gov.kh |
| 4 | Uon Sophal | អួន សុផល | KCH | F | 016 935 584 | 14-Jul-97 | sophal.uon@kch.ncdd.gov.kh |
| 5 | Kong Chanty | គង់ ចាន់ទី | KSP | M | 012 676 618 | 07-May-07 | chanty.kong@ksp.ncdd.gov.kh |
| 6 | Yin Sobin | យិន សុបិន្ត | KPT | M | 017 990 907 | 21-Apr-11 | sobin@kpt.ncdd.gov.kh |
| 7 | Oum Chhaynoy | អ៊ុំ ឆាយណយ | KAM | M | 017 664 321 | 07-Aug-17 | oumchhaynoy@kam.ncdd.gov.kh |
| 8 | Vann Monika | វ៉ាន់ ម៉ូនីកា | KDL | M | 017 582 588 | 10-Jun-13 | monika@kdl.ncdd.gov.kh |
| 9 | Tuy Lalin (2) | ទុយ ឡាលីន | KKG | M | 012 733 895 | 18-Apr-16 | lalin@kkg.ncdd.gov.kh |
| 10 | Noun Syrath | នួន ស៊ីរ៉ាត់ | KRT | M | 092 569 126 | 29-Jul-02 | nounsyrath@krt.ncdd.gov.kh |
| 11 | Nhim Panha | ញឹម បញ្ញា | MKR | M | 017 912 492 | 18-Apr-16 | panha@mkr.ncdd.gov.kh |
| 12 | Mom Sokany | មុំ សុកានី | PNP | M | 012 947 359 | 01-Jun-06 | sokany.mom@pnp.ncdd.gov.kh |
| 13 | Hen Visal | ហែន វិសាល | PVR | M | 099 671 672 | 10-May-07 | visal.hen@pvr.ncdd.gov.kh |
| 14 | Hem Samott | ហែម សមុទ្ទ | PVG | M | 012 912 107 | 01-Mar-00 | samott@pvg.ncdd.gov.kh |
| 15 | Keo Sam Ol | កែវ សំអុល | PUR | M | 012 928 922 | 01-Jun-93 | samol@pur.ncdd.gov.kh |
| 16 | Smann Vannimith | ស្មាន់ វណ្ណនិមិ្មត្រ | RAT | M | 012 809 840 | 17-May-12 | smann.vannimith@rat.ncdd.gov.kh |
| 17 | Khat Sotharith | ខាត់ សុដ្ឋារិទ្ធ | SRP | M | 012 888 234 | 01-Jun-11 | khat.sotharith@srp.ncdd.gov.kh |
| 18 | Sok Chan Thoeun | សុក ចាន់ធឿន | SHV | M | 092 812 591 | 02-May-12 | chanthoeun@shv.ncdd.gov.kh |
| 19 | Kong Sothak (2) | គង់ សុថាក់ | STG | M | 097 806 5658 | 05-Dec-05 | sothak@stg.ncdd.gov.kh |
| 20 | Mourn Sokhom | មួន សុខុម | SVR | M | 012 643 857 | 01-Sep-12 | mournsokhom@svr.ncdd.gov.kh |
| 21 | | | TAK | | | | |
| 22 | Khat Khema | ខាត់ ខេម៉ា | OMC | M | 012 757 832 | 01-May-11 | khema@omc.ncdd.gov.kh |
| 23 | Chea Darith (TSO) | ជា ដារិទ្ធ | KEP | M | 097 235 4000 | 01-Jan-11 | cheadarith.kep@gmail.com |
| 24 | Yam Ith (PID) | យ៉ាន់ អិត | PLN | M | 012 722 437 | 01-Nov-00 | yan.ith@pln.ncdd.gov.kh |
| 25 | Mang Hongkry | ម៉ង់ ហុងគ្រី | TMK | M | 012 299 744 | 01-Jul-13 | kry@tkm.ncdd.gov.kh |

| No | MoI/NCDDS | ឈ្មោះជាខ្មែរ | MoI | SEX | Phone number | EOD | Email address |
|---|---|---|---|---|---|---|---|
| 1 | Tan Samnang | តាន់ សំណាង | DDC | M | 012 722 280 | | tansamnang2002@yahoo.com |
| 2 | Chhun Bunnara | ឈុន ប៊ុនណារ៉ា | NCDDS | M | 017 553 586 | 01-Jan-10 | cbunnara@ncdd.gov.kh |
| 3 | Min Sitha | មិន ស៊ីថា | DDC | M | 012 995 143 | | min.sitha@yahoo.com |
| 4 | Ing Chhe | អ៊ឹង ឆៃ | DDC | M | 012 216 154 | | chhechheing@yahoo.com |
| 5 | Heng Kungmeng | ហេង គង់ម៉េង | DDC | M | 011 711 900 | | kongmeng_heng@yahoo.com |
| 6 | Dy Rado | ឌី រ៉ាដូ | DDC | M | 012 500 801 | | dy_rado@yahoo.com |
| 7 | Say Sinoun | សាយ ស៊ីនួន | DDC | M | 017 373 551 | | saysinoun@gmail.com |
| 8 | Sim Rithy | ស៊ីម រិទ្ធី | DDC | M | 012 468 087 | | simrithy@yahoo.com |
| 9 | Heng Sengkim | ហេង សេងគីម | DDC | M | 011 543 303 | | sengkim.h@gmail.com |
| 10 | Sun Chhunhieng | ស៊ុន ឈុនហៀង | GDA | M | 012 372 017 | | sunchhunhieng@gmail.com |
| 11 | Preap Phirom | ព្រាប ភិរម្យ | GDA | M | 098 995 579 | | phirom.preap@yahoo.com |

..(2).. ចេញ-ចូល ពីរដងហើយ !!!

Note: EOD - Entry Of Date

KEP & PLN, PIA from KAM & BAT will support this provinces

## បញ្ជីរាយនាមមន្ត្រីការិយាល័យគាំទ្រគម្រោងក្រុង ស្រុក ឃុំ សង្កាត់

| ល.រ | គោត្តនាម និងនាម | ភេទ | មុខតំណែងបច្ចុប្បន្ន | ចូលបម្រើការងារ | អ៊ីម៉ែល | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|
| ០១ | មិន ស៊ីថា<br>MIN SITHA | ប | អនុប្រធាននាយកដ្ឋាន | 11/8/1994 | min.sitha@yahoo.com | 012 995 143 |
| ០២ | ម៉ក់ ដុល្លា<br>MAK DOLLA | ប | អនុប្រធាននាយកដ្ឋាន | 28/6/1998 | makdolla89@gmail.com | 017 898 977 |
| ០៣ | មាស ឈីវហ៊ុន<br>MEAS CHIVHUN | ប | អនុប្រធាននាយកដ្ឋាន | 23/6/2008 | chhivhun.meas@hotmail.com | 078 334 335 |
| ០៤ | | | ប្រធានការិយាល័យ | | | |
| ០៥ | លីម កេតដារ៉ាត<br>LIM KETHDARATH | ប | អនុប្រធានការិយាល័យ | 17/12/1998 | Darath168B@gmail.com | 012 520 808 |
| ០៦ | សាយ ស៊ីនួន<br>SAY SINOUN | ប | អនុប្រធានការិយាល័យ | 08/10/2008 | saysinoun@gmail.com | 017 373 551 |
| ០៧ | នួន សុខជា<br>NOUN SOKCHEA | ប | អនុប្រធានការិយាល័យ | 01/2/1996 | | 017 279 595 |
| ០៨ | ហេង សេងគីម<br>HENG SENGKIM | ប | អនុប្រធានការិយាល័យ | 04/12/2013 | sengkim.h@gmail.com | 011 543 303 |
| ០៩ | ប៊ី សោភ័ណ<br>BY SOPHAN | ប | មន្ត្រី | 01/6/1989 | sophanby2013@gmail.com | 012 812 797 |
| ១០ | ហុក សុខម៉េង<br>HOK SOKMENG | ប | មន្ត្រី | 08/10/2012 | hoksokmeng@yahoo.com | 090 888 898 |
| ១១ | សាយ ចាន់តារា<br>SAY CHANDARA | ប | មន្ត្រី | 11/5/2012 | chandara.dita@gmail.com | 017 986 985 |
| ១២ | កែវ សាវុធ<br>KEO SAVUTH | ប | មន្ត្រី | 12/1/2012 | keosavuth0027@yahoo.com | 012 855 379 |
| ១៣ | អ៊ុង សៅវ៍ណារ៉ាប | ស | មន្ត្រី | ព្យួរការងាររយៈពេល២ឆ្នាំ(០១/១០/២០១៦ ដល់ ០៥/១០/២០១៨) | | |
| ១៤ | ហាក់ ព្រីសុហ្គង់ | ប | មន្ត្រី | ព្យួរការងាររយៈពេល២ឆ្នាំ(០១/១២/២០១៧ ដល់ ០១/១២/២០១៩) | | |

☞ បញ្ចប់បញ្ជីត្រឹមចំនួន១៤រូប (ស្ត្រីចំនួន០១រូប)

ការរៀបចំណើគម្រោងចប់ និងបានប្រកាសដេញថ្លៃ

Contract carry out to implement

| Year | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec | Project |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2011 | 0% | 0% | 0% | 0% | 12% | 16% | 19% | 30% | 43% | 59% | 73% | 85% | 1697 |
| 2012 | 0% | 0% | 4% | 17% | 27% | 42% | 53% | 63% | 75% | 81% | 89% | 95% | 1849 |
| 2013 | 0% | 0% | 4% | 21% | 27% | 61% | 80% | 88% | 92% | 94% | 99% | 99% | 1784 |
| 2014 | 0% | 0% | 4% | 14% | 26% | 49% | 50% | 77% | 83% | 90% | 94% | 98% | 1711 |
| 2015 | 0% | 1% | 8% | 22% | 35% | 51% | 65% | 75% | 85% | 90% | 96% | 99% | 1723 |
| 2016 | 0% | 0% | 8% | 15% | 28% | 46% | 64% | 72% | 84% | 91% | 96% | 99% | 1713 |
| 2017 | 0% | 0% | 4% | 23% | 38% | 59% | 63% | 71% | 78% | 86% | 92% | 98% | 1754 |

| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 2011 to 2012 | 98% | 99% | 99% | | ១% លើកមកបញ្ចូលជាមួយគម្រោងឆ្នាំ២០១២ | | | | | | | |
| 2012 to 2013 | 99% | 99% | 99% | | ១% លើកមកបញ្ចូលជាមួយគម្រោងឆ្នាំ២០១៣ | | | | | | | |
| 2013 to 2014 | 100% | | | | | | | | | | | |
| 2014 to 2015 | 100% | | | | | | | | | | | |
| 2015 to 2016 | 98% | | | | 99% | ១% លើកមកបញ្ចូលជាមួយគម្រោងឆ្នាំ២០១៦ | | | | | | |
| 2016 to 2017 | 99% | 99% | 99% | | | | | | | | | |
| 2017 to 2018 | | | | | | | | | | | | |







ការចុះកិច្ចសន្យា ធៀបនឹងចំនួនកិច្ចសន្យាសរុបប្រចាំឆ្នាំ

| Year | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec | Contract |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2011 | 0 | 0 | 0 | 0 | 2% | 4% | 15% | 19% | 33% | 46% | 57% | 83% | 1697 |
| 2012 | 0% | 0% | 2% | 9% | 19% | 36% | 45% | 55% | 64% | 71% | 79% | 90% | 1849 |
| 2013 | 0% | 0% | 0% | 8% | 15% | 30% | 52% | 61% | 72% | 80% | 87% | 93% | 1784 |
| 2014 | 0% | 0% | 1% | 7% | 12% | 29% | 31% | 52% | 62% | 69% | 79% | 92% | 1711 |
| 2015 | 0% | 0% | 0% | 3% | 13% | 28% | 41% | 53% | 70% | 76% | 83% | 92% | 1723 |
| 2016 | 0% | 0% | 0% | 3% | 10% | 21% | 39% | 54% | 64% | 72% | 83% | 93% | 1713 |
| 2017 | 0% | 0% | 0% | 5% | 17% | 38% | 45% | 49% | 58% | 69% | 75% | 88% | 1754 |

| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 2011 to 2012 | 95% | 95% | 98% | 100% | | | | | | | | |
| 2012 to 2013 | 98% | 99% | 100% | | | | | | | | | |
| 2013 to 2014 | 98% | 100% | | | | | | | | | | |
| 2014 to 2015 | | | 98% | 100% | | | | | | | | |
| 2015 to 2016 | 95% | | 97% | | 100% | 100% | | | | | | |
| 2016 to 2017 | 96% | 99% | 99% | 99% | | | | | | | | |
| 2017 to 2018 | | | | | | | | | | | | |







ការអនុវត្តចប់ការសាងសង់ ១០០% ធៀបចំនួនកិច្ចសន្យាដែលបានចុះក្នុងខែ

| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec | Impl. |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2011 | 0% | 0% | 0% | 0% | 0% | 0% | 1% | 3% | 6% | 8% | 10% | 20% | 1697 |
| 2012 | 0% | 0% | 0% | 0% | 0% | 2% | 9% | 18% | 31% | 35% | 40% | 45% | 1849 |
| 2013 | 0% | 0% | 0% | 0% | 0% | 9% | 16% | 29% | 39% | 43% | 47% | 50% | 1784 |
| 2014 | 0% | 0% | 0% | 0% | 2% | 9% | 16% | 29% | 37% | 41% | 45% | 49% | 1711 |
| 2015 | 0% | 0% | 0% | 0% | 4% | 8% | 18% | 32% | 38% | 45% | 49% | 55% | 1723 |
| 2016 | 0% | 0% | 0% | 2% | 4% | 5% | 10% | 17% | 29% | 36% | 37% | 44% | 1713 |
| 2017 | 0% | 0% | 0% | 1% | 1% | 1% | 14% | 23% | 30% | 32% | 35% | 39% | 1754 |

| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sept | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 2011 to 2012 | 26% | 34% | 46% | 62% | 68% | 76% | 82% | 86% | 89% | 89% | 90% | 91% |
| 2012 to 2013 | 56% | 63% | 72% | 81% | 85% | 90% | 95% | 97% | 98% | 98% | | |
| 2013 to 2014 | 58% | 65% | 70% | 80% | 84% | 90% | 93% | 96% | 97% | | | |
| 2014 to 2015 | | | 72% | | | 90% | | | | | 98% | 99% |
| 2015 to 2016 | 63% | | | 80% | 87% | 92% | 95% | | | | | |
| 2016 to 2017 | 49% | 57% | 66% | 73% | 78% | | 88% | | 91% | 93% | 93% | |
| 2017 to 2018 | | | | | | | | | | | | |




